សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជានាពេលបច្ចុប្បន្ន
## ( ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន )

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក. មាន ពេជ្រដាប៊ីណា**

**សីហា ឧត្តម**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **សីហា ឧត្តម** និង នាងខ្ញុំ **មាន ពេជ្រដាប៊ីណា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ជំនាន់ទី ១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ សូមធ្វើការគោរព និងថ្លែងអំណរគុណជូនចំពោះ ៖

- លោកឪពុក និង អ្នកម្តាយជាទីគោរពនៃកូន
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង
- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត**
- លោកគ្រូ អ្នកគ្រូប្រចាំថ្នាក់សិក្សា
- លោកគ្រូ អ្នកគ្រូនៃការិយាល័យស្រាវជ្រាវ
- សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់
- សាស្ត្រាចារ្យនៃមជ្ឈមណ្ឌលស្រាវជ្រាវនិង អប់រំអំពីច្បាប់ជប៉ុនទាំងអស់

ដែលលោកជាអ្នកមានគុណបានផ្តល់នូវកំណើត ព្រមទាំងការចិញ្ចឹមបីបាច់ថែទាំអប់រំ ទូន្មានប្រៀនប្រដៅ ហើយបានផ្គត់ផ្គង់គ្រប់បែបយ៉ាងដើម្បីជម្រុញលទ្ធភាពឱ្យកូនបានសិក្សា យ៉ាងសមរម្យ តាំងពីថ្នាក់ទាបរហូតដល់បានរៀនចប់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យា-សាស្ត្រសេដ្ឋកិច្ច ដោយពុំមានការខ្វះខាតឡើយ ដើម្បីបណ្តុះបណ្តាលកូនមានចំណេះវិជ្ជាជំនាញដ៏ពិសិដ្ឋ រហូតជោគជ័យបានលទ្ធផលគួរជាទីគាប់ចិត្ត។

យើងខ្ញុំសូមថ្លែងអំណរគុណឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោកសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំយកចិត្តទុកដាក់ ចំណាយកម្លាំង និង ពេលវេលាដ៏មានតម្លៃរបស់លោកដើម្បីបណ្តុះបណ្តាលចែករំលែកចំណេះដឹងរួមមានទាំងបទពិសោធន៍ទាំងឡាយដល់ យើងខ្ញុំ និង មិត្តនិស្សិតរួមថ្នាក់ទាំងអស់។ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ដែលបានណែនាំ លើកទឹកចិត្ត និងបណ្តុះបណ្តាល ទាំងចំណេះដឹង ព្រមទាំងការលើកទឹកចិត្ត ក្នុងរយៈពេលកន្លងទៅនេះ។ គុណូបការៈដ៏ថ្លៃថ្លា ទាំងនេះធ្វើឱ្យយើងខ្ញុំដឹងគុណនិងចងចាំជានិច្ចមិនអាចបំភ្លេចបាននិងសូមប្រសិទ្ធពរជ័យ សូមលោកអ្នកមានគុណ និង លោកសាស្ត្រាចារ្យបានជួបប្រទះតែគុណបុណ្យ ព្រះរតនត្រ័យ ដែលជាវត្ថុស័ក្តសិទ្ធិក្នុងលោកមាន ពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលា ព្រមទាំង ពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។ ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអំពីយើងខ្ញុំ ។

# អារម្ភកថា

ជាទូទៅនៅក្នុងការធ្វើច្បាប់គេកត់សម្គាល់ឃើញថាមានតែអំណាចនីតិបញ្ញត្តិដែលក្នុងនោះរួមមានព្រឹទ្ធសភា និង រដ្ឋសភាដែលជាស្ថាប័នក្នុងការបង្កើត និង អនុម័តច្បាប់។រីឯស្ថាប័ននីតិប្រតិបត្តិវិញក៏មានអំណាច នៅក្នុងការធ្វើច្បាប់ដែរ ដែលគេហៅថាសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ជូនឱ្យរដ្ឋសភា និង ព្រឹទ្ធសភា អនុម័ត។ ជាមួយគ្នានេះផងដែរ ដើម្បីធានាបាននូវការមិនបំពានទៅលើរដ្ឋធម្មនុញ្ញ និង ច្បាប់ទាំងឡាយ ពីសំណាក់ រដ្ឋសភា ព្រឹទ្ធសភា និង រាជរដ្ឋាភិបាល ក្រោយពីបានបង្កើតរួចមក និងដើម្បីត្រួតពិនិត្យធម្មនុញ្ញភាព នៃច្បាប់ដែលបានធ្វើរួចហើយនោះ គេបានបង្កើតស្ថាប័នមួយទៀត ដែលគេហៅថា **ក្រុមប្រឹក្សាធម្មនុញ្ញ** ហើយខ្លះទៀតឱ្យឈ្មោះថា **តុលាការធម្មនុញ្ញ** ហើយនៅព្រះរាជាណាចក្រកម្ពុជាយើង រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើត ឱ្យមានស្ថាប័ននេះដែរ ដោយឱ្យឈ្មោះថា **ក្រុមប្រឹក្សាធម្មនុញ្ញ** ដែលជាស្ថាប័នឯករាជ្យ និង អព្យាក្រឹត្យ ហើយមានសមត្ថកិច្ចក្នុងការត្រួត ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលរដ្ឋសភា និង ព្រឹទ្ធសភាបានអនុម័តរួចរាល់។

ចំណែកឯនៅប្រទេសជប៉ុនវិញដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ និង ប្រព័ន្ធស៊ីវិលឡដែរ ឃើញថា ការត្រួតពិនិត្យធម្មនុញ្ញភាពគឺពុំមានស្ថាប័ននៅក្នុងការត្រួតពិនិត្យ ឱ្យមានឈ្មោះថា ក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការធម្មនុញ្ញ នោះឡើយ។ នៅក្នុងនោះចំពោះការត្រួតពិនិត្យធម្មនុញ្ញភាពគឺយើងសង្កេត ឃើញថាអាចពិនិត្យទៅបានដោយមានបណ្តឹងរឿងអធម្មនុញ្ញភាព តែប៉ុណ្ណោះ។គឺតុលាការគ្រប់ជាន់ថ្នាក់ នៅប្រទេសជប៉ុនអាចពិនិត្យ មើលទៅលើបញ្ហាធម្មនុញ្ញភាពរបស់ច្បាប់ដែលបានប្រកាសឱ្យប្រើរួចទៅហើយ។

ប្រធានបទស្តីពី "**ការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជានាពេលបច្ចុប្បន្ន (ករណីសិក្សាប្រៀបធៀបនឹងប្រទេសជប៉ុន)** "គឺជាប្រធានបទមួយដែលមានសារៈសំខាន់ដើម្បីឱ្យស្គាល់ និងយល់ ដឹងអំពីស្ថាប័ននៃការត្រួតពិនិត្យធម្មនុញ្ញភាព ប្រព័ន្ធច្បាប់កម្ពុជា និង ជប៉ុន ដែលជាការសិក្សាប្រៀបធៀបនៃប្រព័ន្ធនីតិប្រៀបធៀប ថា តើរវាងប្រទេសកម្ពុជាយើង និង ប្រទេសជប៉ុន តើស្ថាប័ននៃការត្រួតពិនិត្យធម្មនុញ្ញភាពមានលក្ខណៈដូចម្តេច? ការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ប្រទេសទាំងពីរឈរលើគោលការណ៍អ្វីខ្លះ?តើសេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពមានអានុភាពនិង ការអនុវត្តយ៉ាងណា? ស្ថាប័នដែលត្រួតពិនិត្យធម្មនុញ្ញភាពនៃប្រទេសទាំងពីរនេះ គឺ ប្រព្រឹត្តទៅដោយមានសមាសភាពណា ចូលរួមក្នុងការពិនិត្យ និង បកស្រាយ?

យើងខ្ញុំសូមទទួលយកដោយសេចក្តីរីករាយនូវរាល់មតិកែលម្អន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានដើម្បីបំពេញចំណុចខ្វះខាត ដោយប្រការណាមួយ។

# មាតិកា

ទំព័រ

**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**មាតិកា**

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១ កំណើតនៃការត្រួតពិនិត្យធម្មនុញ្ញភាព** ........................ ៧

**ផ្នែកទី១ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅអឺរ៉ុប** ....... ៧

**ផ្នែកទី២ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជា** ..... ៩

**កថាខណ្ឌទី១ ប្រវត្តិនៃការកកើត** ........................ ៩

១.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ........................ ៩

២.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ........................ ១០

៣.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ............ ១១

៤.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិត ........ ១២

៥.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា ........................ ១២

៦.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២ .... ១២

**កថាខណ្ឌទី២ សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា** ........................ ១៣

១.នីតិវិធីតែងតាំងសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញដោយអង្គព្រះមហាក្សត្រ ........... ១៣

២.នីតិវិធីជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយរដ្ឋសភា ........................ ១៣

២.១.ការជ្រើសតាំងនៅអាណត្តិទី១ ........................ ១៣

២.២.ការបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបន្តបន្ទាប់ ........................ ១៤

៣.នីតិវិធីជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ..................... ១៤
៤.លក្ខខណ្ឌទូទៅក្នុងការជ្រើសតាំង និង តែងតាំង ..................... ១៤
៥.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំង ..................... ១៥
៥.១.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា ..................... ១៥
៥.២.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ..................... ១៥
ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ..................... ១៥
**ផ្នែកទី៣ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ..................... ១៧**
**កថាខណ្ឌទី១ ប្រវត្តិនៃការកកើត ..................... ១៧**
១.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសម័យម៉េជិ ..................... ១៧
២.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្ន ..................... ១៨
**កថាខណ្ឌទី២ ការរៀបចំបង្កើតស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុននាពេលបច្ចុប្បន្ន ..................... ២០**
**កថាខណ្ឌទី៣ អំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ..................... ២២**
**ជំពូកទី២ សមត្ថកិច្ចនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា និង ប្រទេស ជប៉ុន ..................... ២៤**
**ផ្នែកទី១ ការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជា ..................... ២៤**
**កថាខណ្ឌទី១ គោលការណ៍ត្រួតពិនិត្យធម្មនុញ្ញភាព ..................... ២៤**
**កថាខណ្ឌទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិភាព និង បច្ឆាភាព ..................... ២៧**
១.ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល ..................... ២៧

១.១.ការត្រួតពិនិត្យធម្មនុញ្ញភាព ច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ព្រឹទ្ធសភា ........ ២៨
១.២.មតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើសុំធ្វើវិសោធនកម្មច្បាប់ ........ ២៨
២.ការត្រួតពិនិត្យជាបច្ឆាកាល ........ ៣០
**កថាខណ្ឌទី៣ អ្នកមានសិទ្ធិស្នើសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាព** ........ ៣១
**ផ្នែកទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន** ........ ៣២
**កថាខណ្ឌទី១ គោលការណ៍ការត្រួតពិនិត្យធម្មនុញ្ញភាព** ........ ៣២
១. ទ្រឹស្ដីទូទៅ（総説） ........ ៣២
២ .គោលការណ៍សន្មត់ថាស្របនឹងរដ្ឋធម្មនុញ្ញ（合憲性推定の原則） ........ ៣២
៣. ទ្រឹស្ដីមូលដ្ឋានពីរត្រួតគ្នា（「二重の基準」論） ........ ៣៣
៤. គោលការណ៍មូលដ្ឋានត្រួតពិនិត្យរបស់ទ្រឹស្ដីផ្សេងៗ ........ ៣៤
៤. ១.សេចក្ដីកំណត់យ៉ាងទូលំលាយពេក និង ការទប់ស្កាត់ទុកជាមុន ........ ៣៤
៤. ២.សេចក្ដីកំណត់អត្ថន័យបញ្ចេញមតិ（表現内容の規制） ........ ៣៥
៤. ៣.សេចក្ដីកំណត់ពីពេលវេលា ទីកន្លែង វិធីសាស្ត្រនៃការបញ្ចេញមតិ（表現の時・所・方法の規制） ........ ៣៥
៤. ៤.សេចក្ដីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制） ........ ៣៥
៤. ៥.មូលដ្ឋានត្រួតពិនិត្យផ្អែកលើយុទ្ធសាស្ត្រសាលដីការបស់តុលាការកំពូល（判例における審査基準） ........ ៣៦
**កថាខណ្ឌទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល និង បច្ឆាកាល** ........ ៣៧
១.ការត្រួតពិនិត្យជាអាទិកាល ........ ៣៧
១.១.ការត្រួតពិនិត្យធម្មនុញ្ញភាព ដោយស្ថាប័ននីតិប្រតិបត្តិ ........ ៣៧
១.២.ការត្រួតពិនិត្យធម្មនុញ្ញភាព ដោយស្ថាប័ននីតិបញ្ញត្តិ ........ ៣៩
២.ការត្រួតពិនិត្យជាបច្ឆាកាល ដោយស្ថាប័នតុលាការ ........ ៤០

**កថាខណ្ឌទី៣ អ្នកដែលមានសិទ្ធិស្នើសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញ** .................. ៤២
**ផ្នែកទី៣ ការសិក្សាប្រៀបធៀបប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពកម្ពុជា និង ជប៉ុន** ....... ៤៣
**កថាខណ្ឌទី១ លក្ខណៈស្របគ្នានៃប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទាំងពីរ** ............. ៤៣
១.អត្ថិភាពនៃការស្នើសុំ និង អ្នកអាចស្នើសុំប្តឹងការត្រួតពិនិត្យធម្មនុញ្ញភាព .......... ៤៣
២.គោលការណ៍នៃការត្រួតពិនិត្យធម្មនុញ្ញភាព .......................................................... ៤៥
**កថាខណ្ឌទី២ លក្ខណៈខុសគ្នានៃប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទាំងពីរ** .............. ៤៥
១.ស្ថាប័នត្រួតពិនិត្យធម្មនុញ្ញ ........................................................................ ៤៥
២.អ្នកស្នើសុំ .......................................................................................... ៤៦
៣.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាព .................................................... ៤៦
៣.១.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា ................................ ៤៦
៣.១.១ដំណើរការនៃសំណុំរឿងនៅនាយកដ្ឋានជំនាញ ............................................. ៤៦
៣.១.២.ការចាត់តាំងសមាជិករាយការណ៍ ........................................................ ៤៧
៣.១.៣.ភារកិច្ចរបស់សមាជិករាយការណ៍ ....................................................... ៤៧
៣.១.៤.សេចក្តីសម្រេច ........................................................................ ៤៨
៣.១.៥.កិច្ចប្រជុំបឋម ........................................................................ ៤៨
៣.១.៦.កិច្ចប្រជុំពេញអង្គ .................................................................... ៤៨
៣.១.៧.ការចេញសេចក្តីសម្រេច ............................................................ ៥០
៣.២.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ................................ ៥០
៣.២.១.ការត្រួតពិនិត្យធម្មនុញ្ញភាពនៅស្ថាប័ននីតិប្រតិបត្តិ ...................................... ៥០
៣.២.២.ការត្រួតពិនិត្យធម្មនុញ្ញភាពនៅស្ថាប័នតុលាការ ........................................ ៥១
**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃប្រព័ន្ធកម្ពុជា និង ជប៉ុន** ........................................................................ ៥២
**ផ្នែកទី១ បញ្ហាប្រឈមនៃការត្រួតពិនិត្យធម្មនុញ្ញភាព** .............................................. ៥២

**កថាខណ្ឌទី១ បញ្ហាកើតឡើងនៅប្រទេសកម្ពុជា** ........ ៥២

១.សមាជិកភាពនៃស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព(ឯករាជ្យភាព) ........ ៥២

២.បញ្ហានៃការត្រួតពិនិត្យជាអាទិកាល ........ ៥៤

៣.មូលដ្ឋានគ្រឹះនៃគោលការណ៍ត្រួតពិនិត្យធម្មនុញ្ញភាព ........ ៥៤

**កថាខណ្ឌទី២ បញ្ហាកើតឡើងនៅប្រទេសជប៉ុន** ........ ៥៥

១.បញ្ហានៃការត្រួតពិនិត្យជាអាទិ៍កាលនៅស្ថាប័ននីតិប្រតិបត្តិតឹងរឹងជ្រុល ........ ៥៥

២.បញ្ហាទ្រឹស្តីនៃការត្រួតពិនិត្យធម្មនុញ្ញភាព ........ ៥៧

**ផ្នែកទី២ ដំណោះស្រាយលើបញ្ហាត្រួតពិនិត្យធម្មនុញ្ញភាពនៃប្រព័ន្ធទាំងពីរ** .. ៦២

**កថាខណ្ឌទី១ ចំពោះប្រទេសកម្ពុជា** ........ ៦២

**កថាខណ្ឌទី២ ចំពោះប្រទេសជប៉ុន** ........ ៦៣

**សេចក្តីសន្និដ្ឋាន** ........ ៦៥

**អនុសាសន៍** ........ ៧១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការរស់នៅក្នុងសង្គមមួយដើម្បីចៀសចាកបាននូវការទន្ទ្រានផលប្រយោជន៍ និង ការបំពារបំពានទៅលើសិទ្ធិបុគ្គល ក៏ដូចជាក្នុងបំណងសុខុមាលភាព សណ្តាប់ធ្នាប់សាធារណៈសម្រាប់សង្គមជាតិនោះ គឺគេបានបង្កើតនូវច្បាប់សម្រាប់គ្រប់គ្រងសង្គម និងថៃទាំសេចក្តីសុខសម្រាប់ប្រជាពលរដ្ឋទូទៅ។ច្បាប់ដែលត្រូវបង្កើត នៅលើបណ្តាសកលលោកយើងនេះមានលក្ខណៈខុសគ្នា ទៅតាមរបបនយោបាយនៃប្រទេសនីមួយៗ។ប្រទេសខ្លះច្បាប់ត្រូវបង្កើតដោយ សភា ដែលមានពីរថ្នាក់ គឺ រដ្ឋសភា និង ព្រឹទ្ធសភា ឬក៏អាចត្រូវបានស្នើចេញអំពីនាយករដ្ឋមន្ត្រី នៃអំណាច នីតិប្រតិបត្តិដែលមានសិទ្ធិក្នុងការធ្វើសេចក្តីព្រាងច្បាប់ ដាក់ជូនរដ្ឋសភា និង ព្រឹទ្ធសភា ពិនិត្យ និង អនុម័ត។ក្នុងករណីនេះសង្កេតឃើញថា ប្រទេសនីមួយៗនៅក្នុងការធ្វើច្បាប់គឺមាននីតិវិធីខុសៗគ្នា។ទន្ទឹមនឹងនេះផងដែរ លោក **ហ៊ាន កេលសិន** ដែលជាអ្នកនីតិវិទូបានបកស្រាយថា នៅក្នុងការធ្វើច្បាប់ចាំបាច់ត្រូវតែគោរពឋានានុក្រមនៃច្បាប់ រួមមាន **រដ្ឋធម្មនុញ្ញ** គឺជាច្បាប់កំពូលដែលមានឋានានុក្រមខ្ពស់ជាងគេ។ ដោយជាបន្ទាប់ទៀត គឺ លិខិតបទដ្ឋានអន្តរជាតិ រួមមាន សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញានានា ។លំដាប់ទីបីបន្ទាប់មកទៀតគឺ ច្បាប់ ដែលរួម មាន ព្រះរាជក្រម ព្រះរាជក្រឹត្យជាដើម។ ឯលំដាប់ទីបួន គឺលិខិតបទដ្ឋានខាងនីតិប្រតិបត្តិ ដែល ក្នុងនោះមាន អនុក្រឹត្យ ប្រកាស ដីកា សារាចរ ជាដើម។នេះសបញ្ជាក់ថា រដ្ឋធម្មនុញ្ញគឺជាច្បាប់លំដាប់កំពូលនៃរដ្ឋនីមួយៗ ដែលតម្រូវឱ្យមានគ្រប់លិខិតបទដ្ឋានដែលមាន ឋានានុក្រមនៃច្បាប់នោះ គឺមិនអាចធ្វើផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញបាននោះឡើយ។ដោយសារតែការណ៍នេះហើយ ទើបប្រទេសឬ រដ្ឋខ្លះ ក្នុងការបង្កើតច្បាប់ ឬ អនុវត្តច្បាប់ចាំបាច់ឱ្យមានស្ថាប័នមួយសម្រាប់ត្រួតពិនិត្យធម្មនុញ្ញភាព ដើម្បីកុំឱ្យច្បាប់ទាំងឡាយដែលបានធ្វើឡើងគឺបដិប្បញ្ញត្តិទៅនឹងរដ្ឋធម្មនុញ្ញរបស់រដ្ឋ។ការត្រួតពិនិត្យធម្មនុញ្ញភាពនេះរដ្ឋ ឬ ប្រទេសខ្លះ បានបង្កើតឱ្យមានឈ្មោះឡើង ខុសៗគ្នា ខ្លះហៅថា តុលាការធម្មនុញ្ញ ខ្លះទៀតហៅថា ក្រុមប្រឹក្សាធម្មនុញ្ញ ឬ គណៈកម្មការពិនិត្យធម្មនុញ្ញជាដើម។

ដោយឡែកព្រះរាជាណាចក្រកម្ពុជាយើងជារដ្ឋមួយមានច្បាប់ តាំងពីយូរលង់ណាស់មកហើយជនជាតិខ្មែរមានវប្បធម៌ អរិយធម៌ដ៏ល្អប្រពៃទៀតផង។ក្រោយពីការបោះឆ្នោត ដែលរៀបចំដោយអង្គការសហប្រជាជាតិ ហៅកាត់ថា **អ៊ុនតាក់**(UNTAC) ។សភាធម្មនុញ្ញមានសមាជិកចំនួន ១២០រូបដែលចេញមកពីគណបក្សនយោបាយទាំងបួន បានអនុម័តនូវបទបញ្ជាផ្ទៃក្នុងរបស់សភាធម្មនុញ្ញ និងបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ។ក្រោយពីការពិនិត្យ ពិភាក្សារបស់សភាធម្មនុញ្ញពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ **រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា** ត្រូវបានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើជាផ្លូវការថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នេះបានធ្វើវិសោធនកម្មជាច្រើនដងហើយ បានប្បញ្ញត្តិឱ្យមានជំពូកទី១២ថ្មី ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នដែលមាន សមត្ថកិច្ចធានាការពារ ការ

គោរពធម្មនុញ្ញ បកស្រាយធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់[1]។ដូចនេះស្ថាប័ននៅក្នុងការត្រួតពិនិត្យធម្មនុញ្ញ នៅកម្ពុជាគឺ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ១៩៩៨ គឺច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ។

ទន្ទឹមនឹងនេះផងដែរប្រទេសជប៉ុនដែលជាប្រទេសស្ថិតក្នុងតំបន់អាស៊ី នៃប៉ែកខាងកើតក៏មានការត្រួតពិនិត្យធម្មនុញ្ញភាពដែរ។ប្រវត្តិសាស្ត្រជប៉ុនក្រោយពីបានចាញ់សង្គ្រាមលោកលើកទី២ បានបង្កើតឱ្យមានរដ្ឋធម្មនុញ្ញថ្មី ដោយប្រកាន់របបប្រជាធិបតេយ្យ ដោយមានសហរដ្ឋអាមេរិកជាអ្នកត្រួតពិនិត្យ ដែលហៅកាត់ថា GHQ។រដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution）នេះបានការពារយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ជាមូលដ្ឋានទាំងបីធំៗ មានដូចជា ការគោរពនូវសិទ្ធិមនុស្សជាមូលដ្ឋាន លទ្ធិប្រជាធិបតេយ្យ និង លទ្ធិសន្តិភាព ។ ទន្ទឹមនឹងនេះ រដ្ឋធម្មនុញ្ញនេះបានបែងចែកអំណាចទាំងបី ឱ្យប្រសើរឡើងជាងរដ្ឋធម្មនុញ្ញចាស់(រដ្ឋធម្មនុញ្ញសម័យម៉េជិ) ដោយអំណាចទាំងបីនេះ ត្រួតពិនិត្យតុល្យភាពអំណាចគ្នាទៅវិញទៅមក [2] ។ នៅក្នុងរដ្ឋធម្មនុញ្ញប្រទេសជប៉ុនថ្មីនេះ គឺមានចែងអំពីការត្រួតពិនិត្យធម្មនុញ្ញភាពដោយតុលាការកំពូលមានសមត្ថកិច្ចចុងក្រោយ គឺទទួលបណ្តឹងនិងសម្រេចលើអធម្មនុញ្ញ ឬ ស្របនឹងធម្មនុញ្ញ[3]។ ឆ្លងតាមការអនុវត្តសព្វថ្ងៃប្រទេសជប៉ុនគឺមានរឿងក្តីទាក់ទងនឹងអធម្មនុញ្ញនេះច្រើនណាស់ តែពុំមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព មុននឹងច្បាប់ប្រកាសឱ្យប្រើនោះទេ គឺខាងនីតិប្រតិបត្តិ និង នីតិបញ្ញត្តិជាអ្នកត្រួតពិនិត្យលើធម្មនុញ្ញភាព។

## ១.បុព្វហេតុនៃការសិក្សា

មាត្រា ១៥០ថ្មី (១៣១ចាស់)នៃរដ្ឋធម្មនុញ្ញបានចែងថា រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។បើរដ្ឋធម្មនុញ្ញនេះជា ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់និង សេចក្តីសម្រេចទាំងឡាយ នៃស្ថាប័ននានា របស់រដ្ឋត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញ តើអ្នកណា ឬ ស្ថាប័នណាដែលជាអ្នកត្រួតពិនិត្យធម្មនុញ្ញភាព?តើការពិនិត្យធម្មនុញ្ញភាពនោះប្រព្រឹត្តទៅយ៉ាងដូចម្តេច? ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នដែលមានសិទ្ធិនៅក្នុងការត្រួត

[1] មាត្រា១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

[2] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）、（公民 3・5）36 頁、66 頁

មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកុម្ភៈ ឆ្នាំ ២០១១) (សីលធម៌ពលរដ្ឋ ៣,៥ )ទំព័រ ៣៦ ,ទំព័រ៦៦

[3] មាត្រា៨១ នៃរដ្ឋធម្មនុញ្ញប្រទេសជប៉ុន

ពិនិត្យធម្មនុញ្ញភាពតែមួយគត់ ហើយសមត្ថកិច្ចផ្តាច់មុខនេះគឺជាគោលការណ៍បង្កើតច្បាប់ដែលអាចឈានទៅរកនីតិរដ្ឋដ៏ផូរផង់។ តើស្ថាប័ននេះឯករាជ្យឬក៏យ៉ាងណា ប្រសិនបើការពិនិត្យធម្មនុញ្ញភាពនៅកម្ពុជាពុំសូវមានការប្រកាសអធម្មនុញ្ញភាព ច្បាប់ដែលបានពិនិត្យនោះទេ តួយ៉ាងច្បាប់ស្តីការរៀបចំ អង្គការតុលាការ គឺសង្គមស៊ីវិល ក៏ដូចជាអ្នកវិភាគសិក្សាឃើញថា មានមាត្រាខ្លះអាចអធម្មនុញ្ញភាពតែបែរជាមិនអើពើ ?ការពិនិត្យធម្មនុញ្ញភាពនោះពឹងលើមធ្យោបាយអ្វី?

រីឯប្រទេសជប៉ុនដែលប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលឡ ដូចកម្ពុជាដែរ ឃើញថាមានការរៀបចំប្រព័ន្ធស្របតាមលទ្ធិប្រជាធិបតេយ្យ ហើយក៏នៅតែប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដូចកម្ពុជាផងដែរ។ សព្វថ្ងៃប្រទេសជប៉ុនកំពុងតែមានសេដ្ឋកិច្ច និង ប្រព័ន្ធច្បាប់ក៏រីកចម្រើនទៅតាមតថភាពនោះដែរ ដែលជាហេតុធ្វើឱ្យមានការបង្កើតជាច្បាប់យ៉ាងច្រើននៅក្នុងការគ្រប់គ្រង។រឿងក្តីនៅប្រទេសជប៉ុន ភាគច្រើនជារឿងក្តីកម្រ ដូចជាទាក់ទងទៅនឹងអធម្មនុញ្ញភាព ដែលកម្ពុជាយើងតុលាការពុំធ្លាប់មានបណ្តឹងទាំងនោះទេ។ តើជប៉ុនពិនិត្យទៅលើអ្វីខ្លះ ទើបអាចដឹងអំពីអធម្មនុញ្ញភាពនៃរឿងក្តីច្រើនម្ល៉េះ? ប្រព័ន្ធត្រួតពិនិត្យច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រីនៃប្រទេសជប៉ុន គឺជាស្ថាប័នមួយដ៏តឹងរ៉ឹង ចុះមូលហេតុអ្វីនៅតែមាន ការត្រួតពិនិត្យធម្មនុញ្ញភាពមិនច្បាស់លាស់ទៀត?

## ២.ចំណោទបញ្ហា

ថ្វីត្បិតតែស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នដែលបង្កើតតាំងពីឆ្នាំ ១៩៩៨ តែមកទល់ពេលនេះប្រជាពលរដ្ឋខ្មែរជាច្រើន ពុំទាន់បានសូវយល់ច្បាស់អំពីសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពរបស់ស្ថាប័ននេះនៅឡើយទេ។ ក្រឡេកមកមើលប្រទេសជប៉ុនក៏ជាសម្ព័ន្ធមិត្តនៃប្រទេសកម្ពុជាយើងដែរ ហើយមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព ដូចកម្ពុជាយើងដែរ ដែលសុទ្ធតែមានបំណងកសាងប្រទេស ឆ្ពោះទៅកាន់នីតិរដ្ឋ។

ក្នុងការសរសេរសារណានេះ យើងខ្ញុំយកប្រធានបទអំពី **ការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន(ករណីសិក្សាប្រៀបធៀបប្រទេសជប៉ុន)**មកសរសេរ គឺដើម្បីចង់ឱ្យប្រជាជនទូទៅ និង និស្សិត ព្រមទាំងអ្នកសិក្សាជំនាន់ក្រោយៗ បានយល់ដឹងអំពី ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញថាជាស្ថាប័នអ្វី?ដំណើរការយ៉ាងដូចម្តេច?ត្រួតពិនិត្យធម្មនុញ្ញភាពដូចម្តេចខ្លះ?

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជាស្ថាប័នឯករាជ្យនៅក្នុងការពិនិត្យច្បាប់ទាំងឡាយ កុំឱ្យបំពារបំពានលើរដ្ឋធម្មនុញ្ញ។ តែចំណែកការប្រតិបត្តិនាពេលសព្វថ្ងៃសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញហាក់ដូចជាពុំទាន់មានច្បាស់លាស់ទៅលើជំនាញ ក៏ដូចជាបញ្ហាមកពីគណបក្សព្រោះមានតំណាងរាស្ត្រ និង សមាសភាពចៅក្រម ដែលស្ថិតនៅក្នុងអង្គការតុលាការតែបែរជាអាចធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទៅវិញ។ ជាមួយគ្នានេះការត្រួតពិនិត្យធម្មនុញ្ញភាព គឺមានត្រឹមតែរដ្ឋធម្មនុញ្ញជាគោលការណ៍តែប៉ុណ្ណោះពុំទាន់មានការពិចារណាណាមួយផ្សេងមកប្រៀបធៀបអំពីសិទ្ធិ និង ប្រយោជន៍

បុគ្គលនោះទេ គឺត្រឹមក្របខណ្ឌរដ្ឋធម្មនុញ្ញប៉ុណ្ណោះ។បច្ចុប្បន្នក្រុមប្រឹក្សាធម្មនុញ្ញពុំទាន់មានសមត្ថកិច្ចក្នុងការលើកយកច្បាប់ណាមួយមកពិនិត្យ ដោយឯកឯងបាននោះទេ។ទាំងនេះគឺជាបញ្ហាដែលកម្ពុជា គួរតែធ្វើការកែតម្រូវ និងដោះស្រាយដើម្បីឱ្យស្ថាប័ននេះឯករាជ្យ។

តែបើពិនិត្យទៅលើប្រទេសជប៉ុន គឺមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពដែរ នៅពេលដែលអធិរាជបានប្រកាសឱ្យប្រើច្បាប់បង្កើតថ្មីនោះហើយ ចុះហេតុម្តេចបានជានៅតែមាន រឿងអធម្មនុញ្ញភាពបន្តប្តឹងនៅតុលាការយ៉ាងគំហុកបន្តទៅទៀត។ តុលាការគឺជាស្ថាប័នឯករាជ្យសម្រាប់ជំនុំជម្រះរឿងក្តីផ្សេងៗ ចុះហេតុម្តេច បានជារឿងអធម្មនុញ្ញភាពត្រូវតុលាការគ្រប់ជាន់ថ្នាក់ជប៉ុន អាចចេញសេចក្តីសម្រេចបានហើយសេចក្តីសម្រេចនោះហាក់ដូចជាមានអានុភាពខ្លាំងក្លា ដែលគេហៅថាត្រូវធ្វើវិសោធនកម្មច្បាប់។សភាទាំងពីរ កើតឡើងដោយ អំណាចឆន្ទៈរបស់ប្រជារាស្ត្រ ព្រមទាំងអង្គនីតិប្រតិបត្តិផង ចុះម្តេចបានជាប្រទេសជប៉ុន អាចឱ្យតុលាការហ៊ានសម្រេចពិនិត្យលើច្បាប់របស់ស្ថាប័នទាំងនោះបង្កើត ហើយពុំឱ្យអនុវត្តទៀត?ដែលគេអាចវិភាគបានថា ជាការរំលោភអំណាច ឬយ៉ាងណា?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និង រៀបចំចងក្រងសារណានេះឡើង ក្នុងគោលបំណងស្រាវជ្រាវដូចដែលបានអធិប្បាយក្នុងចំណុច ២ ស្តីពីចំណោទបញ្ហាខាងលើ គឺដើម្បីពង្រីកនូវពុទ្ធិនៃចំណេះដឹងផ្ទាល់ខ្លួនព្រមទាំងរក្សា និង ផ្តល់ការយល់ឃើញដែលបានពីការសិក្សាទុកជាចំណេះដឹងបន្តដល់អ្នកសិក្សាជំនាន់ក្រោយៗ បានយល់ដឹងអំពីការរៀបចំប្រព្រឹត្តទៅ ក៏ដូចជាការវិភាគ ប្រៀបធៀបរកចំណុចស្រប និង ចំនុចផ្ទុយគ្នា នៃប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា និង ប្រទេសជប៉ុន។ម្យ៉ាងទៀត យើងនឹងឃើញអំពីបញ្ហាដែលប្រព័ន្ធទាំងពីរប្រឈមមុខនឹងបញ្ហា ដោយភ្ជាប់មកជាមួយដំណោះស្រាយសម្រាប់កែលម្អផងដែរ។

## ៤.ដែនកំណត់ និង វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណុច ២ ស្តីពីចំណោទបញ្ហាខាងលើ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវលើ ឯកសារភាសាជាតិ និង ឯកសារភាសាបរទេស ដើម្បីសរសេរសារណានេះ ដែលមាន ៣ជំពូក។

ការសរសេរសារណានេះផ្តោតទៅលើការត្រួតពិនិត្យធម្មនុញ្ញភាព នាពេលបច្ចុប្បន្នដោយសិក្សាប្រៀបធៀបទៅនឹងប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅក្នុងប្រទេសជប៉ុន។ ប៉ុន្តែយើងក៏លើកនិយាយពីប្រវត្តិសង្ខេប នៃការបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញនេះឡើងនៃបណ្តាប្រទេសមួយចំនួន ដើម្បីជាទឡ្ហីករណ៍សម្រាប់ធ្វើការពិចារណាផងដែរ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះនឹងនាំឱ្យប្រជាពលរដ្ឋ និង អ្នកសិក្សាជំនាន់ក្រោយបានយល់ដឹងពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅព្រះរាជាណាចក្រកម្ពុជាយើង និង ប្រទេសជប៉ុនដោយឱ្យដឹងច្បាស់អំពីថាតើក្រុមប្រឹក្សាធម្មនុញ្ញ កើតឡើងយ៉ាងដូចម្តេច? មូលហេតុអ្វីបានជាចាំបាច់ត្រូវមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព? ស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពប្រទេសទាំងពីរនោះពិនិត្យធម្មនុញ្ញភាពយ៉ាងដូចម្តេច? ហើយសេចក្តីសម្រេចរបស់ស្ថាប័ននោះមានអានុភាពយ៉ាងដូចម្តេច?ទាំងប្រទេសកម្ពុជា និង ប្រទេសជប៉ុនក្នុងការដំណើរការត្រួតពិនិត្យធម្មនុញ្ញភាពនេះ ប្រព្រឹត្តទៅដោយឯករាជ្យ ឬ ជួបបញ្ហាដែរឬទេ? តើដំណោះស្រាយយ៉ាងណាខ្លះដើម្បីជួយកែលម្អស្ថាប័ន និងប្រព័ន្ធត្រួតពិនិត្យទាំងពីរនេះបាន ដោយពុំមានការបំពានអំណាច?

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖

**ជំពូកទី១ ៖** -កំណើតនៃការត្រួតពិនិត្យធម្មនុញ្ញភាព៖

យើងសិក្សាស្រាវជ្រាវអំពីប្រវត្តិនៃការបង្កើតឱ្យមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញនៅលើសកលលោក ការបង្កើតនៅព្រះរាជាណាចក្រកម្ពុជាតាមសម័យកាល និង ការបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន។

-អំពីការរៀបចំសមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញនៅកម្ពុជា និង ការរៀបចំបង្កើតនៅប្រទេសជប៉ុនថាតើការរៀបចំនិងប្រព្រឹត្តទៅនៃស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពមានលក្ខណៈយ៉ាងដូចម្តេច?

យើងនឹងយល់អំពីបុព្វហេតុដែលនាំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាព។

**ជំពូកទី២៖** -អំពីសមត្ថកិច្ចនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជា និង ប្រទេសជប៉ុន ក្នុងជំពូកនេះយើងនឹងសិក្សាអំពីការត្រួតពិនិត្យធម្មនុញ្ញភាពរួមមាន៖

- គោលការណ៍នៃការត្រួតពិនិត្យធម្មនុញ្ញភាព
- ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល និង បច្ឆាកាល
- អ្នកដែលមានសិទ្ធិក្នុងការស្នើសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាព

-អំពីការសិក្សាប្រៀបធៀបប្រព័ន្ធពិនិត្យធម្មនុញ្ញភាពរវាងកម្ពុជា និង ជប៉ុន ស្វែងរកលក្ខណៈដូចគ្នា និង ខុសគ្នានៃប្រព័ន្ធទាំងពីរ

**ជំពូកទី៣៖** -អំពីការសិក្សាទៅលើបញ្ហាដែលកើតឡើងបច្ចុប្បន្ន នៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនិងការសិក្សាស្វែងរកដំណោះស្រាយ ទៅលើចំណោទបញ្ហានៃដំណើរការស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពទាំងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន។ ក្នុងជំពូកទី៣ នេះយើងនឹងបានសិក្សាច្បាស់អំពីចំណុចអវិជ្ជមាន និងវិជ្ជមានដោយភ្ជាប់មកជាមួយការវិភាគរកវិធានការដោះស្រាយផ្សេងៗ។

ក្នុងសារណានេះនឹងមានសេចក្ដីសន្និដ្ឋាន និង ការផ្ដល់អនុសាសន៍ចំពោះការសិក្សាស្រាវជ្រាវ។

# ជំពូកទី១

## កំណើតនៃការត្រួតពិនិត្យធម្មនុញ្ញភាព

# ជំពូកទី១
# កំណើតនៃការត្រួតពិនិត្យធម្មនុញ្ញភាព

## ផ្នែកទី១ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅអឺរ៉ុប

ប្រវត្តិដើមនៃគំនិតផ្តើមឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនេះកើតនៅដើមសតវត្សរ៍ទី១៧ នៅចក្រភពអង់គ្លេស ដែលកាលនោះ គឺបានផ្សារភ្ជាប់ជាមួយនឹងសកម្មភាពនៃ«ក្រុមប្រឹក្សាសម្ងាត់»មួយ ដោយក្នុងនោះក្រុមប្រឹក្សានេះបានទទួលស្គាល់ច្បាប់នានានៃ ឡេជីស្លេជ្ស៍រ(Leguslature) របស់ប្រទេសអាណានិគមខ្លះយល់ថាគ្មានសកម្មភាពទេ ប្រសិនបើច្បាប់ទាំងនោះផ្ទុយនឹងច្បាប់មួយរបស់រដ្ឋសភានៃចក្រភពអង់គ្លេស ឬ ផ្ទុយនឹងច្បាប់កុម្មិនឡ ( Common Law)[4]។ នៅចំណុចនេះចង់បញ្ជាក់ថា បើប្រទេសនៅក្រោមអាណានិគមរបស់ចក្រភពអង់គ្លេសធ្វើច្បាប់ មិនស្របច្បាប់របស់ប្រទេសអង់គ្លេស គឺមានន័យថា អធម្មនុញ្ញភាព គឺមិនអាចយកទៅប្រើបាន។ការត្រួតពិនិត្យធម្មនុញ្ញភាពកើតមានជាហូរហែរ ដូចជា នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ១៨០៣ (លោកប្រធានាធិបតីជ្យម៉ារសាល់ បានប្រកាសនៅក្នុងតុលាការកំពូលថា រដ្ឋធម្មនុញ្ញសហព័ន្ធ គឺជាច្បាប់កំពូលរបស់ប្រទេស ហើយច្បាប់នានារបស់រដ្ឋសភា (Congress)ដែលផ្ទុយនឹង រដ្ឋធម្មនុញ្ញអាចទទួលស្គាល់ដោយតុលាការ ប្រទេសមួយចំនួននៅអាមេរិកឡាទីន ដូចជាប្រទេសប្រេស៊ីលឆ្នាំ ១៨១៩ ប្រទេសអ៊ុរ៉ូហ្គាយ ឆ្នាំ១៩៧១...[5]។ការណ៍មួយដោយឡែកទៀត នៅមុនសង្គ្រាមលោកលើកទី១ នៅអឺរ៉ុបក៏កើតមានការត្រួតពិនិត្យធម្មនុញ្ញភាពដែរ ដូចជា ប្រទេសន័រវេស ប្រទេសក្រិច ប្រទេស ស្វីស......។ បន្ទាប់ពីសង្គ្រាមលោកលើកទី១ បានផុតរលត់ទៅហើយនៅអឺរ៉ុប ក៏កើតមានការកែច្នៃឱ្យកាន់តែប្រសើរឡើងនូវគម្រូកម្មសិទ្ធមួយ ស្តីអំពីការត្រួតពិនិត្យធម្មនុញ្ញភាព ដែលបង្កើតឡើងដោយអ្នកប្រាជ្ញខាងច្បាប់ពិភពលោកម្នាក់ជនជាតិអូទ្រីសឈ្មោះ **ហេន កែលសិន** (អ្នកប្រាជ្ញ Hans Kelsen បានចូលរួមបង្កើតច្បាប់ធម្មនុញ្ញរបស់ប្រទេសអូទ្រីសនៅឆ្នាំ១៩២០ ក្រោយមកលោកជាសមាជិកតុលាការធម្មនុញ្ញនៃប្រទេសអូទ្រីស) បន្ទាប់មកត្រូវបានបណ្តាប្រទេសនានា នៅក្នុងសកលលោកទទួលយកគម្រូអំពីការត្រួតពិនិត្យធម្មនុញ្ញអឺរ៉ុបនេះទៅអនុវត្តដូចជា៖

[4]Constitutional Law of Foreign Country .Part II.M.1994 Page 322
[5] Constitutional Law of Foreign Country .Part II.M.1994 Page 322

- រដ្ឋធម្មនុញ្ញប្រទេសបារាំងឆ្នាំ១៩៨៥ បានប្រគល់អំណាចត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ទៅឱ្យស្ថាប័នមួយមានឈ្មោះថា ក្រុមប្រឹក្សាធម្មនុញ្ញ។
- ប្រទេសម៉ារ៉ុកឱ្យឈ្មោះស្ថាប័ននេះថា ក្រុមប្រឹក្សាធម្មនុញ្ញ។
- ប្រទេសអូទ្រីសឱ្យឈ្មោះស្ថាប័ននេះថា តុលាការធម្មនុញ្ញ។
- ប្រទេសអាល្លឺម៉ង់ស្ថាប័ននេះហៅថា តុលាការធម្មនុញ្ញ។
- ប្រទេសអ៊ីតាលីហៅថា តុលាការធម្មនុញ្ញ។
- ប្រទេសអេស្ប៉ាញហៅថា តុលាការធម្មនុញ្ញ។
- ប្រទេសហ្គីណេហៅថា តុលាការធម្មនុញ្ញ។
- ប្រទេសប៉ូឡូញហៅថា សាលាក្តីធម្មនុញ្ញ។
- រដ្ឋធម្មនុញ្ញប្រទេសប្រេស៊ីលឆ្នាំ១៩៨៨ ស្ថាប័ននេះហៅថា សាលាក្តីកំពូលសហព័ន្ធ។
- រដ្ឋធម្មនុញ្ញប្រទេសកូឡុំប៊ី ឆ្នាំ១៩៩១ ហៅថា តុលាការធម្មនុញ្ញ
- និង ប្រទេសកូស្តារីកាបានហៅថា សភាធម្មនុញ្ញនៃតុលាការកំពូល។ល។

នៅសាធារណរដ្ឋសហព័ន្ធអាលឺម៉ង់ សមាជិកទាំងអស់នៃតុលាការធម្មនុញ្ញសហព័ន្ធ ត្រូវបានបោះឆ្នោតដោយសភាសហព័ន្ធ(ប៊ុនដេសថាក) និង ក្រុមប្រឹក្សាសហព័ន្ធ (ប៊ុនដេសរាត)។ អង្គការនីតិបញ្ញត្តិនៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់បែងចែកជាសភាពីរ គឺ ប៊ុនដេសថាក និង ប៊ុនដេស-រាត។ប៊ុនដេសថាក ដែលបកប្រែជាភាសាខ្មែរថា សភាសហព័ន្ធ គឺជាសភាតំនាងប្រជាពលរដ្ឋសហព័ន្ធទាំងមូលដែលត្រូវបានពលរដ្ឋសហព័ន្ធជ្រើសតាំងឡើងសម្រាប់អាណត្តិ៤ឆ្នាំ។ សភាសហព័ន្ធនេះបង្កើតរដ្ឋាភិបាលសហព័ន្ធតាមរបបប្រជាធិបតេយ្យសភានិយម។ ប៊ុនដេសរាត ដែលបកប្រែជាភាសាខ្មែរថា ក្រុមប្រឹក្សាសហព័ន្ធ គឺសភាតំណាងរដ្ឋសហព័ន្ធ។ក្រុមប្រឹក្សាសហព័ន្ធមានសមាសភាពមកពីសមាជិកតំណាងរដ្ឋាភិបាលនៃរដ្ឋសហព័ន្ធនីមួយៗ។ តាមរដ្ឋធម្មនុញ្ញមាត្រា៩៤ ចំណុចទី១នៃច្បាប់គោលនេះបានចែងថា ៖ តុលាការធម្មនុញ្ញសហព័ន្ធបានរៀបចំបង្កើតឡើងពីសមាសភាពចៅក្រមសហព័ន្ធ និង ចៅក្រមនៃរដ្ឋសមាជិកដទៃទៀត។ ចំនួនពាក់កណ្តាលនៃសមាជិកតុលាការធម្មនុញ្ញ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសភាសហព័ន្ធ (ប៊ុនដេសថាក) និង ពាក់កណ្តាលទៀត បោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សាសហព័ន្ធ(ប៊ុនដេសរាត)។ សមាជិកទាំងអស់របស់តុលាការធម្មនុញ្ញពុំមែនជាសមាជិករបស់សភាតំណាងរាស្ត្រ សភាតំណាងរដ្ឋ រដ្ឋាភិបាលសហព័ន្ធ ឬ ក៏អង្គការនានារបស់សមាជិកសហព័ន្ធទេ។

## ផ្នែកទី២ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជា

### កថាខណ្ឌទី១ ប្រវត្តិនៃការកកើត

ជាដំបូងមុននឹងធ្វើការសិក្សា និងបកស្រាយពីប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាព យើងនឹងធ្វើការសិក្សាពីប្រវត្តិនៃការកកើតជាមុនសិន ។ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ចាប់តាំងពីរដ្ឋធម្មនុញ្ញដំបូងដែលមានឈ្មោះថា រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា(១៩៤៧-១៩៧០) រហូតមកដល់រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា(១៩៨៩-១៩៩៣) បានចែងតែអំពីសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញតែប៉ុណ្ណោះ ហើយមិនមាននិយាយអំពីការត្រួតពិនិត្យធម្មនុញ្ញភាពនោះឡើយ ។ ដូចនេះ យើងអាចសន្និដ្ឋានថា ចាប់ពីរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា(១៩៤៧-១៩៧០) រហូតមកដល់រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា(១៩៨៩-១៩៩៣) គឺមិនមានកំណត់ពីស្ថាប័នមានសមត្ថកិច្ច ក៏ដូចជាប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពឡើយ ។ ផ្ទុយទៅវិញ តាមរយៈរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន) គឺបានបង្កើតឱ្យមានស្ថាប័ន " **ក្រុមប្រឹក្សាធម្មនុញ្ញ** " ដែលមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងរដ្ឋធម្មនុញ្ញនីមួយៗ បានចែងអំពីសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញផងដែរ[6] ។ ដូច្នេះ ដើម្បីស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព ថាតើរដ្ឋធម្មនុញ្ញនៃសម័យកាលនីមួយៗបានចែងយ៉ាងដូចម្តេចនោះ យើងនឹងធ្វើការសិក្សាស្វែងយល់តាមរយៈរដ្ឋធម្មនុញ្ញនៃសម័យកាលនីមួយៗ ដូចខាងក្រោម ។

#### ១.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧

រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងក្នុងសម័យអាណានិគមបារាំង ។ ដោយសារនៅសម័យនោះ ប្រទេសកម្ពុជា ស្ថិតនៅក្រោម អាណានិគមបារាំង រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ១៩៤៧ គឺជារដ្ឋធម្មនុញ្ញដែលបានចម្លងតាមរដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៩៤៦ ធ្វើឡើងដោយពួកបញ្ញវន្តដែលជាអ្នកប្រជាធិបតេយ្យ ពុំមែនដោយសារការតស៊ូរបស់ប្រជារាស្ត្រទេ ។ រដ្ឋធម្មនុញ្ញនេះបានផ្តល់សិទ្ធិអំណាចយ៉ាងខ្លាំងដល់ព្រះមហាក្សត្រ ដែលអំណាចគ្រប់យ៉ាងចេញមកពីព្រះមហាក្សត្រ ។ ហើយចំពោះការបែងចែកអំណាចទាំងបី គឺក្នុងព្រះបរមនាម រដ្ឋសភាប្រើអំណាចនីតិបញ្ញត្តិ គណៈរដ្ឋមន្ត្រីប្រើអំណាចនីតិប្រតិបត្តិ ហើយសាលាជម្រះក្តីគ្រប់ជាន់ប្រើអំណាចតុលាការ[7] ។

[6] http://www.ccc.gov.kh/ccchistory_kh.php

[7] នីតិរដ្ឋធម្មនុញ្ញ សុខ យ៉ាន សុខ ចិន្តា ទំព័រ ១២៦ និង ទំព័រ ១៣១

ប្រសិនបើយើងក្រឡេកទៅមើល អំពីប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ វិញ យើងសង្កេតឃើញថា មិនមាននិយាយអំពីការត្រួតពិនិត្យធម្មនុញ្ញភាពឡើយ ។ នៅក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៤៧ ដែលបានកែប្រែបន្តបន្ទាប់ រហូតដល់ ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ១៩៦៤ ក៏បាននិយាយនៅក្នុងមាត្រា ១១៩[8] តែពីសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញ ហើយមិនមាននិយាយពីការត្រួតពិនិត្យធម្មនុញ្ញភាពទេ ។ សិទ្ធិបកស្រាយចុងក្រោយជារបស់ រដ្ឋសភា[9] ។

ក៏ប៉ុន្តែ មិនមាននិយាយពីការត្រួតពិនិត្យធម្មនុញ្ញភាព ជាទូទៅ ទាំងអ្នកច្បាប់ និងទាំងព្រះមហាក្សត្រ ទទួលស្គាល់ថារដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានយកលំនាំតាមរដ្ឋធម្មនុញ្ញសាធារណរដ្ឋទី ៤ របស់បារាំង សម្តេចព្រះឧបយុវរាជ ទ្រង់បានព្រះរាជនិពន្ធអត្ថបទមួយចុះក្នុងកាសែត "រ៉េអាលីតខ្មែរ" មានចំណងជើងថា តើលទ្ធិប្រជាធិបតេយ្យខ្មែរមានកំណើតយ៉ាងដូចម្តេច ? ទ្រង់បានបញ្ជាក់ថា គណបក្សប្រជាធិបតេយ្យដែលមានជ័យជំនះក្នុងការបោះឆ្នោត បានទទួលយកនូវអត្ថបទរដ្ឋធម្មនុញ្ញមួយដែលចម្លងយកមកពីអត្ថបទរដ្ឋធម្មនុញ្ញ ដែលគេដាក់អោយបារាំងសេសប្រើប្រាស់ក្នុងជំនាន់សាធារណរដ្ឋទី ៤ គ្រាន់តែមានការខុសគ្នាបន្តិចត្រង់ពាក្យ "ស្តេច" ជំនួសដោយ "ប្រធានាធិបតីនៃសាធារណរដ្ឋ" ហើយព្រះមហាក្សត្រខុសគ្នានឹងអត្ថបទបារាំងពុំមានសិទ្ធិធ្វើជាអធិបតីនៃក្រុមឧត្តមប្រឹក្សាតុលាការឡើយ ។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី ៤ ពុំមានចែងអំពីការត្រួតពិនិត្យធម្មនុញ្ញភាព គឺរហូតដល់ឆ្នាំ ១៩៥៨ ទើបបង្កើតស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់[10] ។

## ២.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ

រដ្ឋធម្មនុញ្ញ សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) គឺត្រូវបានបង្កើតឡើងនៅក្នុងសម័យសាធារណរដ្ឋ ដែលជំនួសរបបរាជានិយម ដែលជាទូទៅត្រូវបានហៅថា សម័យលន់ នល់ នៅក្រោមឥទ្ធិពលរបស់សហរដ្ឋអាមេរិក ។ រដ្ឋធម្មនុញ្ញ សាធារណរដ្ឋខ្មែរនេះ ត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧២តាមបញ្ញត្តិលេខ១៩/៧២ ប.ស.ខ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧២ ។ រដ្ឋធម្មនុញ្ញនេះ បានបែងចែកអំណាច ដោយប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ប្រើអំណាចនីតិប្រតិបត្តិដែលប្រជារាស្ត្រប្រគល់ជូន, រដ្ឋាភិបាលជាគណៈរដ្ឋមន្ត្រីដែលដឹកនាំដោយរដ្ឋ មន្ត្រីទីមួយ (នាយករដ្ឋមន្ត្រី) ហើយរដ្ឋមន្ត្រីទីមួយ និងសមាជិកគណៈរដ្ឋមន្ត្រី ត្រូវទទួលខុសត្រូវចំពោះប្រធានាធិបតីពីកិច្ចចាត់ការអនុវត្តនយោបាយរបស់រដ្ឋឱ្យបានសំរេចតាមសហសភាដែលមាន សភា

[8] រដ្ឋធម្មនុញ្ញ ១៩៤៧ មាត្រា ១១៩ (មាត្រា ១០១ ចាស់) ចែងថា ៖ រដ្ឋសភា មានសិទ្ធិបកស្រាយសេចក្តីបទរដ្ឋធម្មនុញ្ញនេះជាដាច់ ខាត។

[9] http://www.ccc.gov.kh/ccchistory_kh.php

[10] សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ សំរាប់ថ្នាក់មូលដ្ឋាន បណ្ឌិត ឈុន ណារ៉េត ឆ្នាំ ២០១២ ទំព័រ ៦៧ និងទំព័រ៦៨ រោងពុម្ព ដារ៉ា

ជាតិនិង ព្រឹទ្ធសភា ប្រើអំណាចនីតិបញ្ញត្តិ, ហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ប្រើអំណាចតុលាការ[11] ។

តាមរយៈរដ្ឋធម្មនុញ្ញ សាធារណរដ្ឋខ្មែរថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧២ នេះ បានបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពមួយ ដែលមានឈ្មោះថា "តុលាការធម្មនុញ្ញ" ។ ទោះបីជាមានឈ្មោះជាតុលាការធម្មនុញ្ញក៏ដោយ ក៏អង្គការនេះស្ថិតនៅដោយឡែកពីអង្គការតុលាការដែរ ហើយតុលាការធម្មនុញ្ញនេះពិនិត្យដោះស្រាយវិវាទកម្ម និងប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រជាធិបតី និងអនុប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ។ តុលាការធម្មនុញ្ញក៏ពិនិត្យ និងដោះស្រាយអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសមាជិកសហសភា និងជាអ្នកបកស្រាយជាចុងក្រោយនូវបទប្បញ្ញត្តិធម្មនុញ្ញ ។ តុលាការធម្មនុញ្ញនេះ ដំណើរការចាប់តាំងពីឆ្នាំ ១៩៧២ ប៉ុន្តែការមកដល់នៃរបបខ្មែរក្រហមនាឆ្នាំ ១៩៧៥ សង្គមកម្ពុជាត្រូវទទួលនូវវិនាសកម្ម និងការប្រល័យពូជសាសន៍រហូតដល់ដំណាច់ឆ្នាំ ១៩៧៨ ។ ដូច្នេះ ទោះបីជារដ្ឋធម្មនុញ្ញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧២ បានបង្កើតស្ថាប័ន "**តុលាការធម្មនុញ្ញ**" ក្តី ក៏រដ្ឋធម្មនុញ្ញនេះមិនបានប្រគល់អោយស្ថាប័នតុលាការធម្មនុញ្ញត្រួតពិនិត្យធម្មនុញ្ញភាពដែរ[12] ។

### ៣.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

សាធារណរដ្ឋខ្មែរត្រូវបានដួលរលំនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ជំនួសមកវិញដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋធម្មនុញ្ញ កម្ពុជាប្រជាធិបតេយ្យ គឺត្រូវបានបង្កើតឡើងនៅក្នុងសម័យនេះ ដែលរបបនេះដឹកនាំដោយមេបក្សកុំម្មុយនិស្តឈ្មោះ ប៉ុល ពត បានបោសសម្អាតរបបចាស់ចោលទាំងស្រុង ទាំងស្ថាប័ន ទាំងមនុស្ស ដោយបានកាប់សម្លាប់ ធ្វើទារុណកម្ម បង្អត់អាហារប្រជាពលរដ្ឋស្លាប់រាប់លាននាក់ បំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិខ្ទេចខ្ទី មិនអោយមានសាសនា មិនអោយមានការសិក្សារៀនសូត្រ និងមិនមានទីផ្សារ ។ ការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ប្រាសចាកទាំងស្រុងពីគោលការណ៍ច្បាប់ និងសិទ្ធិមនុស្ស ។ នៅលើផ្នែកនយោបាយ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានឈរលើគោលការណ៍ Marxisme (ម៉ាក្សស៊ីស) គឺគោលការណ៍គណបក្សតែមួយជាអ្នកដឹកនាំ[13] ។

ដោយសារតែការមកដល់នៃរបបខ្មែរក្រហម នៅឆ្នាំ ១៩៧៥ បាននាំមកនូវការកាប់សម្លាប់ប្រជាជន និងកំទេចបំផ្លាញរចនាសម្ព័ន្ធទាំងអស់ ព្រមទាំងជាន់ឈ្លីក្បួនច្បាប់ទាំងឡាយគ្មានសល់

[11] នីតិរដ្ឋធម្មនុញ្ញ សុខ យ៉ាន សុខ ចិន្តា ទំព័រ ១៣៨ ដល់ ទំព័រ ១៤៥

[12] សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ សំរាប់ថ្នាក់មូលដ្ឋាន បណ្ឌិត ឈុន ណារ៉េត ឆ្នាំ ២០១២ ទំព័រ ៦៨ ពោងពុម្ព ដារ៉ា

[13] នីតិរដ្ឋធម្មនុញ្ញ សុខ យ៉ាន សុខ ចិន្តា ទំព័រ ១៤៩ និង ទំព័រ ១៥២

រហូតដល់ ដំណាច់ឆ្នាំ ១៩៧៨ ដូច្នេះប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពមិនបានមាននៅក្នុងសម័យនេះឡើយ ហើយនៅក្នុងរដ្ឋធម្មនុញ្ញនេះ ក៏ពុំមានចែងពីសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពផងដែរ[14] ។

### ៤.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិត

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ទន្ទឹមនឹងការកសាងប្រទេសជាតិឡើងវិញគ្រប់វិស័យ ការស្តារប្រព័ន្ធច្បាប់ ក៏មានសកម្មភាព ខ្លាំងក្លាណាស់ដែរ ។ រដ្ឋធម្មនុញ្ញ សាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ ១៩៨១ អនុញ្ញាតអោយមានការបកស្រាយច្បាប់ដោយ ក្រុមប្រឹក្សារដ្ឋក្នុងឋានៈ ជាអង្គការអចិន្ត្រៃយ៍របស់ រដ្ឋសភា តែការត្រួតពិនិត្យធម្មនុញ្ញភាពទៅលើច្បាប់នោះគឺគ្មាននោះទេ។

### ៥.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា

ជំនួបកំពូលរវាង**សម្តេច នរោត្តម សីហនុ** និង លោក **ហ៊ុន សែន** តាំងពីថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៨៧ ដើម្បីស្វែងរកសន្តិភាព បានជម្រុញឱ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ខ្លួន ដោយដកចេញនូវអ្វីៗ ដែលជាប់ពាក់ព័ន្ធនឹងការធ្វើបដិវត្តន៍សង្គមនិយមតាមរបៀបម៉ាក្សនិយម ។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ តម្រូវឱ្យមានការកែប្រែនូវអ្វីៗដែលជាតំណាងរបបមុនគឺ សញ្ញាជាតិ ទង់ជាតិ និង ភ្លេងជាតិ ។ រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា អាចចាត់ទុកជាស្ពានមួយដើម្បីចំលងប្រទេសកម្ពុជាពីរបបកុំម្មុយនិស មករបបបែបសេរី ត្បិតរដ្ឋធម្មនុញ្ញនេះបានជូនសេរីភាពមួយកំរិតដល់ប្រជាពលរដ្ឋជាអាទ៍សេរីភាព ជំនឿ សាសនា ការអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជន សេរីភាពខាងការប្រកបអាជីវកម្មនានា ។ ល ។ លើកលែងតែសេរីភាពបង្កើតគណបក្សនយោបាយចេញ[15] ។ចាប់ពីឆ្នាំ ១៩៨៩ ដល់ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា បានចែងអំពីការបកស្រាយច្បាប់ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។ ប៉ុន្តែនៅពេលនោះ ការបកស្រាយរដ្ឋធម្មនុញ្ញ និងការត្រួតពិនិត្យធម្មនុញ្ញភាព នៃច្បាប់ពុំទាន់មាននៅឡើយ[16] ។

### ៦.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២

រដ្ឋធម្មនុញ្ញថ្មីដែលបានអនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដោយសភាធម្មនុញ្ញ ដែលកើតចេញពីការបោះឆ្នោតរៀបចំដោយអង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៣ ត្រូវបានប្រកាសអោយប្រើនៅ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។ ជំពូកទី ១០ នៃរដ្ឋធម្មនុញ្ញ (ក្រោយពីវិសោធនកម្ម ជំពូកទី ១២ ថ្មី នៃរដ្ឋធម្មនុញ្ញ) បានបង្កើតអោយមានស្ថាប័ន "**ក្រុមប្រឹក្សាធម្មនុញ្ញ**" ដែលមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ។

[14] http://www.ccc.gov.kh/cchistory_kh.php

[15] នីតិរដ្ឋធម្មនុញ្ញ សុខ យ៉ាន សុខ ចិន្តា ទំព័រ ១៥៧ និង ទំព័រ ១៥៨

[16] http://www.ccc.gov.kh/cchistory_kh.php

ក្រុមប្រឹក្សាធម្មនុញ្ញបានកំណត់ថ្ងៃទី ១៥ ខែ មិថុនា ជាខួបកំណើតរបស់ស្ថាប័ន ។ ជាទូទៅជារៀងរាល់ឆ្នាំ អោយតែដល់ថ្ងៃទី ១៥ ខែ មិថុនា (អាចមុន ឬក្រោយថ្ងៃទី ១៥ ខែ មិថុនា ដោយមូលហេតុថ្ងៃទី ១៥ ចំថ្ងៃបុណ្យ ឬថ្ងៃឈប់សំរាក) អគ្គលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សាធម្មនុញ្ញ តែងតែរៀបចំពិធីសំណេះសំណាលរវាងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាមួយនឹងមន្ត្រីរាជការ[17] ។

## កថាខណ្ឌទី២ សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា

### ១.នីតិវិធីតែងតាំងសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញដោយអង្គព្រះមហាក្សត្រ

បើពិនិត្យមើលទៅក្នុងរដ្ឋធម្មនុញ្ញ និង ព្រះរាជក្រមស្ដីអំពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ គឺ ពុំមានចែងអំពីនីតិវិធីសម្រាប់អង្គព្រះមហាក្សត្រធ្វើការតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទេ [18] ។ដូចនេះការតែងតាំងនេះ ស្ថិតនៅក្នុងការសម្រេចព្រះទ័យរបស់ព្រះមហាក្សត្រ។ប៉ុន្តែក្នុងព្រះរាជក្រមខាងលើបានចែង អំពីនីតិវិធីតែងតាំង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ៩ ឆ្នាំមួយរូប សម្រាប់អាណត្តិ៦ឆ្នាំ និង មួយរូបទៀតសម្រាប់អាណត្តិ៣ឆ្នាំ។

### ២.នីតិវិធីជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយរដ្ឋសភា

នីតិវិធីនៃការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយរដ្ឋសភា បានបែងចែកដាច់គ្នាសម្រាប់ការបោះឆ្នោតគាំទ្រ គឺសម្រាប់អាណត្តិទីមួយនៃក្រុមប្រឹក្សាធម្មនុញ្ញ(១៩៩៨ ដល់ ២០០១) និង សម្រាប់អាណត្តិបន្តបន្ទាប់របស់ ក្រុមប្រឹក្សាធម្មនុញ្ញ។

#### ២.១.ការជ្រើសតាំងនៅអាណត្តិទី១

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយរដ្ឋសភា អាចត្រូវធ្វើឡើងជា២លើកបាន។ប្រសិនបើជាការបោះឆ្នោតលើកទីមួយ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះទេ ត្រូវបោះឆ្នោតជាលើកទីពីរ ដោយយកតែបេក្ខជនទទួលសម្លេងច្រើនជាងគេ៥រូប មកបោះឆ្នោតឡើងវិញ។

ការបោះឆ្នោតសម្រាប់លើកទី២នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប។បេក្ខជនដែលបានសម្លេងច្រើនជាងគេ ត្រូវតែងតាំងសម្រាប់៩ឆ្នាំបេក្ខជនដែលមានសម្លេងបន្ទាប់ត្រូវតែងតាំងសម្រាប់៦ឆ្នាំ និង បេក្ខជនដែល ទទួលបានសម្លេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់៣ឆ្នាំ។

[17] សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ សំរាប់ថ្នាក់មូលដ្ឋាន បណ្ឌិត ឈុន ណារ៉េត ឆ្នាំ ២០១២ ទំព័រ ៦៩ រោងពុម្ព ដារ៉ា

[18] ព្រះរាជក្រមលេខជស/រកម/០៤៩៨ /០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨

## ២.២.ការបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបន្តបន្ទាប់

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដោយសភាអាចត្រូវធ្វើឡើងជា ២ លើកបាន។ការបោះឆ្នោតលើកទីមួយមិនបានទទួលមតិភាគច្រើនដាច់ខាត ត្រូវធ្វើការបោះឆ្នោតជាលើកទីពីរ ដោយយកតែបេក្ខជនដែលបានទទួលសម្លេងច្រើនជាងគេចំនួន២នាក់នៃការបោះឆ្នោតកាលពីលើកទីមួយ យកមកបោះឡើងវិញ។ការបោះឆ្នោតលើកទីពីរនេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប។ក្នុងករណីបេក្ខជន ទទួលបានសម្លេងស្មើគ្នាត្រូវយកបេក្ខជនដែលមានអាយុច្រើនជាងគេ។

## ៣.នីតិវិធីជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា១៣៨ថ្មី(១១៨ចាស់) បានចែងថា«.........បីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម»។ប៉ុន្តែតាមលិខិតចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៨ របស់**សម្តេចជា ស៊ីម** ប្រធានរដ្ឋសភា និង ជាតំណាងខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រដែលអញ្ជើញជាអធិបតីក្នុងសម័យប្រជុំរបស់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនាព្រឹកថ្ងៃទី២១ ខែ ឧសភា ឆ្នាំ១៩៩៨ បានទូលថ្វាយព្រះមហាក្សត្រអំពីលទ្ធផលនៃការបោះឆ្នោតរបស់ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ដូច្នេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមធ្វើការបោះឆ្នោតជ្រើសតាំងពុំមែនតែងតាំងទេ។

នៅក្នុងព្រះរាជក្រមស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបញ្ញត្តិថាក្នុងអាណត្តិទីមួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (១៩៩៨ ដល់២០០១) ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងសមាជិកមួយរូបសម្រាប់អាណត្តិ៣ឆ្នាំមួយរូប សម្រាប់អាណត្តិ៦ឆ្នាំ និង មួយរូបទៀតសម្រាប់អាណត្តិ ៩ឆ្នាំ។

## ៤.លក្ខខណ្ឌទូទៅក្នុងការជ្រើសតាំង និង តែងតាំង

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានៈ

- សញ្ជាតិខ្មែរពីកំណើត
- ត្រូវមានអាយុយ៉ាងតិច៤៥ ឆ្នាំ
- មានបទពិសោធន៍ក្នុងការងារយ៉ាងតិច១៥ឆ្នាំ

- មានសញ្ញាបត្រចាប់ពីឧត្តមសិក្សាឡើងទៅ ខាងច្បាប់ រដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច។[19]

ការកំណត់កម្រិតវប្បធម៌របស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញបញ្ជាក់បានថា ស្ថាប័ននេះមិនមែនជាអង្គការនយោបាយទេ គឺពិតជាក្រុមជំនាញបច្ចេកទេស ដែលសុទ្ធសឹងតែមានបទពិសោធន៍ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត និង សេដ្ឋកិច្ចជាដើម។

### ៥.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំង

#### ៥.១.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា

បេក្ខជនឈរឈ្មោះសម្រាប់រដ្ឋសភា ជ្រើសតាំងធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅក្នុងអាណត្តិទី១ ក៏ដូចជាអាណត្តិបន្តបន្ទាប់មិនមានលក្ខខណ្ឌកំណត់ថា បុគ្គលនោះជាអ្នកតំណាងរាស្ត្រនោះទេ គឺអាចថា ជាអ្នកតំណាងរាស្ត្រឬ ឥស្សរជនដទៃទៀតឱ្យតែគ្រប់លក្ខខណ្ឌ និង គុណសម្បត្តិដែលមានចែងនៅក្នុងមាត្រា ១៣៨ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា៣ នៃ ព្រះរាជក្រមស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ(ដូចជារៀបរាប់ខាងលើ)។ ប៉ុន្តែបេក្ខជនម្នាក់ៗ ជាការចាំបាច់ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ហើយសមាជិករដ្ឋសភាមួយរូបមានសិទ្ធិគាំទ្រតែបេក្ខជនមួយរូបប៉ុណ្ណោះ។

#### ៥.២.លក្ខខណ្ឌដោយឡែកនៃការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ការជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនកំណត់បេក្ខជននោះត្រូវជាចៅក្រមនោះទេគឺអាចជាចៅក្រម ឬ ឥស្សរជនដទៃទៀតឱ្យតែគ្រប់លក្ខខណ្ឌ និង គុណសម្បត្តិដូចមានចែងនៅក្នុងមាត្រា១៣៨ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា៣នៃព្រះរាជក្រមស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

តាមមាត្រា១៣៨ ថ្មី (មាត្រា១១៨ចាស់) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា «......បីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម»។នៅក្នុងវាក្យខណ្ឌទី២ នៃ មាត្រា៣ មាត្រា៤ មាត្រា៣០ និង មាត្រា៣៨ នៃ ព្រះរាជក្រមស្តីពីការរៀបចំនិង ប្រព្រឹត្ត ទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ សុទ្ធសឹងតែបញ្ជាក់ថាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមួយរូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺបានន័យថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺជាអ្នកចង្អុលការតែងតាំងតែម្តងពុំមានការបោះឆ្នោត

[19] មាត្រា៣ នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ជ្រើសរើសនោះទេ។ឯកឧត្តម **ចែម សួន** តំណាងរាជរដ្ឋាភិបាលបានថ្លែងការពារច្បាប់ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាបានមានប្រសាសន៍បញ្ជាក់ថា«...ក្រៅបេក្ខជន ដែលព្រះមហាក្សត្រទ្រង់ស្នើមក និងក្រៅពីបេក្ខជនខាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីព្រោះខាងលើនោះសុទ្ធតែជាចៅក្រម ហើយនឹងមន្ត្រីក្រសួងយុត្តិធម៌......។

## ផ្នែកទី៣ ប្រវត្តិដើមនៃគំនិតបង្កើតឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន

បន្ទាប់ពីបានរៀបរាប់អំពីប្រព័ន្ធនៃការកកើត និង ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរដ្ឋធម្មនុញ្ញនៃសម័យកាលនីមួយៗរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការរៀបចំបង្កើត និងសមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញដូចខាងលើ នៅក្នុងផ្នែកទី ៣ នេះនឹងធ្វើការរៀបរាប់អំពីប្រវត្តិនៃការកកើត (កថាខណ្ឌទី ១ ) ការរៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុននាពេលបច្ចុប្បន្ន (កថាខណ្ឌទី ២) និងអំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន (កថាខណ្ឌទី ៣) ។

### កថាខណ្ឌទី១ ប្រវត្តិនៃការកកើត

ប្រសិនបើយើងក្រឡេកមើលទៅលើប្រវត្តិសាស្ត្ររបស់ប្រទេសជប៉ុនវិញ ប្រទេសជប៉ុនមានប្រវត្តិនៃការកកើតប្រទេសរបស់ខ្លួន ជាយូរលង់ណាស់មកហើយ បើប្រៀបធៀបជាមួយប្រទេសកម្ពុជា ហើយប្រទេសជប៉ុនក៏អាចចាត់ទុកថាជា ប្រទេសដែលមានវ័យចំណាស់មួយដូចប្រទេសកម្ពុជាដែរ ។ ផ្ទុយទៅវិញ ចំពោះប្រវត្តិនៃការបង្កើតរដ្ឋធម្មនុញ្ញរបស់ប្រទេសជប៉ុន គឺប្រទេសជប៉ុនបានបង្កើតរដ្ឋធម្មនុញ្ញរបស់ខ្លួនតែពីរដងប៉ុណ្ណោះ គឺរដ្ឋធម្មនុញ្ញសម័យម៉េជិ និង រដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្ន ដែលនេះផ្ទុយស្រឡះទៅនឹងរដ្ឋធម្មនុញ្ញរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ដែលបានបង្កើតរដ្ឋធម្មនុញ្ញចំនួន ៦ ដង រួចមកហើយ នៅគ្រប់សម័យទាំងអស់បន្ទាប់ពីសម័យអាណានិគមបារាំង រហូតមកដល់សម័យបច្ចុប្បន្ន ។ ដូច្នេះ ដើម្បីស្វែងយល់អំពីប្រវត្តិនៃការបង្កើតរដ្ឋធម្មនុញ្ញ និង ការត្រួតពិនិត្យធម្មនុញ្ញភាពតាមសម័យនីមួយៗ យើងនឹងធ្វើការសិក្សាអំពីប្រវត្តិរដ្ឋធម្មនុញ្ញ និង ការត្រួតពិនិត្យធម្មនុញ្ញភាពតាមសម័យនីមួយៗរបស់ប្រទេសជប៉ុនដូចខាងក្រោម ។

#### ១.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសម័យម៉េជិ

ក្រោយពេលចូលដល់សម័យម៉េជិ ដោយសារតែប្រទេសជប៉ុនចង់ក្លាយខ្លួនជាប្រទេសអារ្យប្រទេសស្ថិតនៅក្នុងកំរិតប្រហាក់ប្រហែលនឹងប្រទេសលោកខាងលិច ប្រទេសជប៉ុនបានរៀបចំប្រព័ន្ធច្បាប់បែបសម័យថ្មីយ៉ាងប្រញាប់ប្រញាល់ ។ ហើយនៅពេលនោះក៏មានការទាមទារយ៉ាងខ្លាំងពីប្រជាពលរដ្ឋអោយបង្កើតសភាដែលកើតឡើងពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ និង បង្កើតរដ្ឋធម្មនុញ្ញ ។ ដូចនេះ រដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）ត្រូវបានប្រកាសនៅឆ្នាំ ១៩៨៩ ហើយក្លាយជាប្រទេសដែលទទួលយករបបអាស្រ័យរដ្ឋធម្មនុញ្ញលឿនជាងគេបំផុតនៅអាស៊ីខាងកើត។ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសជប៉ុន រដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）គឺជារដ្ឋធម្មនុញ្ញដំបូងបង្អស់របស់ប្រទេសជប៉ុន ។ រដ្ឋធម្មនុញ្ញនេះគឺជា រដ្ឋធម្មនុញ្ញដែលផ្តល់អំណាចគ្រប់គ្រងរដ្ឋអោយទៅព្រះចៅអធិរាជ ។

ផ្ទុយទៅវិញ ការប្រតិបត្តិអំណាចគ្រប់គ្រងរដ្ឋ របស់ព្រះចៅអធិរាជត្រូវបានកម្រិតក្នុងរដ្ឋធម្មនុញ្ញ ដោយសារក្នុងរដ្ឋធម្មនុញ្ញនេះបានដាក់បញ្ចូលនូវប្រព័ន្ធរបបលទ្ធិប្រជាធិបតេយ្យចូល ។ បើទោះបីជារដ្ឋធម្មនុញ្ញនេះបានដាក់បញ្ចូលនូវប្រព័ន្ធរបបលទ្ធិប្រជាធិបតេយ្យចូលក៏ដោយ ក៏ប៉ុន្តែការបង្កើតរដ្ឋធម្មនុញ្ញនេះមិនបានបង្កើតឡើងតាមរយៈឆន្ទៈរបស់ប្រជាជនឡើយ គឺព្រះចៅអធិរាជជា អ្នកបង្កើត ហើយឱ្យប្រជាជនជាអ្នកអនុវត្តតាមការបញ្ជារបស់ព្រះអង្គ ។ ម៉្យាងវិញទៀត ថ្វីត្បិតតែរដ្ឋធម្មនុញ្ញនេះបានបែកចែកអំណាចទាំងបី (អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ) ប៉ុន្តែបើសង្កេតមើលទៅលើបញ្ញត្តិដែលបានចែង ផ្តល់សិទ្ធិអំណាចទៅឱ្យព្រះចៅអធិរាជយ៉ាងខ្លាំងដែលអធិរាជអាចលូកដៃចូលទៅក្នុងអំណាចណាក៏បាន [20]។

ប្រសិនបើយើងក្រលេកទៅមើល អំពីប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅក្នុងរដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）វិញ យើងសង្កេតឃើញថាមិនមាននិយាយអំពីការត្រួតពិនិត្យធម្មនុញ្ញភាពឡើយ ។ ដូចនេះ យើងអាចសន្និតថា រដ្ឋធម្មនុញ្ញសម័យម៉េជិនេះ គ្មានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពឡើយ ។

## ២.ការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈរដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្ន

ក្រោយពីចាញ់សង្គ្រាមលោកលើកទី ២ មក ប្រទេសជប៉ុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ GHQ（連合国総司令部、General Headquarters）ក៏ប៉ុន្តែសហរដ្ឋអាមេរិកជាអ្នកគ្រប់គ្រងដោយផ្ទាល់ ។ ដើម្បីធ្វើកំណែទម្រង់ប្រទេសជប៉ុនឱ្យក្លាយជាប្រទេសប្រជាធិបតេយ្យ GHQ（連合国総司令部、General Headquarters）បានបញ្ជាឱ្យប្រទេសជប៉ុនវិសោធនកម្មរដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）។ ថ្វីត្បិតតែ រដ្ឋាភិបាលប្រទេសជប៉ុនបានវិសោធនកម្មរដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）ក៏ប៉ុន្តែ GHQ（連合国総司令部、General Headquarters）មិនយល់ស្របទៅនឹង អត្ថន័យនៃការវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ទើប GHQ（連合国総司令部、General Headquarters）បានធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី ហើយរដ្ឋាភិបាលប្រទេសជប៉ុនបានយកសេចក្តីព្រាងនោះ ធ្វើជាគម្រូនៃការវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ និង ប្រកាសអោយប្រើប្រាស់ ។ ក្រោយពីវិសោធនកម្មរដ្ឋធម្មនុញ្ញសម័យម៉េជិ（明治憲法/大日本帝国憲法、Meiji Constitution）រួចមក រដ្ឋធម្មនុញ្ញនេះត្រូវបានប្តូរ

---

[20] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）、（公民 3） 35 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យាដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៣៥

ឈ្មោះទៅជា រដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution）វិញ ហើយ ប្រកាសឱ្យប្រើនៅ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៦ និង អនុវត្តនៅ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៤៧[21] ។

រដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution）នេះបានការពារ យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សិទ្ធិជាមូលដ្ឋានទាំងបីធំៗ មានដូចជា ការគោរពនូវសិទ្ធិមនុស្សជា មូលដ្ឋាន លទ្ធិប្រជាធិបតេយ្យ និង លទ្ធិសន្តិភាព ។ ទន្ទឹមនឹងនេះ រដ្ឋធម្មនុញ្ញនេះបានបែងចែក អំណាចទាំងបី អោយប្រសើរឡើងជាងរដ្ឋធម្មនុញ្ញចាស់ ដោយអំណាចទាំងបីនេះ ត្រួតពិនិត្យ តុល្យភាពអំណាចគ្នាទៅវិញទៅមក [22]។

ប្រសិនបើយើងក្រឡេកទៅមើលការអនុវត្ត អំពីប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution） វិញ យើងសង្កេតឃើញថា នៅ ក្នុងរដ្ឋធម្មនុញ្ញនេះ បាននាំយកប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពយកមកអនុវត្តនៅប្រទេសជប៉ុន ដែល យកគម្រូតាមប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពរបស់សហរដ្ឋអាមេរិក ។ យោងតាមមាត្រា ៨១ នៃរដ្ឋធម្មនុញ្ញនេះបានចែងថា "តុលាការកំពូល ជាតុលាការចុងក្រោយដែលមានអំណាចកាត់សេចក្ដីថា តើ ច្បាប់ បទបញ្ជា បទបញ្ជាផ្ទៃក្នុង ដីកា សារាចរជាដើមស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ" ដូចនេះ យោងតាមមាត្រា ៨១ នេះ មានន័យថា រដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution）បាននាំយកប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពយកមកអនុវត្តនៅប្រទេសជប៉ុន[23]។

21 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）、（公民 3・5）66 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៣៥

22 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）、（公民 3・5）36 頁、66 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៦៦

23 衆議院憲法調査会事務局『「司法制度及び憲法裁判所（憲法の有権解釈権の所在の視点から）」に関する基礎的資料』（衆憲資第 29 号）（2013）9 頁
ការិយាល័យស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា 『ឯកសារមូលដ្ឋានទាក់ទងនឹង「ប្រព័ន្ធយុត្តាធិការ និង តុលាការធម្មនុញ្ញ （ពីចក្ខុវិស័យ នៃសិទ្ធិមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ）」』（លេខ ២៩）（ឆ្នាំ ២០១៣）ទំព័រ ៩

## កថាខណ្ឌទី២ ការរៀបចំបង្កើតស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន នាពេលបច្ចុប្បន្ន

បន្ទាប់ពីបានសិក្សាទៅលើ ប្រវត្តិនៃការកកើត (កថាខណ្ឌទី ១) ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុនរួចមក នៅក្នុងកថាខណ្ឌទី ២ នេះ យើងនឹងធ្វើការសិក្សាពី ការរៀបចំបង្កើតស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុននាពេលបច្ចុប្បន្ន ថាតើហេតុអ្វីបានជាបង្កើតប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនេះ ហើយត្រូវបានបង្កើតឡើងដោយរបៀបណា នៅពេលណា ដោយនរណាផងដែរ ។

ក្រោយពីសង្គ្រាមលោកលើកទី ២ ប្រទេសជប៉ុនបានបង្កើតរដ្ឋធម្មនុញ្ញប្រទេសជប៉ុន (日本国憲法、The Japanese Constitution) ប្រកាសឱ្យប្រើនៅ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៦, អនុវត្តនៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៤៧) ដែលជាកំណែទម្រង់ក្រោយសង្គ្រាមដ៏សំខាន់ ដើម្បីឱ្យប្រទេសជប៉ុនក្លាយជាប្រទេសប្រជាធិបតេយ្យ ។ រដ្ឋធម្មនុញ្ញសម័យម៉េជិ (大日本帝国憲法、Meiji Constitution ) ដែលបានបង្កើតនៅមុនសង្គ្រាមលោកលើកទី ២ និងជារដ្ឋធម្មនុញ្ញដំបូងរបស់ប្រទេសជប៉ុន គឺមិនបានចែងអំពីអំណាចត្រួតពិនិត្យធម្មនុញ្ញភាពទៅតុលាការឡើយ ដូច្នេះត្រូវបានគេបកស្រាយថា ក្នុងរដ្ឋធម្មនុញ្ញសម័យម៉េជិ (大日本帝国憲法、Meiji Constitution) តុលាការមិនមានអំណាចនៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនោះទេ ។ ដោយសារតែនៅក្នុងរដ្ឋធម្មនុញ្ញសម័យម៉េជិ (大日本帝国憲法、Meiji Constitution) មិនបានចែងអំពីប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ។ ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពត្រូវបាននាំមកជាលើកដំបូងនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន (日本国憲法、The Japanese Constitution) ហើយក្នុងរដ្ឋធម្មនុញ្ញនេះ មាត្រា ៨១ បានចែងថា តុលាការកំពូល ជាតុលាការចុងក្រោយដែលមានអំណាចកាត់សេចក្តីថាតើ ច្បាប់ បទបញ្ជា បទបញ្ជាផ្ទៃក្នុង ដីកា សារាចរជាដើមស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

ក៏ប៉ុន្តែនៅពេលនោះ ប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាពដែលទើបតែយកមកប្រើនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន (日本国憲法、The Japanese Constitution) គឺមានទ្រឹស្តីប្រឆាំងគ្នាថាតើគឺជាប្រភេទយុត្តាធិការតុលាការ (司法裁判所型、Judicial Review System) ក៏ត្រូវបានហៅថាជាប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបែបរួបី (付随的違憲審査制) ព្រោះអំណាចត្រួតពិនិត្យធម្មនុញ្ញភាពត្រូវបានប្រើជាប់ជាមួយការអនុវត្តអំណាចតុលាការ ដែលទទួលស្គាល់អំណាចត្រួតពិនិត្យធម្មនុញ្ញភាពនៅតុលាការ ឬ ថាតើជាប្រភេទច្របាច់បញ្ចូលគ្នា ( 折 衷 型 ) រវាងប្រភេទយុត្តាធិការតុលាការ (司法裁判所型、Judicial Review System) និង គឺជាប្រភេទតុលាការធម្មនុញ្ញ (憲法裁判所型、Constitutional Court System) ។ ចំពោះគោលជំហរមតិខាងក្រោយ គឺផ្តោតទៅលើឃ្លា

ក្នុងមាត្រា ៨១ នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន បានចែងថា តុលាការកំពូលមានសិទ្ធិអំណាចវិនិច្ឆ័យលើរដ្ឋធម្មនុញ្ញ ដូចនេះមតិនេះយល់ថា តុលាការទាំងអស់ទទួលបានអំណាចត្រួតពិនិត្យធម្មនុញ្ញភាពជាប់ជាមួយអំណាចតុលាការ ហើយលើសពីនេះទៅទៀត តុលាការកំពូលមានសិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាពបែបអរូបី (抽象的違憲審査権、 Abstract Constitutional Review Rights) ។ តុលាការកំពូលគឺមានរូបរាងគ្រប់គ្រងដូចជាស្តង់ដាបែបអរូបីរបស់តុលាការរដ្ឋធម្មនុញ្ញប្រទេសអាឡឺម៉ង់ និង អាចចេញសេចក្តីសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ ផ្អែកលើការទាមទាររបស់ស្ថាប័ននីតិបញ្ញត្តិ ឬ ស្ថាប័ននីតិប្រតិបត្តិដោយមិនចាំបាច់មានរឿងក្តីជាក់ស្តែងឡើយ ។ ក៏ប៉ុន្តែ ចំពោះអំណាចត្រួតពិនិត្យធម្មនុញ្ញភាពបែបអរូបី ប្រសិនបើមាត្រា ៨១ នៃរដ្ឋធម្មនុញ្ញជប៉ុន មានចែងផ្តល់អោយអំណាចត្រួតពិនិត្យធម្មនុញ្ញភាពបែបអរូបីទៅតុលាការកំពូល ប្រាកដជាមានចែងនៅក្នុងរដ្ឋធម្មនុញ្ញអំពីចំណុចមូលដ្ឋានទាក់ទងពីការប្រើប្រាស់អំណាចត្រួតពិនិត្យធម្មនុញ្ញភាពបែបអរូបី ដែលមានដូចជា សិទ្ធិអ្នកដាក់ពាក្យបណ្តឹង លក្ខខ័ណ្ឌដាក់ពាក្យបណ្តឹង អានុភាពនៃសេចក្តីសម្រេចជាដើម តែត្រូវបានគេបកស្រាយថា មិនអាចយកមកអនុវត្តបានឡើយនៅប្រទេសជប៉ុន ដោយសារតែនៅក្នុងរដ្ឋធម្មនុញ្ញជប៉ុនមិនមានចែងអំពីបញ្ញត្តិនេះឡើយ ។ ដូច្នេះ គោលជំហរមតិជំបូងដែលបាននិយាយថា មានតែអំណាចត្រួតពិនិត្យធម្មនុញ្ញភាពដែលបាននៅជាប់ការអនុវត្តអំណាចតុលាការ រួមទាំងតុលាការកំពូលផងនោះ គឺជាទ្រឹស្តីរួមដែលត្រូវបានគេយកមកប្រើយ៉ាងច្រើនលើសលប់ ហើយទ្រឹស្តីដែលគាំទ្រគោលជំហរមតិជំបូងជាច្រើនបាននិយាយថា ផ្អែកតាមច្បាប់ ការដែលផ្តល់អោយអំណាចត្រួតពិនិត្យធម្មនុញ្ញភាពបែបអរូបីទៅតុលាការកំពូលនោះ គឺវាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។ លើសពីនេះទៅទៀត តុលាការកំពូលផងដែរក៏បានបញ្ជាក់យ៉ាងច្បាស់ថាយកតាមគោលជំហរមតិជំបូង ហើយប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញដែលបានចែងក្នុងរដ្ឋធម្មនុញ្ញជប៉ុន គឺស្ថាប័នតុលាការត្រូវប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបែបយុត្តាធិការតុលាការ (司法裁判所、Judicial Review) ពោលគឺអាចធ្វើសេចក្តីសម្រេចត្រួតពិនិត្យធម្មនុញ្ញភាពបានតែក្នុងករណីចាំបាច់ ដែលមានទាក់ទងនឹងរឿងក្តីដែលកំពុងកាត់ក្តីនៅក្នុងតុលាការ[24] ។ ម្យ៉ាងវិញទៀត ដោយសារតែប្រទេសជប៉ុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិច ទើបប្រទេសនេះជ្រើសយកប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពតាមបែបយុត្តាធិការតុលាការ (司法裁判所、Judicial Review) ពោលគឺជាប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបែបរូបី (付随的違憲審査制) អំណាចត្រួតពិនិត្យធម្មនុញ្ញភាពត្រូវបានប្រើជាប់ជាមួយការអនុវត្ត

[24] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）104-105 頁
ម៉ាសាអុ អិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឹមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១០៤ និង ១០៥

អំណាចតុលាការ ដែលទទួលស្គាល់អំណាចត្រួតពិនិត្យធម្មនុញ្ញភាពនៅតុលាការ ដែលនៅសហរដ្ឋអាមេរិកក៏អនុវត្តប្រព័ន្ធនេះផងដែរ [25]។

## កថាខណ្ឌទី៣ អំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន

បន្ទាប់ពីបានសិក្សាទៅលើ ប្រវត្តិនៃការកកើត (កថាខណ្ឌទី ១) និង ការរៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុននាពេលបច្ចុប្បន្ន (កថាខណ្ឌទី ២) រួចមក នៅក្នុងកថាខណ្ឌទី ៣ នេះ យើងនឹងធ្វើការសិក្សាពីអំពីស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ថាតើស្ថាប័នណាមានសិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន ។

ប្រសិនបើនិយាយអំពីការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាលនៃសេចក្តីព្រាងច្បាប់ជាដំបូង គឺ គណៈរដ្ឋមន្ត្រីក៏ជាស្ថាប័នមួយដែលពិនិត្យពាក្យពេចន៍ និង អត្ថាធិប្បាយ ក៏ដូចជាធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់ផងដែរ មុននឹងដាក់ស្នើសេចក្តីព្រាងច្បាប់ទៅឱ្យរដ្ឋសភា និង ព្រឹទ្ធសភា ពិនិត្យ និង អនុម័ត ។ បើទោះជាច្បាប់មិនមានចែង កំណត់អំពីសិទ្ធិអំណាចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់នៅក្នុងដំណាក់កាលគណៈរដ្ឋមន្ត្រី ក៏ប៉ុន្តែ ជាទម្លាប់របស់ស្ថាប័ននីតិប្រតិបត្តិ គឺមានគោលគំនិតចាក់ជាប់យ៉ាងជ្រៅ ចង់ធ្វើសេចក្តីព្រាងច្បាប់យ៉ាងល្អបំផុតមុននឹងដាក់ជូនទៅសភា ទើបនៅពេលដែលដាក់ជូនទៅសភាពិនិត្យ ជាទូទៅកម្រមានមតិប្រឆាំង ។ បន្តមកទៀត នៅក្នុងសភា (រដ្ឋសភា និង ព្រឹទ្ធសភា) ក៏ត្រួតពិនិត្យពាក្យពេចន៍និង អត្ថាធិប្បាយ ក៏ដូចជាធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់ផងដែរ មុនពេលអនុម័ត និង ប្រកាសឱ្យប្រើប្រាស់ ។ ចំពោះការធ្វើសេចក្តីព្រាងច្បាប់ មិនមែនតែស្ថាប័ននីតិប្រតិបត្តិប៉ុណ្ណោះទេ ដែលធ្វើសេចក្តីព្រាងច្បាប់ តំណាងរាស្ត្រដែលជាសមាជិកសភាក៏អាចធ្វើសេចក្តីព្រាងច្បាប់បានដែរ គ្រាន់ខាងស្ថាប័ននីតិប្រតិបត្តិពិនិត្យយ៉ាងម៉ត់ចត់ជាងខាងសភា (រដ្ឋសភា និង ព្រឹទ្ធសភា) ។ ផ្ទុយទៅវិញ បើទោះបីជាស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័ននីតិបញ្ញត្តិ មានសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល ក៏ប៉ុន្តែ ចំពោះសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ទៅលើច្បាប់ដែលបានអនុម័ត និង ប្រកាសអោយអនុវត្តរួច ស្ថាប័នទាំងពីរនេះ មិនមានសិទ្ធិក្នុងការសើរើអោយត្រួតពិនិត្យធម្មនុញ្ញភាពឡើយ [26]។

---

[25] 衆議院憲法調査会事務局『「司法制度及び憲法裁判所（憲法の有権解釈権の所在の視点から）」に関する基礎的資料』（衆憲資第 29 号）（2013）9 頁
ការិយាល័យស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា『ឯកសារមូលដ្ឋានទាក់ទងនឹង「ប្រព័ន្ធយុត្តាធិការ និង តុលាការធម្មនុញ្ញ（ពីចក្ខុវិស័យ នៃសិទ្ធិមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ）」』（លេខ ២៩）（ឆ្នាំ ២០១៣）ទំព័រ ៩

[26] 名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）、（Flight S402）196-197 頁

ក៏ប្រសិនបើយើងក្រឡេកមើល ថាតើស្ថាប័នណាមានសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល នោះគឺស្ថាប័នតុលាការ ពោលគឺ តុលាការគ្រប់ជាន់ថ្នាក់នៅប្រទេសជប៉ុនទាំងអស់ មានអំណាចត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ។ យោងតាមមាត្រា ៨១ នៃរដ្ឋធម្មនុញ្ញប្រទេសជប៉ុន（日本国憲法、The Japanese Constitution）បានចែងថា "តុលាការកំពូល ជាតុលាការចុងក្រោយដែលមានអំណាចកាត់សេចក្ដីថាតើ ច្បាប់ បទបញ្ជា បទបញ្ជាផ្ទៃក្នុង ដីកា សារាចរជាដើម ស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ" ។ ដូចនេះ យោងតាមមាត្រា ៨១ នេះ មិនមែនត្រឹមតែតុលាការកំពូលទេ ដែលមានអំណាចត្រួតពិនិត្យធម្មនុញ្ញភាព ក៏ប៉ុន្តែតុលាការគ្រប់ជាន់ថ្នាក់នៅប្រទេសជប៉ុនទាំងអស់ សុទ្ធតែមានអំណាចត្រួតពិនិត្យធម្មនុញ្ញភាព គ្រាន់តែមាត្រានេះចង់ផ្ដោតទៅអំណាចដែលត្រួតពិនិត្យធម្មនុញ្ញភាពចុងក្រោយបំផុតគឺ ផ្ដល់ទៅឱ្យតុលាការកំពូលតែប៉ុណ្ណោះ ។ ពោលគឺ តុលាការគ្រប់ជាន់ថ្នាក់នៅប្រទេសជប៉ុនទាំងអស់ សុទ្ធតែមានអំណាចត្រួតពិនិត្យធម្មនុញ្ញភាព ហើយ ច្បាប់ សារាចរ ឬ បទបញ្ជាទាំងឡាយណាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ គឺត្រូវលុបចោល ។ ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនេះគឺ ដើម្បីឱ្យតុលាការបំពេញកាតព្វកិច្ចខ្លួន ក្នុងគោលបំណងដើម្បីការពារការពិនិត្យតុល្យភាពនៃអំណាចចំពោះសភា និង គណៈរដ្ឋមន្ត្រី [27]។

សរុបសេចក្ដីមក ស្ថាប័នដែលមានសិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន គឺ ចែកចេញជា ពីរ គឺ ស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័ននីតិបញ្ញត្តិ មានសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល និង ស្ថាប័នតុលាការ មានសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ។

---

មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកញ្ញា ឆ្នាំ ២០១៣) ទំព័រ ១៩៦ និង ១៩៧

[27] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）、（公民 5）66 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៦៦

# ជំពូកទី២

## សមត្ថកិច្ចនៃការត្រួតពិនិត្យ

## ធម្មនុញ្ញភាព

## នៅប្រទេសកម្ពុជា និងប្រទេស ជប៉ុន

# ជំពូកទី២
# សមត្ថកិច្ចនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា និងប្រទេស ជប៉ុន

## ផ្នែកទី១ ការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជា

### កថាខណ្ឌទី១ គោលការណ៍ត្រួតពិនិត្យធម្មនុញ្ញភាព

នៅព្រះរាជាណាចក្រកម្ពុជាក្រុមប្រឹក្សាធម្មនុញ្ញធ្វើការត្រួតពិនិត្យ ទាំងទម្រង់និងគតិច្បាប់។ នៅក្នុងការសិក្សាស្រាវជ្រាវអំពីការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅលើទម្រង់ ឬ បែបបទទាំងនេះ គឺជាការត្រួតពិនិត្យអំពីការប្រតិបត្តិនានា ទៅតាមលក្ខខណ្ឌទាំងឡាយដែលរដ្ឋធម្មនុញ្ញបានកំណត់ជាច្បាប់កំពូល និង ជាការទាមទារ ដែលតម្រូវឱ្យមានការពាក់ព័ន្ធចំពោះ ការបង្កើតនូវលិខិតបទដ្ឋានណាមួយនោះ។គឺបានន័យថា តើការបង្កើតលិខិតបទដ្ឋាននោះ តម្រូវដោយអង្គការណាមួយ?តើអង្គការនោះបានធ្វើទៅតាមនីតិវិធីដែលរដ្ឋធម្មនុញ្ញបានតម្រូវដែរឬយ៉ាងណា?

ក្រុមប្រឹក្សាធម្មនុញ្ញនឹងពិនិត្យអំពីទម្រង់ច្បាប់ដូចដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានបញ្ញត្តិថា៖ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់។តំណាងរាស្ត្រមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬ បន្ថែមបន្ទុកលើប្រជាពលរដ្ឋ។ការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និង ប្រធានរដ្ឋសភា តាមការស្នើសុំរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។ការសើរើ ឬ វិសោធកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលត្រូវ អនុម័តដោយរដ្ឋសភាតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

រដ្ឋសភាអនុម័តច្បាប់ និង ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័ត យល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។បើជាការប្រញាប់រយៈពេលនោះត្រូវតែបន្ថយមកត្រឹមតែប្រាំថ្ងៃ។ បើព្រឹទ្ធសភាពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលមានកំនត់ទុកហើយនោះច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើដោយអង្គព្រះមហាក្សត្រ។បើព្រឹទ្ធសភាសុំឱ្យកែសម្រួលលើសេចក្តីព្រាងច្បាប់ឬ សេចក្តីស្នើច្បាប់ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ

ឬ ចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬ ទុកជាបានការខ្លះ ។ការបង្វិលទៅបង្វិលមកវាងព្រឹទ្ធសភា និង រដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ[28]។ រយៈពេលនេះត្រូវបន្ថយមកត្រឹមតែដប់ថ្ងៃ បើពិនិត្យសម្រេចពីថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។ បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកឱ្យសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះជាអសារបង់រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យច្បាប់ថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។ការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះរដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និង យកតាមមតិភាគច្រើនដាច់ខាត។សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយ នោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

ក្រុមប្រឹក្សាធម្មនុញ្ញក៏ពិនិត្យអំពីទម្រង់ទៅតាមបញ្ញត្តិផ្ទៃក្នុងនៃរដ្ឋសភាផងដែរគឺសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។សេចក្តីព្រាងច្បាប់នោះ ជាលិខិតលាយលក្ខណ៍អក្សរហើយត្រូវចែកជូនតំណាងរាស្ត្រទាំងអស់ព្រមទាំងមានសេចក្តីថ្លែងហេតុមកជាមួយផង។គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីព្រាងនោះទៅគណៈកម្មការតាមមុខជំនាញពិនិត្យជំបូង។កាលបើពិនិត្យរួចហើយនោះ ប្រធានគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។សេចក្តីស្នើច្បាប់ដែលអ្នកតំណាងរាស្ត្រជាអ្នកធ្វើត្រូវធ្វើជា លាយលក្ខណ៍អក្សរចែកជាមាត្រាហើយមានសេចក្តីថ្លែងហេតុនៅ ខាងដើមមកជាមួយផង។ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ត្រូវធ្វើទៅតាមនីតិវិធីដូចខាងក្រោម៖

- ពិភាក្សា និង អនុម័តលើខ្លឹមសារទាំងមូលគឺបញ្ចេញមតិថា តើគួរពិចារណាឬទេ។
- អង្គសភាពិភាក្សា និង អនុម័តលើមាត្រាមួយម្តងៗក៏បានមួយជំពូកម្តងៗក៏បានអង្គសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបានដោយពិភាក្សាតែមាត្រា ឬ ជំពូកណាដែលមានសំណើវិសោធនកម្មជាលាយលក្ខណ៍អក្សរ។នៅក្នុងការអនុវត្តនូវវិធីណាមួយគណៈកម្មការអចិន្ត្រៃយ៍ត្រូវជូនពត៌មានដល់អ្នកតំណាងរាស្ត្រជាមុន។
- អង្គសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ទាំងមូល។

[28] មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

នីតិវិធីនៃការអនុម័តរបស់អង្គនីតិបញ្ញត្តិមាន ៣ យ៉ាង គឺ ដោយលើកដៃ ដោយបោះឆ្នោតជាចំហ ឬ ដោយបោះឆ្នោតជាសម្ងាត់។វិធីបញ្ចេញមតិ ដោយដៃ ឬ ដោយបោះឆ្នោតចំហ អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច។ ចំពោះការបោះឆ្នោតដោយលើកដៃ ប្រធាន និង លេខាធិការនៃអង្គប្រជុំជាអ្នករាប់ចំនួនសមាជិក ដែលលើកដៃ ប៉ុន្តែបើការបញ្ចេញមតិដោយលើកដៃនោះ ឃើញថាមិនបានលទ្ធផលច្បាស់លាស់ទេ គឺត្រូវបញ្ចេញមតិ និង រាប់សាជាថ្មីម្តងទៀត។កាលបើការបញ្ចេញមតិដោយលើកដៃបានធ្វើពីរដង ហើយនៅតែមិនទាន់បានលទ្ធផលច្បាស់លាស់នោះទេ ត្រូវប្រើការបញ្ចេញមតិដោយបោះឆ្នោតជាចំហ [29] ។ការបើឆ្នោតជាចំហមានពីរករណី ករណីទីមួយគឺអាជ្ញាសភាកាន់ហិបឆ្នោតដើរទទួលប្រមូលសន្លឹកឆ្នោតពីសមាជិកអង្គប្រជុំ។សមាជិកម្នាក់ៗត្រូវសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតណាមួយក្នុងចំណោមសន្លឹកឆ្នោតទាំងបី ដែលមានពណ៌បីយ៉ាង គឺ ពណ៌សសម្គាល់ថាព្រម ពណ៌ខៀវសម្គាល់ថាមិនព្រម និង ពណ៌សឆ្នូតសម្គាល់ថាអនុប្បវាទ។ករណីទីពីរ វិធីបោះឆ្នោតចំហានៅលើវេទិកា វិធីនេះយកមកប្រើបាន លុះត្រាតែមានសមាជិករដ្ឋសភា ឬ សមាជិក ព្រឹទ្ធសភា ១០ នាក់ យ៉ាងតិចស្នើសុំ។នីតិវិធីនៃការបោះឆ្នោតចំហានៅលើវេទិកា គឺសមាជិកម្នាក់ៗដើរយកសន្លឹកឆ្នោតមកដាក់ក្នុងហិបដែលដាក់នៅលើវេទិកា។ ចំណែកវិធីបោះឆ្នោតដោយសម្ងាត់ ត្រូវតែប្រើក្នុងការជ្រើសតាំង ការសម្តែងការទុកចិត្ត និង ការអនុម័តញត្តិបន្ទោស។ ការអនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញអាចប្រព្រឹត្តដោយវិធីបោះឆ្នោតសម្ងាត់ដែរ។ ការអនុម័តទាំងឡាយត្រូវយកតាមមតិភាគច្រើន ដែលមានកំនត់ក្នុងរដ្ឋធម្មនុញ្ញ ក្រៅពីនេះ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូលត្រូវជាបានការ។ ការបញ្ចេញមតិ បើមានមតិយល់ព្រម និង មិនយល់ព្រមស្មើគ្នាការបោះឆ្នោតត្រូវធ្វើម្តងទៀត បើលទ្ធផលនៃការបោះឆ្នោតលើកទី២នៅតែស្មើគ្នាត្រូវទុកថាមិនយល់ព្រម។ក្រោយពីបោះឆ្នោតរួចស្រេចហើយលេខាធិការរាប់សន្លឹកឆ្នោត ហើយប្រធានជាអ្នកប្រកាសលទ្ធផលជូនសមាជិកនៃសម័យប្រជុំស្តាប់។

[29] ប្រការ៣៨នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ក្រុមប្រឹក្សាធម្មនុញ្ញក៏ពិនិត្យផងដែរអំពីទម្រង់នៃលិខិតស្នើសុំ ឬ អ្នកមានសមត្ថកិច្ចស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញ គឺ ជារៀងរហូតមកដល់ពេលនេះក្រុមប្រឹក្សាធម្មនុញ្ញនៅតែប្រកាន់ខ្ជាប់គោលការណ៍ដែលមានចែងក្នុងមាត្រា១៤០ថ្មី មាត្រា១៤១ថ្មី និង មាត្រា ១៤៣ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ បន្ថែមលើសពីនេះការចុះហត្ថលេខារបស់អ្នកស្នើសុំនោះ គឺតម្រូវឱ្យហត្ថលេខាមានលក្ខណៈដើមទាំងស្រុង មិនមែនជាហត្ថលេខាថតចម្លងឡើយ។នៅក្នុងករណីលិខិតស្នើសុំនេះដែរ ប្រសិនជាមានច្រើនទំព័រ គឺត្រូវមានហត្ថលេខាខ្លីនៅចុងរឹមខាងក្រោមនៃទំព័រនីមួយៗ និង នៅទំព័រចុងបំផុតនៃលិខិតស្នើសុំ គឺ ហត្ថលេខាពេញរបស់អ្នកស្នើសុំ។ប្រការនេះចៀសវាងការប្តឹងពីការក្លែងបន្លំរបស់អ្នកស្នើសុំ[30]។

## កថាខណ្ឌទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិភាល និង បច្ឆាភាល

ការពិនិត្យធម្មនុញ្ញភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញចែកចេញជា៖

### ១.ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិភាល

ក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់អត្ថបទច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង បទបញ្ជាផ្ទៃក្នុង ឬ វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភាត្រូវដាក់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យថា តើអត្ថបទច្បាប់ និង បទបញ្ជាផ្ទៃក្នុងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ។ ក្រៅអំពីអត្ថបទច្បាប់រៀបចំអង្គការបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភាអត្ថបទច្បាប់ស្តីពីការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិនិង ច្បាប់ធម្មតាទូទៅ ក៏អាចត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យផងដែរ។

ដោយឡែកចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើ រដ្ឋធម្មនុញ្ញត្រូវបានព្រះមហាក្សត្រទ្រង់ពិគ្រោះមតិ ជាមួយក្រុមប្រឹក្សាធម្មនុញ្ញជាមុនសិន។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យថា សេចក្តីស្នើធ្វើវិសោធនកម្មមិនប៉ះពាល់ទៅនឹងវាក្យខណ្ឌទីមួយនៃមាត្រា ៧ មាត្រា៨៦ មាត្រា ១៥៣ថ្មី នៃ រដ្ឋធម្មនុញ្ញ។

អ្នកដែលស្នើគឺជាស្ថាប័នដែលមានចែងដោយរដ្ឋធម្មនុញ្ញដូចជាព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិក១/៤ នៃសមាជិកព្រឹទ្ធសភា ឬ សមាជិក១/១០នៃសមាជិករដ្ឋសភា។អ្នកស្នើដូចរៀបរាប់ខាងលើ អាចប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញឱ្យពិនិត្យធម្មនុញ្ញនៃ

[30] សូមមើលលិខិតលេខ០៣/២០០៣ កបធ សជណ ចុះថ្ងៃទី០៥ខែកុម្ភៈ២០០៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

ច្បាប់ ដែលអនុម័តដោយរដ្ឋសភា និង ពិនិត្យចប់សព្វគ្រប់ដោយព្រឹទ្ធសភា មុនពេលប្រកាសឱ្យប្រើ។ប៉ុន្តែបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និង ព្រឹទ្ធសភាក៏ដូចជា ច្បាប់រៀបចំអង្គការមុន នឹងប្រកាសឱ្យប្រើត្រូវតែបញ្ជូនជាដាច់ខាត មកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាព។ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចតបវិញក្នុងរយៈពេល៣០ថ្ងៃ (មាត្រា១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៦ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ) ឬ ក្នុងករណីកិច្ចការប្រញាប់ត្រូវតបវិញក្នុងរយៈពេល៨ថ្ងៃ ( មាត្រា២២ថ្មី នៃច្បាប់ស្ដីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ)។

### ១.១.ការត្រួតពិនិត្យធម្មនុញ្ញភាព ច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ព្រឹទ្ធសភា

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចនៅក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ(ការបង្កើតក្រសួង ស្ថាប័ន) និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា ច្បាប់រៀបចំអង្គការមុននឹងប្រកាសឱ្យប្រើត្រូវដាក់ជូនមកក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញមុននឹងត្រូវបានប្រកាសឱ្យប្រើ[31]។

### ១.២.មតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើសុំធ្វើវិសោធនកម្មច្បាប់

ការកត់សម្គាល់ ការស្នើសុំវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៨ដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភាៈ តាមការកោះអញ្ជើញរបស់ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង នៅថ្ងៃទី១២ និង ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ នៅក្នុងព្រះបរមរាជវាំង ថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជាជនកម្ពុជា និង គណបក្សហ្វុនសិនប៉ិច បានជួបប្រជុំកំពូលក្រោមព្រះរាជធិបតីភាពរបស់ព្រះករុណាអង្គម្ចាស់ជីវិតតម្កល់លើត្បូង។កិច្ចប្រជុំកំពូលនេះបានឈានដល់ការចេញសេចក្ដីប្រកាសមួយ ដោយសម្រេចជាឯកច្ឆន្ទលើគោលការណ៍ចំនួន១០ ចំណុចក្នុងនោះ ចំណុចទីមួយនិយាយអំពីការឯកភាពរបស់គណបក្សទាំងពីរបង្កើតស្ថាប័នព្រឹទ្ធសភា ដោយធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញបច្ចុប្បន្ន និង មានគោលការណ៍សំខាន់ៗ ចំនួន ៨ចំណុច ដែលបានឯកភាពក្នុងការប្រជុំកំពូលមានចែងនៅក្នុង ឧបសម្ព័ន្ធស្ដីពីការបង្កើតស្ថាប័នព្រឹទ្ធសភា[32]។

យោងតាមស្មារតីនៃកិច្ចព្រមព្រៀងរបស់ថ្នាក់ដឹកនាំកំពូលគណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនសិនប៉ិចខាងលើ ឯកឧត្តម **ស ខេង**តំណាងឱ្យតំណាងរាស្ត្រចំនួន៩៦រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ទូលថ្វាយសម្ដេចក្រុមព្រះប្រធានរដ្ឋសភា។កម្មវត្ថុនៃលិខិតគឺ

---

[31] មាត្រា១៦ ច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

[32] ទំព័រទី៩៧ និង ៩៨នៃសៀវភៅ «រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី២ ១៩៩៨ដល់២០០៣»ចងក្រងដោយកាសែតកម្ពុជា ឆ្នាំ១៩៩៩

សេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១២,១៣,១៨,២២,២៤,២៦,២៨,៣០,៣៤,៥១ និង មាត្រាទាំងឡាយនៃជំពូកទី៧ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ។ការស្នើសុំនេះធ្វើឡើងផ្អែកតាមស្មារតីនៃសេចក្តីប្រកាសរួមរវាងគណបក្សទាំងពីរ រដ្ឋសភា នីតិកាលទី២ បានប្រារព្ធសម័យប្រជុំលើកទី១ របស់ខ្លួននៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមអធិបតីភាពឯកឧត្តម **អ៊ឹង គៀត** ជាព្រឹទ្ធសភាសមាជិករដ្ឋសភា ដើម្បីប្រកាសសុពលភាពសមាជិករដ្ឋសភាទាំង ១២២ រូប និង បោះឆ្នោតជ្រើសតាំងប្រធានរដ្ឋសភា អនុប្រធានទី១ និង ទី២ នៃរដ្ឋសភា។ការបោះឆ្នោតជ្រើសតាំងប្រធានរដ្ឋសភា អនុប្រធានទី១ និងទី២ នៃរដ្ឋសភា បានប្រព្រឹត្តទៅដោយឡែកពីគ្នា។សម័យប្រជុំថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ មានកូរ៉ុមចំនួន១១៥រូប។

នៅអំឡុងចុងឆ្នាំ ១៩៩៨ និង ដើមឆ្នាំ១៩៩៩ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាព្រះអង្គទ្រង់បានគង់ព្យាបាលព្រះរោគនៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន សម្តេចក្រុមព្រះ**នរោត្តម រណឬទ្ធិ** ទ្រង់គង់ជាព្រះប្រមុខរដ្ឋស្តីទី[33]។ ដូច្នេះហើយសម្តេច **ហេង សំរិន** ជាប្រធារដ្ឋសភាស្តីទីបានធ្វើលិខិតមួយចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ទូលថ្វាយព្រះករុណាព្រះបាទសម្តេច ព្រះ**នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា អំពីសំណើរបស់តំណាងរាស្ត្រ ៩៦ រូប ដែលពាក់ព័ន្ធនឹងការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ សំដៅបង្កើតស្ថាប័នព្រឹទ្ធសភាឆ្លើយតបទៅនឹងស្មារតីនៃការប្រជុំកំពូលនាថ្ងៃទី ១២ និង ១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាទីសក្ការៈជីវិតតម្កល់លើត្បូង។

ចាប់តាំងពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ រហូតដល់ថ្ងៃទី១៨ ខែធ្នូឆ្នាំ១៩៩៨ ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសារពិគ្រោះមតិ នឹង ក្រុមប្រឹក្សាធម្មនុញ្ញ តាមបទប្បញ្ញត្តិនៃមាត្រា ១៤៣ថ្មី (១២៤ចាស់) នៃរដ្ឋធម្មនុញ្ញឡើយ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ សម្តេច **ហេង សំរិន**ប្រធានរដ្ឋសភាស្តីទី បានផ្ញើលិខិតលេខ៣០ រស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រោយពីពិនិត្យ និង ពិភាក្សាលិខិតលេខ ៣០ រស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើលិខិតទូលថ្វាយទៅព្រះករុណា[34]។

[33] មាត្រា១១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[34] សូមមើលលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញទូលថ្វាយព្រះករុណា និង ព្រះករុណាផ្ញើព្រះរាជសារមកក្រុមប្រឹក្សាធម្មនុញ្ញ នៅឧបសម្ព័នទី២«ឃ»និងទី២«ង»

## ២.ការត្រួតពិនិត្យជាបច្ឆាកាល

ក្រោយពីបានប្រកាសឱ្យប្រើ ច្បាប់ទាំងឡាយអាចដាក់មកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាពដោយអ្នកស្នើសុំជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឬ ដោយតុលាការ។អ្នកស្នើសុំឯកជនក៏អាចប្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យធ្វើការពិនិត្យដូចគ្នានេះបានផងដែរតែត្រូវធ្វើឡើងតាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬ ប្រធានព្រឹទ្ធសភា (មាត្រា១៤១ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនិង មាត្រា១៨ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ)។

ក្រុមប្រឹក្សាធម្មនុញ្ញ ដោយធ្វើការផ្ទៀងផ្ទាត់នូវប្រការនីមួយៗ ដែលពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញដើម្បីពិនិត្យថា តើមានអ្វីស្របនឹងរដ្ឋធម្មនុញ្ញ ។ការពិនិត្យផ្ទៀងផ្ទាត់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាទូទៅពិនិត្យឃើញថា មានប្រការទាំងនោះ គឺមិនប៉ះពាល់ដល់គោលការណ៍នៃ រដ្ឋធម្មនុញ្ញ និង មានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ [35] ។ការពិនិត្យផ្ទៀងផ្ទាត់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាទូទៅពិនិត្យឃើញថា មានប្រការជាច្រើនសុទ្ធសឹងជា ប្រការដែលនិយាយលម្អិតសម្រាប់ការអនុវត្តជាក់ស្ដែង ហើយប្រការទាំងនោះ គឺ មិនប៉ះពាល់ដល់គោលការណ៍នៃរដ្ឋធម្មនុញ្ញឡើយ លើកលែងតែមាត្រា ៤៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មាត្រា១១០ ថ្មី ដែលចែងថា ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភាទទួលញ្ញត្តិច្បាប់ និង សេចក្ដីសម្រេចទាំងឡាយ ដែលព្រឹទ្ធសភាបានអនុម័ត វ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា[36]។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជម្ងឺ ឬ បំពេញមុខងារជាប្រមុខរដ្ឋស្ដីទីឬជាព្រះរាជានុសិទ្ធិ ឬ បំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងជំនួស។

ឯប្រការ ៤៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាបានចែងថា ក្នុងពេលប្រជុំណាមួយ បើប្រធាន និង អនុប្រធានព្រឹទ្ធសភាមិននៅដោយហេតុការណ៍អ្វីជាពិសេស ព្រឹទ្ធសភាអាចជ្រើសតាំងប្រធានបណ្ដោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំបន្ត។

[35] សូមមើលលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញទូលថ្វាយព្រះករុណា និង ព្រះករុណាផ្ញើព្រះរាជសារមកក្រុមប្រឹក្សាធម្មនុញ្ញ នៅឧបសម្ព័ន្ធទី២«ឃ»និងទី២«ង»

[36] សូមអានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ០៤៨កបធ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩ នៅឧបសម្ព័ន្ធទី២«ច»

## កថាខណ្ឌទី៣ អ្នកមានសិទ្ធិស្នើសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាព

យោងតាមមាត្រា ១៤០ថ្មី និង មាត្រា១៤១ថ្មី នៃ រដ្ឋធម្មនុញ្ញ និងមាត្រា១៦ មាត្រា១៧ មាត្រា ១៨ មាត្រា១៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានកំណត់អំពីអ្នកដែលមានសិទ្ធិស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញដែលមាន ៖ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ តុលាការ និង ប្រជាពលរដ្ឋ។ប៉ុន្តែសម្រាប់តុលាការ គឺក្រោយពីច្បាប់ត្រូវបានប្រកាសឱ្យប្រើហើយទើបមានសិទ្ធិស្នើសុំពិនិត្យធម្មនុញ្ញភាព។ ដោយឡែកប្រជាពលរដ្ឋមានសិទ្ធិប្ដឹងពីអធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ (មួយភាគដប់)ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា (មួយភាគបួន) ឬ ប្រធានព្រឹទ្ធសភា។ទន្ទឹមនឹងនេះ ប្រសិនជាប្រជាពលរដ្ឋដែលជាប់ពាក់ព័ន្ធក្នុងរឿងក្ដីណាមួយ ហើយរឿងក្ដីកើតឡើងដល់តុលាការ ប្រជាពលរដ្ឋអាចលើកឡើងប្ដឹងទៅតុលាការអំពីបញ្ហាអធម្មនុញ្ញភាពនៃច្បាប់ ឬ សេចក្ដីសម្រេចរបស់ ស្ថាប័ននានារបស់រដ្ឋ ដូចជា ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង សេចក្ដីសម្រេចរដ្ឋបាលនានា ព្រមទាំងសេចក្ដីសម្រេចរបស់តុលាការផងដែរ។តុលាការថ្នាក់ក្រោមបញ្ជូន បណ្ដឹងទៅតុលាការកំពូល ហើយតុលាការកំពូលជា អ្នកបញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញ បើសិនជាតុលាការកំពូលយល់ឃើញថា មានការសមហេតុផល។បញ្ហានេះ គឺជាករណីបន្ទាន់បង្ខំ ដែលតុលាការទទួលជំនុំជម្រះត្រូវផ្អាកសិន ដោយរង់ចាំចម្លើយរបស់ក្រុមប្រឹក្សា- ធម្មនុញ្ញ។

## ផ្នែកទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន

### កថាខណ្ឌទី១ គោលការណ៍ការត្រួតពិនិត្យធម្មនុញ្ញភាព

នៅប្រទេសជប៉ុន ការត្រួតពិនិត្យធម្មនុញ្ញភាពគឺ មានគោលការណ៍ និងទ្រឹស្តីជាច្រើន មិនមែនគ្រាន់តែមើល ទៅលើអត្ថន័យ ឬក៏ឃ្លានៃអត្ថបទច្បាប់ ថាតើស្របឬ មិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ។ ដូចនេះ ដើម្បីយល់អោយបានច្បាស់ថា តើការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុនគឺមានគោលការណ៍ និងទ្រឹស្តីបែបណាខ្លះនោះ យើងនឹងធ្វើការសិក្សាដូចខាងក្រោម ។

**១. ទ្រឹស្តីទូទៅ** (総説)

គោលការណ៍ជាមូលដ្ឋានក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព គឺធ្វើការវិនិច្ឆ័យទៅលើការកម្រិតសិទ្ធិមនុស្សរបស់អង្គនីតិបញ្ញត្តិ ថាតើស្របតាមរដ្ឋធម្មនុញ្ញ ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញដែរឬទេ ។ ហើយក៏ពិនិត្យវិនិច្ឆ័យទៅលើភាពទាក់ទងគ្នារវាងសកម្មភាពរបស់ច្បាប់ និងគោលបំណងនៃភាពត្រឹមត្រូវរបស់រដ្ឋធម្មនុញ្ញ ក៏ដូចជាភាពទាក់ទងគ្នារវាងគោលដៅនៃការកំណត់ (規制目的) និង វិធាននៃការកំណត់ (規制手段) ថាក្នុងកំរិតណាដែលស្របនឹងរដ្ឋធម្មនុញ្ញ ។ នៅក្នុងភាពទាក់ទងគ្នាទាំងនោះ ថាតើវាមានភាពចាំបាច់ត្រូវតែមានអត្ថន័យយ៉ាងតឹងរឹងខ្លាំង ឬត្រឹមកំរិតល្មមមួយបានល្អ ឬក៏យោងទៅតាមគោលការណ៍មូលដ្ឋានទាំងពីរខាងលើនេះ គឺផ្អែកតាមគោលការណ៍ទាំងនេះ សេចក្តីសន្និដ្ឋានថាតើស្របនឹងរដ្ឋធម្មនុញ្ញ ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញនោះនឹងមានការប្រែប្រួល ។ យោងតាមអត្ថន័យនេះ ទ្រឹស្តីគោលការណ៍មូលដ្ឋានក្នុងការត្រួតពិនិត្យ គឺមានតួនាទីយ៉ាងសំខាន់ផងដែរនៅក្នុងទ្រឹស្តីនីតិវិធីរដ្ឋធម្មនុញ្ញ ។ ក៏ប៉ុន្តែ ទ្រឹស្តីគោលការណ៍មូលដ្ឋាននេះ បើមានទំនាក់ទំនងយ៉ាងជិតស្និទទៅនឹង អត្តចរឹតនៃការចែងកំណត់សិទ្ធិមនុស្ស ឬ បើពិនិត្យមើលពីបញ្ហាដែលត្រូវបានប្រើប្រាស់នៅក្នុងទ្រឹស្តីសិទ្ធិមនុស្សនោះ នឹងបញ្ឈប់ ហើយត្រូវការការបកស្រាយនូវការសង្ខេបរបស់វា [37]។

**២ .គោលការណ៍សន្មត់ថាស្របនឹងរដ្ឋធម្មនុញ្ញ** (合憲性推定の原則)

នៅក្នុងអំណាចនីតិបញ្ញត្តិ ច្បាប់ទាំងអស់តាក់តែងដោយឆ្លងកាត់សភា ហើយក្រោយសភាពិនិត្យថា ច្បាប់នោះស្របនឹងរដ្ឋធម្មនុញ្ញរួចច្បាប់នោះនឹងត្រូវបានអនុម័ត ហើយដាក់ឱ្យប្រើប្រាស់ ។ ជាទូទៅ នៅក្នុងដំណាក់កាលនេះ គឺទទួលការវិនិច្ឆ័យថា ស្របនឹងរដ្ឋធម្មនុញ្ញ ។ ប្រសិនបើទទួលយកគោលការណ៍នេះ ការដែលសន្មត់ថាអធម្មនុញ្ញភាពនៃច្បាប់ គឺនឹងលេចចេញនូវគោលគំនិតថាអធម្មនុញ្ញភាពនៃច្បាប់នេះ មាននៅក្នុងករណីដែលត្រូវបានច្រានចោលនូវការបញ្ជាក់ភស្តុតាងនៃ

[37] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）306 頁
តុស៊ីហិកុ ណូណាកា ផ្សេងៗ 『រដ្ឋធម្មនុញ្ញ II【បោះពុម្ពលើកទី ៤】』 (រោងពុម្ព យីហ៊ីកាកុ, ឆ្នាំ ២០១០) ទំព័រ ៣០៦

ការកំណត់ធម្មនុញ្ញភាព ។ នៅក្នុងគោលគំនិតនេះ បានទទួលស្គាល់ផ្នត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ(立法裁量)យ៉ាងទូលាយ ក្នុងករណីគ្រាន់តែកំរិតនៃការចែងជាក់លាក់មួយ គឺអាចអភិវឌ្ឍន៍ការគិតនោះ អាចក្លាយទៅជាអធម្មនុញ្ញ ហើយគោលការណ៍ដែលវាស់ពីកម្រិតរបស់ផ្នត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ(立法裁量)គឺគោលការណ៍តម្លាភាព「明白性の原則」។ ពោលគឺជាគោលការណ៍ដែលគួរប្រើក្នុងការតាក់តែងច្បាប់ ក្នុងករណីច្បាស់លាស់អំពីភាពមិនសមស្របយ៉ាងគួរអោយកត់សំគាល់ ប្រសិនបើផ្នត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ(立法裁量)ហួសពីព្រំដែនកំណត់ គឺអាចសន្មត់ថាអធម្មនុញ្ញ ។ គោលគំនិតដូចដែលបានរៀបរាប់ខាងលើនេះ នៅក្នុងការអនុវត្តជាក់ស្តែងរបស់ប្រទេសជប៉ុន ជាគោលការណ៍ដែលបានចាក់គ្រឹះយ៉ាងរឹងមាំរហូតមកដល់ពេលបច្ចុប្បន្ន ហើយក៏ត្រូវបានសន្មត់ថានៅតែមានឥទ្ធិពល ។ ក៏ប៉ុន្តែ យោងតាមទ្រឹស្តីដ៏ល្បីមួយលោកអាស៊ីបេ（芦部・理論 251 頁以下）បានអះអាងថាគោលការណ៍ថាស្របនឹងរដ្ឋធម្មនុញ្ញ「合憲性推定の原則」គឺដោយសារត្រូវបានប្រើប្រាស់ទាក់ទងនឹងសេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច(経済的自由規制)យ៉ាងសំខាន់ ត្រូវតែសន្មតថាជាគោលការណ៍ដែលត្រូវប្រើប្រាស់ជាទូទៅនូវគោលការណ៍នៃការបង្កើតច្បាប់ទាក់ទងនឹងសិទ្ធិមនុស្ស(人権規制立法)ទាំងមូល ។ ពោលគឺទាក់ទងនឹងសេចក្តីកំណត់សេរីភាពខាងផ្លូវចិត្ត (精神的自由規制立法) ហើយដែលកំណត់នៃការប្រើប្រាស់វាផងដែរ គឺគួរតែបំពេញតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និង បង្ហាញភស្តុតាងបញ្ជាក់គោលការណ៍នៅក្នុងការបង្កើតច្បាប់(立法事実)ផងដែរ [38]។

### ៣. ទ្រឹស្តីមូលដ្ឋានពីរត្រួតគ្នា（「二重の基準」論）

ទ្រឹស្តីមូលដ្ឋានពីរត្រួតគ្នា（「二重の基準」論）គឺជាគោលគំនិតដែលផ្តល់អត្ថិភាពដល់ការពិនិត្យធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងផ្លូវចិត្ត（精神的自由規制）ត្រូវពិនិត្យយ៉ាងតឹងរឹង ដែលផ្ទុយទៅវិញចំពោះការពិនិត្យធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制）វិញ គឺគ្រាន់តែពិនិត្យយ៉ាងធូរស្រាលជាងសេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងផ្លូវចិត្ត（精神的自由規制立法）។ ដូចនេះ ការពិនិត្យវិនិច្ឆ័យពីធម្មនុញ្ញភាពដែលផ្ទុយចំពោះការពិនិត្យធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制）គឺជាដំណើរការទៅមុន ក៏ប៉ុន្តែការពិនិត្យវិនិច្ឆ័យពីធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងផ្លូវចិត្ត（精神的自由規制）មិនសូវដំណើរការ ផ្ទុយទៅវិញបែរជាមានលេចចេញនូវគោលគំនិតថា សន្មត់ទុកជាមុនថាអធម្មនុញ្ញភាពទៅវិញ ។ ក៏ប៉ុន្តែទ្រឹស្តីនេះ គឺអាចលើកឡើងនូវចំណុចបញ្ហាចំពោះ ចំនុចមិនគួរមានភាពខុសគ្នានូវមូលដ្ឋានត្រួតពិនិត្យតាមរយៈទម្រង់នៃ

---

[38] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）306 頁
តុស៊ីហិកុ ណុណាកា ផ្សេងៗ『រដ្ឋធម្មនុញ្ញ Ⅱ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហ៊ីកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៦

ការធ្វើច្បាប់ ឬក៏ ចំនុចបញ្ហានៃការបំបែកជាពីរនូវសិទ្ធិមនុស្សជាច្រើនប្រភេទ គឺមានភាពមិនសមស្របជាដើម ។ ឧទាហរណ៍ដូចជា មានការអះអាងថា បើទោះបីជាក្នុងករណីសេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងសេដ្ឋកិច្ច (経済的自由規制立法) ក៏ដោយ ការចែងគោលបំណងយ៉ាងវិជ្ជមាន និង ការចែងគោលបំណងអវិជ្ជមាន គឺគួរតែមានការបែងចែកអំពីការទាក់ទងគ្នានៃអង្គនីតិបញ្ញត្តិ ដែលជា គោលការណ៍សមភាពនៃសិទ្ធិរស់រានមានជីវិត គួរតែមានគោលការណ៍មូលដ្ឋាននៅឈរកណ្តាលនៃគោលគំនិតទាំងពីរនេះ ។ តុលាការកំពូលប្រទេសជប៉ុន ឆ្លើយតបទៅនឹងស្ថានភាពនៃទ្រឹស្តីនេះ ទាក់ទងនឹងដែលផ្ទុយទៅវិញចំពោះការពិនិត្យធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច (経済的自由規制) បានចេញសេចក្តីសម្រេចយ៉ាងច្បាស់អំពីមូលដ្ឋានត្រួតពិនិត្យ ដែលខុសពីករណីសេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងផ្លូវចិត្ត (精神的自由規制) ។ ផ្ទុយទៅវិញ ទាក់ទងនឹងភាពចាំបាច់របស់សេចក្តីកំណត់អំពីនីតិកម្មនៃសេរីភាពខាងផ្លូវចិត្ត (精神的自由規制) មិនធ្លាប់មានសេចក្តីសម្រេចណាបញ្ជាក់យ៉ាងច្បាស់ពីការដែលគួរតែ យកមូលដ្ឋានត្រួតពិនិត្យយ៉ាងតឹងរ៉ឹងនោះឡើយ [39]។

## ៤. គោលការណ៍មូលដ្ឋានត្រួតពិនិត្យរបស់ទ្រឹស្តីផ្សេងៗ

ទាក់ទងនឹងមូលដ្ឋានត្រួតពិនិត្យ គឺមានគម្លាតរវាងយុទ្ធសាស្ត្រ និង ទ្រឹស្តី ហើយនៅក្នុងទ្រឹស្តី ក៏មានទ្រឹស្តីជាច្រើនដែរ ។

### ៤. ១.សេចក្តីកំណត់យ៉ាងទូលំទូលាយពេក និង ការទប់ស្កាត់ទុកជាមុន

(事前抑制・過度に広汎な規制)

សេចក្តីកំណត់យ៉ាងទូលំទូលាយពេក និង ការទប់ស្កាត់ទុកជាមុន (事前抑制・過度に広汎な規制) គឺជាសេចក្តីកំណត់ដែលគ្របដណ្តប់ទៅលើសេរីភាពបញ្ចេញមតិ ពោលគឺជា 萎縮効果 (Chilling Effect) ហើយជាធម្មតា គឺមិនមានការត្រួតពិនិត្យរបស់គោលការណ៍បរិបទជាក់ស្តែងក្នុងការបង្កើតច្បាប់ (立法事実) ហើយអាចចេញសេចក្តីសម្រេចវិនិច្ឆ័យអធម្មនុញ្ញភាពនៃច្បាប់ ដោយគ្រាន់តែត្រួតពិនិត្យអត្ថបទច្បាប់ប៉ុណ្ណោះ[40] ។

[39] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）307 頁
តុស៊ីហិកុ ណូណាកា ផ្សេងៗ『រដ្ឋធម្មនុញ្ញ Ⅱ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហ៊ីកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៧

[40] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）308 頁
តុស៊ិហិកុ ណូណាកា ផ្សេងៗ『រដ្ឋធម្មនុញ្ញ Ⅱ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហ៊ិកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៨

### ៤. ២.សេចក្តីកំណត់អត្ថន័យបញ្ចេញមតិ（表現内容の規制）

សេចក្តីកំណត់អត្ថន័យបញ្ចេញមតិ（表現内容の規制） គឺជាសេចក្តីកំណត់ដែលចាំបាច់ក្នុងការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុត ។ មូលដ្ឋានត្រួតពិនិត្យនេះ គឺស័ក្តិសមជាមួយមូលដ្ឋាននៃភាពច្បាស់លាស់និងបច្ចុប្បន្នភាពនៃហានិភ័យ（「明白かつ現在の危険」の基準）បំផុត ។ សកម្មភាពបញ្ចេញមតិ គឺក្នុងករណីដែលគ្រោះថ្នាក់កើតឡើង ចេញនូវការខូចខាតជាក់ស្តែងយ៉ាងអាក្រក់ជិតត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ សេចក្តីកំណត់នេះគឺគួរតែត្រូវវិនិច្ឆ័យថាអធម្មនុញ្ញភាព ។ ទន្ទឹមនឹងនេះ ការលើកឡើងអំពីលក្ខណៈនៃភេទចំពោះបុគ្គល 性表現( Sex Expression) ឬ ការបញ្ចេញមតិដែលប៉ះពាល់ដល់បរិហាកេរ្តិ៍ក៏មានភាពចាំបាច់ពិនិត្យយ៉ាងតឹងរឹងដែរ [41]។

### ៤. ៣.សេចក្តីកំណត់ពីពេលវេលា ទីកន្លែង វិធីសាស្ត្រនៃការបញ្ចេញមតិ（表現の　時・所・方法の規制）

សេចក្តីកំណត់ពីពេលវេលា ទីកន្លែង វិធីសាស្ត្រនៃការបញ្ចេញមតិ（表現の時・所・方法の規制） គឺជាវិធាននៃការកំណត់បែបប្រៀបធៀបយ៉ាងងាយស្រួល មិនសូវតឹងរឹង ក៏ប៉ុន្តែ បច្ចុប្បន្នសេចក្តីកំណត់អំពីការបញ្ចេញមតិ（表現規制）ជាច្រើន គឺមានទម្រង់បែបនេះជាច្រើន ដូចនេះត្រូវបានទាមទារអោយមានការត្រួតពិនិត្យយ៉ាងតឹងរឹង ។ មូលដ្ឋានត្រួតពិនិត្យដែលតំណាងការត្រួតពិនិត្យនេះគឺគោលការណ៍បន្ធូរបន្ថយនៃការត្រួតពិនិត្យតឹងរ៉ឹង「LRA(Less Restrictive Alternatives)の基準」ដែលជាការត្រួតពិនិត្យវិនិច្ឆ័យថាតើស្របនឹងរដ្ឋធម្មនុញ្ញ ឬ អធម្មនុញ្ញ ដោយយោងតាមការត្រួតពិនិត្យជាក់ស្តែងលើ ដំណាក់កាលមាន ឬ មិនមានភាពត្រឹមត្រូវ ដែលទាក់ទងនឹងការកម្រិតយ៉ាងតិចបំផុតស្របពេលតែមួយ និង អាចជាគោលបំណងនៃការបង្កើតច្បាប់អោយមានប្រសិទ្ធិភាព ។ មិនថាក្នុងករណីណាក៏ដោយ ដូចដែលបានរៀបរាប់ខាងលើ គឺមិនអាចសន្មតថាមានភាពស្របនឹងរដ្ឋធម្មនុញ្ញឡើយ[42] ។

### ៤. ៤.សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制）

បន្តមកទៀតគឺជា សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制） ហើយវាត្រូវបានបែងចែកជា សេចក្តីកំណត់គោលបំណងបែបវិជ្ជមាន (積極目的の規制) និង សេចក្តីកំណត់គោលបំណងបែបអវិជ្ជមាន(消極目的の規制) ។ សេចក្តីកំណត់ទាំងនេះ មិនថាក្នុងករណីណាក៏ដោយ អាចសន្មតថាមានភាពស្របនឹងរដ្ឋធម្មនុញ្ញ ។ ដំបូងគឺករណីសេចក្តីកំណត់គោលបំណងបែប

---

[41] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）308 頁
គុស៊ីហិកុ ណុណាកា ផ្សេងៗ 『រដ្ឋធម្មនុញ្ញⅡ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហ៊ីកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៨

[42] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）309 頁
គុស៊ិហិកុ ណុណាកា ផ្សេងៗ 『រដ្ឋធម្មនុញ្ញⅡ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហ៊ីកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៩

វិជ្ជមាន (積極目的の規制) គឺធ្វើការត្រួតពិនិត្យវិនិច្ឆ័យតាមរយៈគោលការណ៍នៃភាពសមហេតុផល 「合理性の基準」( Standard of Reasonableness ) ។ ពោលគឺ ធ្វើការទទួលយកយ៉ាងទូលាយនូវផ្នត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ（立法裁量）ដែលទាក់ទងនឹងគោលបំណងក្នុងការធ្វើច្បាប់ និង នីតិវិធីនៃការធ្វើច្បាប់ ហើយនៅពេលដែលសេចក្តីកំណត់ចូលទៅក្នុងដែនកំណត់របស់ផ្នត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ（立法裁量）ហើយអាចវិនិច្ឆ័យថាអធម្មនុញ្ញភាពបាន ក្នុងករណីដែលមានភាពសមស្របយ៉ាងគួរអោយកត់សំគាល់ខ្លាំង ។ ផ្ទុយទៅវិញ ករណីសេចក្តីកំណត់គោលបំណងបែបអវិជ្ជមាន(消極目的の規制) វិញគឺធ្វើការត្រួតពិនិត្យវិនិច្ឆ័យតាមរយៈសេចក្តីកំណត់នៃភាពស្របគ្នាយ៉ាងតឹងរ៉ឹង(厳格な合理性の規制) ។ ពោលគឺ ក្រៅពីការត្រួតពិនិត្យភាពត្រឹមត្រូវរបស់គោលបំណងក្នុងការធ្វើច្បាប់ គឺត្រួតពិនិត្យថាតើមានភាពទាក់ទងគ្នាពិតប្រាកដនៃភាពជាក់ស្តែងទៅលើភាពទាក់ទងនឹងការស្របគ្នារវាងគោលបំណងក្នុងការធ្វើច្បាប់ និង នីតិវិធីនៃការធ្វើច្បាប់ ឬយ៉ាងណា ប្រសិនបើមិនមានទំនាក់ទំនងគ្នាដូចខាងលើនេះទេ គឺត្រូវសន្មតថា អធម្មនុញ្ញភាព [43]។

### ៤. ៥.មូលដ្ឋានត្រួតពិនិត្យផ្អែកលើយុទ្ធសាស្ត្រសាលដីការបស់តុលាការកំពូល（判例における審査基準）

នៅក្នុងសាលដីកាពីដំបូង នៅពេលនោះ ដោយសារតែមិនមានទ្រឹស្តីនីតិវិធីរដ្ឋធម្មនុញ្ញ និងមានផ្នែកជាច្រើនដែរ ដែលមិនទាន់អភិវឌ្ឍន៍ នោះគឺត្រូវបានបញ្ចប់ដោយនីតិវិធីត្រួតពិនិត្យដែលមានអត្ថន័យថា 「យោងតាមសុខមាលភាពសាធារណៈ ការកំណត់ក្នុងកំរិតនេះ គឺត្រូវលើកលែង（公共の福祉に照らし、この程度の規制は許される。）」 ។ ក្រោយមក តុលាការកំពូលប្រទេសជប៉ុន បានពិចារណាលើទ្រឹស្តីមូលដ្ឋានត្រួតពិនិត្យជាបន្តបន្ទាប់ ហើយក៏បានចង្អុលបង្ហាញឱ្យយល់អំពីទ្រឹស្តីមូលដ្ឋានពីរត្រួតគ្នា（「二重の基準」）នៅក្នុងសាលដីកា ។ ប៉ុន្តែ ទ្រឹស្តីមូលដ្ឋានត្រួតពិនិត្យដែលត្រូវលើកយកមកប្រើប្រាស់នៅ ក្នុងសាលដីការបស់តុលាការកំពូលប្រទេសជប៉ុន គឺបានផ្លាស់ប្តូររូបរាងទៅសង្កត់ធ្ងន់លើប្រភេទរបស់សេចក្តីកំណត់ ជាជាងការកំណត់ ដែលផ្តោតទៅលើសារធាតុរបស់សិទ្ធិ និង សិទ្ធិសេរីភាព ។ ពោលគឺ តុលាការកំពូលប្រទេសជប៉ុន គឺចាប់ផ្តើមការគិតពីចំនុចដែលត្រួតពិនិត្យយ៉ាងតឹងរ៉ឹងទៅលើដែលផ្ទុយទៅវិញ ចំពោះការពិនិត្យធម្មនុញ្ញភាពរបស់សេចក្តីកំណត់អំពីសេរីភាពខាងសេដ្ឋកិច្ច（経済的自由規制）ជាជាងសេចក្តីកំណត់អំពីនីតិ

---

[43] 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）309 頁
តុស៊ិហិកុ ណុណាកា ផ្សេងៗ『រដ្ឋធម្មនុញ្ញ II【បោះពុម្ពលើកទី ៤】』（រោងពុម្ព យ៉ឺហិកាកុ、ឆ្នាំ ២០១០）ទំព័រ ៣០៩

កម្មនៃសេរីភាពខាងផ្លូវចិត្ត (精神的自由規制) ហើយបន្ទាប់មកក៏ទទួលយកទ្រឹស្តីផ្សេងៗ យកមកពិចារណា និង ធ្វើជាគោលការណ៍មូលដ្ឋានក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព [44]។

## កថាខណ្ឌទី២ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល និង បច្ឆាកាល

### ១.ការត្រួតពិនិត្យជាអាទិកាល

ការត្រួតជាអាទិកាលជាការពិនិត្យនូវសេចក្តីព្រាងច្បាប់ដែលស្ថាប័នប្រតិបត្តិពោលគឺសេចក្តីព្រាងច្បាប់ដែលចេញមកពីគណៈរដ្ឋមន្ត្រីដាក់ស្នើទៅអោយស្ថាប័ននីតិបញ្ញត្តិ (រដ្ឋសភា និង ព្រឹទ្ធសភា)ដើម្បីពិនិត្យ មុនពេលអនុម័តសេចក្តីព្រាងនោះ ដាក់ឱ្យប្រើប្រាស់ស្ថាប័ននីតិបញ្ញត្តិនេះក៏មានតួនាទីពិនិត្យ សេចក្តីព្រាងច្បាប់នោះថា តើមានចំណុចណាដែលប៉ះពាល់ផលប្រយោជន៍ប្រទេសជាតិ ឬ ប្រជាជនដែរឬទេ ហើយមានបញ្ញត្តិណាផ្ទុយជាមួយនឹងបទបញ្ញត្តិណាមួយឬខុសពីស្មារតីរបស់រដ្ឋធម្មនុញ្ញផងដែរ។ដើម្បីយល់ឱ្យកាន់តែស៊ីជម្រៅអំពីនីតិវិធីត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាលនៅប្រទេសជប៉ុនប្រព្រឹត្តទៅបែបណានោះ យើងនឹងធ្វើការសិក្សាដូចខាងក្រោម។

#### ១.១.ការត្រួតពិនិត្យធម្មនុញ្ញភាព ដោយស្ថាប័ននីតិប្រតិបត្តិ

នៅក្នុងនីតិវិធីបង្កើតសេចក្តីព្រាងច្បាប់របស់ប្រទេសជប៉ុនគឺមានច្រើនដំណាក់កាល ហើយវាស្មុគស្មាញដោយសារតែខាងស្ថាប័ននីតិប្រតិបត្តិចង់បង្កើតសេចក្តីព្រាងច្បាប់ដែលឥតខ្ចោះ មិនចង់ឱ្យមានបញ្ហា ឬការកែប្រែក្រោយពេលដែលខ្លួនដាក់ស្នើទៅស្ថាប័នបញ្ញត្តិពិនិត្យ និង អនុម័តឡើយ។

សេចក្តីព្រាងច្បាប់ដំបូង ត្រូវបានធ្វើឡើងដោយនាយកដ្ឋាននីតិកម្មរបស់ក្រសួងនីមួយៗ។ ការធ្វើសេចក្តីព្រាងច្បាប់ទាំងនេះគឺធ្វើឡើងតាមការទាមទាររបស់ក្រុមសង្គមស៊ីវិល ក្រុមដែលទទួលបានផលផលប្រយោជន៍ ឬ ក៏អ្នកនយោបាយមួយរូបៗរបស់គណបក្សដែលកាន់អំណាច ឬគណៈបក្សប្រឆាំង។ដើម្បីធ្វើសេចក្តីព្រាងច្បាប់នោះបាន ក្រសួងសាមីត្រូវបង្កើតក្រុមអ្នកស្រាវជ្រាវ ឬ កិច្ចប្រជុំពិនិត្យ ដើម្បីធ្វើសេចក្តីព្រាង។ ផ្ទុយទៅវិញទោះបីជានាយកដ្ឋានរបស់ក្រសួងនីមួយៗបង្កើតសេចក្តីព្រាងច្រើនក៏ពិតមែនក៏ប៉ុន្តែមិនមែនសុទ្ធតែអាចដាក់ចេញជាលទ្ធផលបានឡើយ ដោយសារតែកញ្ចប់ថវិកា ឬចំនួនសមាជិកដែលចូលរួមបង្កើតមានកម្រិត។ដូចនេះក្រសួងនីមួយៗជ្រើសយក

44 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）309 頁
គុស៊ីហិកុ ណុណាកា ផ្សេងៗ 『រដ្ឋធម្មនុញ្ញ II 【បោះពុម្ពលើកទី ៤】』 (រោងពុម្ព យឺហិកាកុ، ឆ្នាំ ២០១០) ទំព័រ ៣០៩

តែសេចក្តីព្រាងច្បាប់ណាដែលទទួលបានការវាយតម្លៃខ្ពស់ និងជាសេចក្តីព្រាងដែលមានអត្ថិភាពនៅក្នុងក្រសួង[45]។

បន្ទាប់ពីសម្រេចជ្រើសរើសសេចក្តីព្រាងច្បាប់រួច ក្រសួងសាមីនោះនឹងបើកកិច្ចប្រជុំពិភាក្សាទទួលមតិយោបល់ ក៏ដូចជាការចង្អុល បង្ហាញពីក្រសួងផ្សេងៗទាំងអស់ចំពោះការតាក់តែងសេចក្តីព្រាងច្បាប់របស់ក្រសួងសាមីនោះ ។ចំណុចពិសេសនៅត្រង់នេះ គឺ ចំណុចដែលក្រសួងសាមីកែតម្រូវ រហូតដល់អស់មតិយោបល់ក្នុងការប្រឆាំងទៅនឹងសេចក្តីព្រាងច្បាប់នោះ មិនថា ពីក្រសួងទាំងអស់ជួបពិភាក្សាគ្នា និង ក្រសួងដែលពាក់ព័ន្ធនោះទេ ទោះបីជាក្រសួងដែលមិនពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់នេះក៏ត្រូវចូលរួមផ្តល់យោបល់និងទទួលស្គាល់ទាំងអស់។សំនួរសួរថា តើហេតុអ្វីបានជាប្រព័ន្ធរបស់ប្រទេសជប៉ុន ត្រូវតែត្រួតពិនិត្យម៉ត់ចត់ខ្លាំងបែបនេះ?អ្នកទាំងអស់គ្នាប្រហែលជាគិតថាមូលហេតុនោះ តើអាចមកពីវប្បធម៌ជប៉ុន ក៏ប៉ុន្តែមូលហេតុដែលសំខាន់បំផុតនោះគឺដោយសារតែនៅក្នុងកិច្ចប្រជុំគណរដ្ឋមន្ត្រី ការបង្កើតសេចក្តីព្រាងច្បាប់នោះ គឺចាំបាច់ត្រូវតែមានការប្រជុំសម្រេចគាំទ្រទាំងស្រុង ពីសមាជិកនៃអង្គប្រជុំគណរដ្ឋមន្ត្រី។នេះគឺ ដោយសារតែនៅពេលដែលមានបញ្ហាកើតឡើង គណៈរដ្ឋមន្ត្រីទាំងមូលត្រូវប្រឈមមុខនឹងការទទួលខុសត្រូវចំពោះមុខសភាទាំងពីរ ហើយចំពោះផ្នែកផ្ទៃក្នុងរបស់គណៈរដ្ឋមន្ត្រី គឺមានគោលគំនិតតាំងពីដើមមកថាមិនអាចមានគំនិតគោលបំណងមិនឯកភាពគ្នាសោះឡើយ។ បន្តមកទៀតនៅមុនថ្ងៃប្រជុំគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រីនៃក្រសួងនីមួយៗបានបើកកិច្ចប្រជុំពិភាក្សា និងពិនិត្យទៅលើសេចក្តីព្រាងច្បាប់និងដាក់ជូនទៅកិច្ចប្រជុំគណៈរដ្ឋមន្ត្រីទុកមុនថ្ងៃដាក់ទៅកិច្ចប្រជុំគណៈរដ្ឋមន្ត្រី។គោលបំនងក្នុងការធ្វើបែបនេះគឺការពារកុំឱ្យលេចឡើង នូវមតិប្រឆាំងភ្លាមៗនៅក្នុងកិច្ចប្រជុំ ដូច្នេះគោលការណ៍នៃការគាំទ្រទាំងស្រុងគឺមានភាពចាំបាច់នៅក្នុងការអនុម័តនីតិវិធីនេះ។ ប្រសិនបើយើងក្រឡេកមើលការត្រួតពិនិត្យធម្មនុញ្ញភាពវិញ នៅក្នុងដំណាក់កាលនេះប្រាកដណាស់ថាយើងអាចសន្មតថាក្រសួងសាមីគាត់បានពិនិត្យនិងកែតម្រូវយ៉ាងល្អិតល្អន់ ដើម្បីកុំឱ្យបទបញ្ញត្តិ ឬមាត្រាណាមួយផ្ទុយទៅនឹងរដ្ឋធម្មនុញនៅពេលដែលដាក់ជូនទៅកិច្ចប្រជុំគណរដ្ឋមន្ត្រី ក្រោយពីត្រួតពិនិត្យយ៉ាងល្អិតល្អន់ ហើយសេចក្តីព្រាងនោះត្រូវបញ្ជូនទៅឱ្យគណៈរដ្ឋមន្ត្រីពិនិត្យបន្ថែមពីលើម្តងទៀត។ការត្រួតពិនិត្យសេចក្តីព្រាងច្បាប់របស់គណៈរដ្ឋមន្ត្រី សេចក្តីព្រាងសារាចរ សេចក្តីព្រាងសន្ធិសញ្ញាជាដើម គឺត្រូវត្រួតពិនិត្យដោយនាយកដ្ឋាននីតិកម្មរបស់គណៈរដ្ឋមន្ត្រីជាមុនសិន។លើសពីនេះទៅទៀត ក្នុងករណី

---

[45]名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）、（Flight S403）196 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』 (ភាសាខ្មែរ)(ខែកញ្ញា ឆ្នាំ ២០១៣) ទំព័រ ១៩៦

មានសំណួរទាក់ទងនឹងច្បាប់ក្រសួងនីមួយៗ ឬ គណៈរដ្ឋមន្ត្រីនាយកដ្ឋាននេះនឹងធ្វើការប្រមូលសំណួរ និងបកស្រាយនូវសំណួរក៏ដូចជាអត្ថបទច្បាប់[46]។

ពោលគឺនាយកដ្ឋាននេះត្រួតពិនិត្យលើអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ លិខិតបទដ្ឋាននានា បើមានមន្ត្រីរដ្ឋាភិបាលណាមួយមិនយល់ពីអត្ថន័យនៃច្បាប់ គឺអាចសួរទៅនាយកដ្ឋាននីតិកម្មនេះឱ្យជួយបកស្រាយឱ្យបាន។ប្រសិនបើនិយាយពីការត្រួតពិនិត្យធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់ ឬ លិខិតបទដ្ឋាននានា នាយកដ្ឋាននេះក៏ត្រួតពិនិត្យយ៉ាងល្អិតល្អន់ផងដែរ ថាតើមានចំណុចណាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញដែរឬទេ ឬ មានផ្ទុយជាមួយច្បាប់ដទៃទៀតដែរឬយ៉ាងណាផងដែរ។ការដែលត្រួតពិនិត្យយ៉ាងល្អិតល្អន់បែបនេះ ក៏ព្រោះតែដូចដែលបាន រៀបរាប់នៅក្នុងដំណាក់កាលក្រសួងគឺនីតិប្រតិបត្តិមានគោលការណ៍ ដែលត្រូវត្រួតពិនិត្យសេចក្តីព្រាងច្បាប់ក៏ដូចជាលិខិតបទដ្ឋានឱ្យម៉ត់ចត់បំផុតដើម្បីកុំឱ្យមានមតិប្រឆាំងកើតមានឡើងនៅពេលដែលដាក់ជូនសភាត្រួតពិនិត្យ និង អនុម័តឱ្យមានការប្រើប្រាស់។

## ១.២.ការត្រួតពិនិត្យធម្មនុញ្ញភាព ដោយស្ថាប័ននីតិបញ្ញត្តិ

បន្ទាប់ពីបានស្វែងយល់សិក្សាអំពីដំណាក់កាលនៃការត្រួតពិនិត្យធម្មនុញ្ញភាពដោយស្ថាប័ននីតិប្រតិបត្តិរួចមក ចំណុចយើងនឹងធ្វើការសិក្សាស្វែងយល់ពីការត្រួតពិនិត្យធម្មនុញ្ញភាពដោយស្ថាប័ននីតិបញ្ញត្តិថាតើក្នុងដំណាក់កាលនេះគេធ្វើការត្រួតពិនិត្យយ៉ាងដូចម្តេច? ក្រោយពីបានទទួលការដាក់ជូននូវសេចក្តីព្រាងច្បាប់ស្តីពីគណៈរដ្ឋមន្ត្រី ឬ ពីសមាជិកសភា ឆ្លងតាមការបោះឆ្នោតគាំទ្រសម្រេចតាម សម្លេងមួយដែលបានកំណត់រួចមក មិនថានៅក្នុងដំណាក់កាលរដ្ឋសភា ឬ ព្រឹទ្ធសភានោះឡើយគឺ នឹងត្រូវអនុវត្តនូវវិធី ដូចបន្តមកទៀតនេះ។ ជាដំបូងនៅការប្រជុំដំបូងនៃគណៈកម្មការអចិន្ត្រៃយ៍មានបើកការពន្យល់ណែនាំអំពីសេចក្តីព្រាងច្បាប់។ បន្តមកទៀត ប្រធានសភា(រដ្ឋសភា និង ព្រឹទ្ធសភា)ប្រគល់អំណាច និងតួនាទីទៅឱ្យគណៈកម្មការមួយដើម្បីត្រួតពិនិត្យនូវសេចក្តីព្រាងច្បាប់នោះ។ ការប្រជុំត្រួតពិនិត្យយ៉ាងល្អិតល្អន់នឹង ត្រូវធ្វើឡើងដោយគណៈកម្មការនេះហើយប្រធានគណៈកម្មការនេះ នឹងធ្វើរបាយការណ៍រាយការណ៍ អំពីលទ្ធផលនៃការត្រួតពិនិត្យសចក្តីព្រាងច្បាប់នោះ។បន្ទាប់មកក្រោយពីស្តាប់លទ្ធផលនៃការត្រួតពិនិត្យរួចនៅគណៈកម្មការអចិន្ត្រៃយ៍នឹងមានការបើកកិច្ចប្រជុំទទួលនូវសំណួរនិងមតិកែតម្រូវពីសមាជិកសភាទាំងអស់[47]។

---

[46] 名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）、（Flight S403）196-197 頁
មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ)(ខែកញ្ញា ឆ្នាំ ២០១៣) ទំព័រ ១៩៦ និង ១៩៧

[47] 名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）、（Flight S401）171 頁

ក្រោយពីជជែកវែកញែកនូវអត្ថបទ និង អត្ថន័យនៃសេចក្តីព្រាងច្បាប់រួច សភានឹងធ្វើការអនុម័ត សេចក្តីព្រាងច្បាប់នោះ។ជាទូទៅនៅពេលអនុវត្តជាក់ស្តែងគេមិនសូវមានការបើកទទួលសំណួរឬមតិយោបល់នៅគណកម្មការអចិន្ត្រៃយ៍នោះទេ ដោយសារសមាជិកសភាជឿជាក់ទៅលើការត្រួតពិនិត្យយ៉ាងម៉ត់ចត់របស់គណៈកម្មការដែលបានទទួលភារកិច្ច និង ត្រួតពិនិត្យសេចក្តីព្រាងច្បាប់នោះ។ម្យ៉ាងវិញទៀត នៅក្នុងដំណាក់កាលគណកម្មការនោះដោយសារតែមិនមានការបើកជាសាធារណៈទើបធ្វើឱ្យគណៈកម្មការនោះអាចជជែកគ្នាយ៉ាងល្អិតល្អន់ទៅលើសេចក្តីព្រាងច្បាប់នោះល្អជាងនៅដំណាក់កាលទទួលសំណួរ និង មតិយោបល់នៅគណៈកម្មការអចិន្ត្រៃយ៍ដែលត្រូវបើកចំហជាសាធារណៈ ជាហេតុធ្វើឱ្យមានការពិបាកដែលធ្វើការសួរសំណួរឬផ្តល់ជាមតិយោបល់ដែលទាក់ទងទៅនឹងពត៌មានសម្ងាត់របស់នយោបាយ ឬ ផ្នែកការទូតជាដើម។

ប្រសិនបើក្រឡេកទៅមើលការត្រួតពិនិត្យធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់វិញ គឺនៅក្នុងដំណាក់កាលស្ថាប័ននីតិបញ្ញត្តិក៏បានត្រួតពិនិត្យធម្មនុញ្ញភាពយ៉ាងល្អិតល្អន់ផងដែរ ដោយយោងតាមគោលការណ៍ជាមូលដ្ឋាននៃការត្រួតពិនិត្យធម្មនុញ្ញភាពដូចដែលបានរៀបរាប់ពន្យល់ នៅក្នុងកថាខណ្ឌទី១។ ក្រោយពីបានប្រជុំសម្រេចអនុម័តសេចក្តីព្រាងច្បាប់នៅរដ្ឋសភារួច រដ្ឋសភាត្រូវបញ្ជូនសេចក្តីព្រាងច្បាប់នោះទៅឱ្យព្រឹទ្ធសភាត្រួតពិនិត្យពីលើម្តងទៀត ហើយព្រឹទ្ធសភាក៏ត្រួតពិនិ-ត្យធម្មនុញ្ញភាព ក៏ដូចជាអត្ថន័យ ឬអត្ថបទច្បាប់ដូចនៅក្នុងដំណាក់កាលរដ្ឋសភាពិនិត្យផងដែរ។ បន្ទាប់ពីទទួលបានការគាំទ្រ និង ធ្វើសេចក្តីសម្រេចឱ្យអនុម័តសេចក្តីព្រាងច្បាប់នោះ សេចក្តីព្រាងច្បាប់ត្រូវបញ្ជូនទៅឱ្យព្រះចៅអធិរាជតាមរយៈ គណៈរដ្ឋមន្ត្រីដើម្បីឱ្យឡាយព្រះហស្ថលេខាដើម្បីប្រកាសឱ្យប្រើប្រាស់ច្បាប់ថ្មីនោះ។ក្រោយឡាយព្រះហស្ថលេខាដោយព្រះចៅអធិរាជរួច សេចក្តីព្រាងច្បាប់នោះនឹងត្រូវប្រកាសឱ្យប្រើប្រាស់ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃព្រះចៅអធិរាជឡាយព្រះហស្ថលេខា។

### ២.ការត្រួតពិនិត្យជាបច្ឆាកាល ដោយស្ថាប័នតុលាការ

នៅប្រទេសជប៉ុន ការត្រួតពិនិត្យជាបច្ឆាកាលដោយស្ថាប័នតុលាការមានលក្ខណៈខុសគ្នាទាំងស្រុងពីប្រព័ន្ធរបស់ ព្រះរាជាណាចក្រកម្ពុជាដែលក្រុមប្រឹក្សាធម្មនុញ្ញរបស់ព្រះរាជាណាចក្រ-កម្ពុជាមិនអាចមានសិទ្ធិសើរើច្បាប់ ឬលិខិតបទដ្ឋាននានាដោយខ្លួនឯងនោះទេ បើមិនមានការស្នើសុំឱ្យត្រួតពិនិត្យតាមរយៈព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬ តំណាងរាស្ត្រ ចំនួនមួយភាគដប់ឬ តុលាការកំពូល។ តុលាការគ្រប់ជាន់ថ្នាក់របស់ប្រទេសជប៉ុនធ្វើការត្រួតពិនិត្យធម្មនុ-

---

មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』 (ភាសាខ្មែរ)(ខែកញ្ញា ឆ្នាំ ២០១៣) ទំព័រ ១៧១

ញ្ញភាព នៅពេលចៅក្រមយកច្បាប់មកប្រើ ដើម្បីដោះស្រាយរឿងក្តីហើយរកឃើញថាច្បាប់នោះផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន។នៅពេលតុលាការធ្វើសេចក្តីសម្រេចថា ច្បាប់នោះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់នោះត្រូវមោឃភាព ហើយមិនអាចយកមកប្រើប្រាស់ដើម្បីដោះស្រាយវិវាទឡើយ។ សិទ្ធិអំណាចនេះ(ពោលគឺសិទ្ធអំណាចដែលមិនប្រើច្បាប់អធម្មនុញ្ញភាព) គឺ អាចនិយាយបានថាជាសិទ្ធិអំណាចដែលត្រូវបានទទួលស្គាល់ឱ្យតុលាការ ដោះស្រាយវិវាទតាមរយៈការប្រើប្រាស់ ការបកស្រាយនៃច្បាប់ក៏ពិតមែនក៏ប៉ុន្តែតាមការពិតជាក់ស្តែង នៅក្នុងប្រវត្តិសាស្ត្រប្រទេសជប៉ុនក្រោយពីសង្គ្រាមលោកលើកទី២បានបញ្ចប់គឺទីបំផុតគឺត្រូវបានទទួលស្គាល់ និង ចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ យោងតាមរដ្ឋធម្មនុញ្ញមាត្រា៨១របស់ប្រទេសជប៉ុនបច្ចុប្បន្ន តុលាការមិនត្រឹមតែជាស្ថាប័នដែលប្រើប្រាស់ និងអនុវត្តនូវច្បាប់ដែលសភាបានអនុម័តនោះទេ តែស្ថាប័ននេះក៏អាចត្រួតពិនិត្យទៅលើធម្មនុញ្ញភាពរបស់ច្បាប់ទាំងឡាយបានផងដែរ ដែលមាត្រានេះបានចែងយ៉ាងច្បាស់ នៅក្នុងរដ្ឋធម្មនុញ្ញ។

ការត្រួតពិនិត្យធម្មនុញ្ញភាពនេះជាគោលការណ៍គឺធ្វើការត្រួតពិនិត្យទៅលើ២ចំណុចជាមូលដ្ឋានចម្បងទីមួយគឺគោលគំនិតនៃភាពដែលជាច្បាប់កំពូលរដ្ឋធម្មនុញ្ញ។រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ហើយច្បាប់លិខិតបទដ្ឋាន ឬសកម្មភាពរបស់រដ្ឋដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញគឺត្រូវសន្មត់ថាអធម្មនុញ្ញ និង មោឃភាពចោលដែលវាត្រូវបានការពារយ៉ាងពិតប្រាកដនៅក្នុងរដ្ឋធម្មនុញ្ញ។ ចំណុចទីពីរ គឺផ្អែកតាមគោលការណ៍គោរពសិទ្ធមនុស្សជាមូលដ្ឋាន។ការការពារនូវការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននេះ គឺជាគោលបំណង និង គោលការណ៍ចម្បងនៅក្នុងរដ្ឋធម្មនុញ្ញបច្ចុប្បន្នរបស់ប្រទេសជប៉ុន ហើយវាក៏មានតម្លៃផងដែរដែលក្លាយជាមូលដ្ឋានគ្រឹះនៃច្បាប់កំពូលដែលជារដ្ឋធម្មនុញ្ញ។គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាននោះ បើក្នុងករណីមានការរំលោភបំពានពីអំណាចនីតិបញ្ញត្តិ និង នីតិប្រតិបត្តិគឺអាចទាមទារ ជំនួយពីអំណាចតុលាការ ដើម្បីការពារការរំលោភបំពាននោះបាន[48]។ដូចនេះតាមរយៈរឿងក្តីខ្លួនកំពុងកាត់ក្តី តុលាការមិនធ្វើការត្រួតពិនិត្យលើអ្វីដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះទេ តែក៏ពិនិត្យទៅលើការការពារសិទ្ធិមនុស្សផងដែរ បើទោះបីជាមានឬ គ្មានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ក៏ដោយក៏ការគោរពសិទ្ធិមនុស្សនៅប្រទេសជប៉ុន ជាគោលការណ៍ចម្បងដែលត្រូវអាចការពារ និងមិនរំលោភបំពានដោយអង្គនីតិប្រតិបត្តិ និង នីតិបញ្ញត្តិបានឡើយ។

---

[48] 衆議院憲法調査会事務局（平成 16 年 3 月）「最高法規としての憲法のあり方に関する調査小委員会」、3 頁
ការិយាល័យស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា（ឆ្នាំ ២០០៤ ខែ មិនា）「គណៈកម្មាការស្រាវជ្រាវនីតិរដ្ឋធម្មនុញ្ញក្នុងនាមជាច្បាប់កំពូល」ទំព័រ ៣

## កថាខណ្ឌទី៣ អ្នកដែលមានសិទ្ធិស្នើសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញ

យោងតាមការបកស្រាយនៅក្នុងកថាខណ្ឌទី២ខាងលើយើងសង្កេតឃើញថាអ្នកដែលមានសិទ្ធិអាចស្នើសុំសើរើឱ្យ ត្រួតពិនិត្យធម្មនុញ្ញភាព លើច្បាប់ដែលសភា បានអនុម័តហើយនោះ គឺមានតែតុលាការដែលកំពុងកាន់ក្តីដោះស្រាយវិវាទ ហើយរកឃើញថាច្បាប់នោះមានបញ្ហាផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះដែលអាចសើរើត្រួតពិនិត្យធម្មនុញ្ញភាពបាន។ ពោលគឺតុលាការគ្រប់ជាន់ថ្នាក់ទាំងអស់នៅក្នុងប្រទេសជប៉ុនមានសិទ្ធិក្នុងការត្រួតពិនិត្យធម្មនុញ្ញបាន លុះត្រាណានៅក្នុងករណីដែលតុលាការដោះស្រាយវិវាទជាក់ស្តែង ហើយនៅពេលដែលយកច្បាប់នោះមកដោះស្រាយវិវាទ តែបែរជារកឃើញថា ផ្ទុយជាមួយនឹងរដ្ឋធម្មនុញ្ញ ទើបអាចសើរើត្រួតពិនិត្យធម្មនុញ្ញភាពបាន។ ប្រសិនបើគ្មានវិវាទការរំលោភបំពាន លើសិទ្ធិពលរដ្ឋទេ តុលាការមិនអាចធ្វើសើរើពិនិត្យធម្មនុញ្ញភាពដោយឯកឯងបានឡើយ។ ថ្វីត្បិតតែក្នុងលក្ខខណ្ឌនេះមានលក្ខណៈដូចទៅនឹងក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើងក៏ពិតមែន ក៏ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញ មិនឆ្លងកាត់ការដោះស្រាយវិវាទ ឬការបំពានសិទ្ធដូចតុលាការប្រទេសជប៉ុនឡើយ។មិនថាមាន ឬ គ្មានវិវាទ ឱ្យតែមានការស្នើសុំពីព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ឬ តំនាងរាស្ត្រចំនួនមួយភាគដប់ ឬ ក៏តុលាការ ក្រុមប្រឹក្សាធម្មនុញ្ញអាចសើរើពិនិត្យធម្មនុញ្ញភាពបាន។

# ផ្នែកទី៣ ការសិក្សាប្រៀបធៀបប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពកម្ពុជា និង ជប៉ុន

## កថាខណ្ឌទី១ លក្ខណៈស្របគ្នានៃប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទាំងពីរ

តាមការរៀបរាប់ និង បកស្រាយសិក្សាអំពីប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាពខាងលើរួចមក ឃើញថាទាំងនៅព្រះរាជាណាចក្រកម្ពុជា និង នៅប្រទេសជប៉ុន គឺមានចំណុចដូចគ្នាចំពោះប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាព ដែលត្រូវលើកយកមកធ្វើការប្រៀបធៀបគួរឱ្យកត់សម្គាល់ដូចខាងក្រោម។

### ១.អត្ថិភាពនៃការស្នើសុំ និង អ្នកអាចស្នើសុំប្ដឹងការត្រួតពិនិត្យធម្មនុញ្ញភាព

អត្ថិភាពនៃការស្នើសុំត្រួតពិនិន្យធម្មនុញ្ញភាពគឺមានន័យថាទាំងព្រះរាជាណាចក្រកម្ពុជានិងប្រទេសជប៉ុនគឺមានប្រព័ន្ធនៃ ការស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពដូចគ្នាក្នុងគោលបំណងនៃការធ្វើច្បាប់ និង អនុវត្តច្បាប់ កុំឱ្យមានបញ្ហាអធម្មនុញ្ញភាព។ នេះសបញ្ជាក់ឱ្យឃើញថា គឺជាការគិតគូរទៅដល់តម្លាភាព សមភាព និង អព្យាក្រឹត្យភាពនៅក្នុងការអនុវត្តច្បាប់ដើម្បីឈានទៅរកប្រទីបនីតិរដ្ឋ។

ចំពោះព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកច្បាប់ណាមួយមកពិនិត្យខ្លួនឯង ដោយគ្មានអ្នកមានសមត្ថកិច្ចស្នើសុំ ឬប្ដឹងបាននោះទេ។រហូតមកដល់ពេលនេះក្រុមប្រឹក្សាធម្មនុញ្ញនៅតែប្រកាន់តាមគោលការណ៍នេះ។នៅព្រះរាជាណាចក្រកម្ពុជា មានការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល និង បច្ឆាកាល។ក្នុងការពិនិត្យច្បាប់អាទិកាលនេះ យោងតាមមាត្រា១៤០ថ្មី វាក្យខណ្ឌទី១នៃរដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភាតំនាងរាស្ត្រចំនួន មួយភាគដប់ ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួនអាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះប្រកាសឱ្យប្រើ។ ដោយឡែកចំពោះការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល១៤១ថ្មីនៃរដ្ឋធម្មនុញ្ញចែងថាក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភានាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ ឬ តុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញភាពនៃច្បាប់។ វាក្យខណ្ឌទី២ នៃមាត្រាដដែលនេះបានចែងទៀតថា

ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីអធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬប្រធានរដ្ឋសភា ដូចមានចែងក្នុងវាក្យខណ្ឌខាងលើ។សិទ្ធដែលផ្ដល់ឱ្យអ្នកតំណាងរាស្ត្រចំនួនមួយភាគដប់ និង សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ដើម្បីស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញមានសារៈសំខាន់ណាស់។សិទ្ធនេះផ្ដល់ឱ្យមតិភាគតិចក្នុងរដ្ឋសភាក្នុងការសុំឱ្យមានការត្រួតពិនិត្យធម្មនុញ្ញនៃច្បាប់ដែលអនុម័តដោយមតិភាគច្រើន។ វាជាធាតុផ្សំមួយនៃនីតិរដ្ឋ ។

ទន្ទឹមនឹងនេះ មាត្រា១៨ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា ក្រោយពីច្បាប់ណាមួយ ត្រូវបានប្រកាស ឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការអាចសុំឱ្យ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។មានន័យថា តុលាការក៏អាចស្នើសុំឱ្យត្រួតពិនិត្យធម្មនុញ្ញភាពបានដែរ ដោយភាគីដែលជាគូក្តី ឬ ចៅក្រមខ្លួនឯង អាចលើកឡើងនូវអញ្ញត្រកម្មអធម្មនុញ្ញភាពនៃច្បាប់។នៅក្នុងរដ្ឋធម្មនុញ្ញមិនបានកំណត់នូវលក្ខខណ្ឌការត្រួតពិនិត្យធម្មនុញ្ញភាពដោយអញ្ញត្រកម្មទេ ។ក៏ប៉ុន្តែមានចែងនៅក្នុងមាត្រា ១៩ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយហើយ រឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន។ បើយោងតាមមាត្រានេះ សិទ្ធិប្តឹងទៅតុលាការអាចជាសិទ្ធិដើមចោទ ចុងចោទ ក៏ដូចជារបស់គូភាគីនៅតុលាការដែរ។ក៏ប៉ុន្តែទោះជា យ៉ាងណាក៏ដោយ ក៏មាត្រា១៩ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងបន្ថែមថា បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូល ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ។ចំណុចនេះចៅក្រមវាយតម្លៃពីភាពមានមូលដ្ឋានច្បាស់លាស់របស់បណ្តឹង ប្រសិនបើចៅក្រមយល់ថា មានមូលដ្ឋានច្បាស់លាស់ ចៅក្រមត្រូវបញ្ជូនសំណុំរឿងទៅតុលាការកំពូលត្រូវចាត់ការពិនិត្យ និង ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ ដូចក្នុងមាត្រា១៩ វាក្យខណ្ឌទី៣នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា តុលាការកំពូលត្រូវចាត់ការពិនិត្យ និង ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថាពាក្យបណ្តឹងតវ៉ានេះអាចទទួលបាន។លទ្ធភាពឱ្យមានការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាលជាការធានាជាអតិបរមានូវការគោរពនីតិរដ្ឋ តាមរយៈការត្រួតពិនិត្យធម្មនុញ្ញភាពដែលមានលក្ខណៈពេញលេញបំផុត។

ចំណែកឯប្រទេសជប៉ុនក៏មានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពដែរតែជាការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាលនៅពេលដែលមានបណ្តឹងរបស់ភាគីណាមួយប្តឹង ទាមទារឱ្យត្រួតពិនិត្យធម្មនុញ្ញភាពនោះ តុលាការនឹងពិនិត្យទៅលើរឿងក្តី នឹងត្រួតពិនិត្យធម្មនុញ្ញទៅនឹងបរិបទនៃរឿងក្តីដែលបានកើតឡើង។ប្រសិនបើយល់ឃើញថាមាត្រា ឬ ច្បាប់នោះអធម្មនុញ្ញភាពទៅនឹងការអនុវត្តចំពោះរឿងក្តីដូច្នេះ តុលាការគ្រប់ជាន់ថ្នាក់អាចចេញសេចក្តីសម្រេចអធម្មនុញ្ញទៅនឹងរឿងក្តីនោះហើយ

មានអានុភាពអនុវត្ត ឬមិនអនុវត្តតាមការសម្រេចរបស់តុលាការ ដោយមានវិសាលភាពច្បាប់ខាងនីតិប្រតិបត្តិ និង នីតិប្រតិបត្តិផងដែរ។

**២.គោលការណ៍នៃការត្រួតពិនិត្យធម្មនុញ្ញភាព**

គោលការណ៍នៃការត្រួតពិនិត្យនៃធម្មនុញ្ញភាព គឺ ទាំងប្រទេសជប៉ុន និង ព្រះរាជាណាចក្រកម្ពុជា គឺពិនិត្យទៅលើទាំងទម្រង់ និង គតិនៃច្បាប់ ដោយយករដ្ឋធម្មនុញ្ញនៃប្រទេសរៀងខ្លួនមកធ្វើការពិនិត្យផ្ទៀងផ្ទាត់។ គឺមានន័យថាគេយករដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលមកធ្វើជាគោលក្នុងការពិនិត្យធម្មនុញ្ញភាពចំពោះច្បាប់ទាំងឡាយ។ ជាក់ស្តែងមាត្រា១៥ថ្មីនៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានប្បញ្ញត្តិថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ ដូច្នេះរដ្ឋធម្មនុញ្ញគឺជា ច្បាប់ផ្តាច់មុខតែមួយគត់ដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពចំពោះច្បាប់ទាំងឡាយ។

## កថាខណ្ឌទី២ លក្ខណៈខុសគ្នានៃប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទាំងពីរ

ថ្វីបើព្រះរាជាណាចក្រកម្ពុជា និង ប្រទេសជប៉ុន មានការត្រួតពិនិត្យធម្មនុញ្ញភាព ក៏ប្រព័ន្ធទាំងពីរនេះពុំមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ។ គឺលក្ខណៈខុសគ្នាមួយចំនួនដែលលេចចេញឡើងគួរឱ្យកត់សម្គាល់ដែលត្រូវលើកយកមកសិក្សាដូចខាងក្រោម។

**១.ស្ថាប័នត្រួតពិនិត្យធម្មនុញ្ញ**

នៅព្រះរាជាណាចក្រកម្ពុជាយើង ស្ថាប័នដែលមានតួនាទីក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនាពេលបច្ចុប្បន្នគឺ ក្រុមប្រឹក្សាធម្មនុញ្ញដែលមានសមត្ថកិច្ចពេញលេញ និង ស្របច្បាប់ក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ តាមស្មារតីនៃរដ្ឋធម្មនុញ្ញ មាត្រា ១៣៦ បានចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារគោរពរដ្ឋធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់។ទន្ទឹមនឹងនេះមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃរដ្ឋធម្មនុញ្ញបានចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពាររដ្ឋធម្មនុញ្ញ និង ច្បាប់ដែលអនុម័តដោយរដ្ឋសភាក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។មានន័យថា ប្រទេសកម្ពុជាយើងមានស្ថាប័នមួយសម្រាប់ត្រួតពិនិត្យធម្មនុញ្ញភាពមួយដាច់ដោយឡែក មិនពាក់ព័ន្ធនឹងស្ថាប័នផ្សេងណាឡើយ។

រីឯប្រទេសជប៉ុនវិញយើងឃើញថា ពុំមានស្ថាប័ននៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពមួយដោយឡែកនោះទេ គឺប្រព័ន្ធប្រទេសជប៉ុនពិនិត្យធម្មនុញ្ញភាព ជាបច្ឆាកាលនៅពេលមានបណ្តឹង

អធម្មនុញ្ញភាពចំពោះរឿងក្តី ពោលគឺតុលាការគ្រប់ជាន់ថ្នាក់អាចពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់ដែលកំពុងអនុវត្តនោះបាន។ចំណែកឯការពិនិត្យច្បាប់មុនប្រកាសឱ្យប្រើនោះ ពុំមានការត្រួតពិនិត្យធម្មនុញ្ញភាពពីស្ថាប័នតុលាការខាងលើឡើយ គឺ ខាងគណៈរដ្ឋមន្ត្រីជាអ្នកពិនិត្យយ៉ាងម៉ត់ចត់ទៅលើធម្មនុញ្ញភាព។

**២.អ្នកស្នើសុំ**

ចំពោះព្រះរាជាណាចក្រកម្ពុជាជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យ ដោយខ្លួនឯងបានឡើយ ។ មានតែ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងអ្នកតំណាងរាស្ត្រមួយភាគដប់ ឬ តុលាការប៉ុណ្ណោះ ដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ ធម្មនុញ្ញភាព នៃច្បាប់បាន ។ ប្រជា-រាស្ត្រ និងគណបក្សនយោបាយអាច លើកសំណើ ឬ ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមលក្ខ-ខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់។

រីឯប្រទេសជប៉ុនវិញការសុំប្តឹងឱ្យត្រួតពិនិត្យធម្មនុញ្ញភាព គឺមានតែភាគីនៃបណ្តឹងចំពោះរឿងក្តីរបស់ខ្លួនដែលយល់ឃើញថា ច្បាប់នោះអធម្មនុញ្ញភាពប៉ុណ្ណោះ ដែលអាចស្នើសុំប្តឹងទៅតុលាការមានសមត្ថកិច្ចពិនិត្យមើលអធម្មនុញ្ញភាពនោះ។ ចំណែកច្បាប់ដែលប្រកាសឱ្យប្រើហើយ ប្រសិនបើ សភាពិនិត្យមើលឃើញថាអធម្មនុញ្ញភាពនោះ គឺគេធ្វើវិសោធនកម្មមាត្រា ឬ ច្បាប់នោះតែម្តង ដោយពុំមានក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិគ្រោះនិង ឱ្យយោបល់តែម្តង។

**៣.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាព**

**៣.១.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជា**

**៣.១.១ដំណើរការនៃសំណុំរឿងនៅនាយកដ្ឋានជំនាញ**

នៅពេលទទួលបានសំណើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់នាយកដ្ឋានជំនាញចុះបញ្ជីក្នុងសៀវភៅទទួលសំណុំរឿង។ ក្រោយពីចុះបញ្ជីរួចនាយកដ្ឋានត្រូវរៀបចំកំណត់បង្ហាញរឿងដាក់ឆ្លងតាមឋានានុក្រមរហូតដល់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញភាពនៃច្បាប់ដើម្បីពិនិត្យនិងសម្រេច។ ការងារបន្ទាប់របស់នាយកដ្ឋានជំនាញ គឺជួយដល់ក្រុមប្រឹក្សាធម្មនុញ្ញដូចជារៀបចំសំណុំរឿងសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ រៀបចំកម្មវិធីលម្អិតជូនថ្នាក់ដឹកនាំ សម្រាប់កិច្ចប្រជុំទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីស្រាវជ្រាវរកឯកសារ តាមតម្រូវការសមាជិករាយការណ៍របស់ក្រុមប្រឹក្សាធម្ម-នុញ្ញ ចូលរួមជាជំនួយការលេខាកត់ត្រា និង ធ្វើកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ៣.១.២.ការចាត់តាំងសមាជិករាយការណ៍

នៅពេលច្បាប់ដែលត្រូវបានស្នើសុំមកក្រុមប្រឹក្សាធម្មនុញ្ញ ចាត់តាំងសមាជិកម្នាក់ឱ្យធ្វើជាសមាជិករាយការណ៍។ របាយការណ៍របស់សមាជិករាយការណ៍ជាមូលដ្ឋានសំខាន់មួយសម្រាប់ពិចារណា។យោងតាមមាត្រា២២ថ្មី វាក្យខណ្ឌទី២ នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ឬបកស្រាយច្បាប់ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិក ដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍ ហើយសមាជិករាយការណ៍ជាសមាជិកនៃក្រុមរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា៣០នៃច្បាប់នេះ។

ប្រការ៣ថ្មី នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខ ក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថាក្រោយពីចុះបញ្ជីរួច ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជូនសំណើទាំងនោះទៅសមាជិករាយការណ៍ក្នុងក្រុមណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ។ របាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវដាក់ជូនអង្គប្រជុំបឋមដើម្បីពិភាក្សា។

### ៣.១.៣.ភារកិច្ចរបស់សមាជិករាយការណ៍

បន្ទាប់ពីប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាត់តាំងសមាជិករាយការណ៍ សមាជិករាយការណ៍ត្រូវកោះប្រជុំក្រុមដោយមានមន្ត្រីសេវាកម្មច្បាប់ចូលរួមជាលេខាធិការកត់ត្រា។ សមាជិករាយការណ៍អាចស្នើសុំប្រធានក្រុមប្រឹក្សាធម្មនុញ្ញឱ្យអញ្ជើញបុគ្គលឯកជន ឬ បុគ្គលសាធារណៈម្នាក់ ឬ ច្រើននាក់ដើម្បីសុំឱ្យអ្នកទាំងនោះផ្តល់ការបំភ្លឺឬផ្តល់ឯកសារផ្សេងៗដែលពាក់ព័ន្ធ ដូចក្នុងមាត្រា២១នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ ឬ ច្រើននាក់មកបំភ្លឺ ឬផ្តល់ឯកសារដែលពាក់ព័ន្ធបាន។បុគ្គលគ្រប់រូប ស្ថាប័នរដ្ឋ ឬ ឯកជនទាំងឡាយ ត្រូវគោរព និង ប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រោយពីសិក្សាលើច្បាប់ហើយ ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើរបាយការណ៍ស្តីពីការពិនិត្យធម្មនុញ្ញភាពដើម្បីដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញនាសម័យប្រជុំបឋមដើម្បីពិនិត្យ និង ពិភាក្សា។

### ៣.១.៤.សេចក្តីសម្រេច

បន្ទាប់ពីក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើរបាយការណ៍ ស្តីពីការពិនិត្យធម្មនុញ្ញភាពចប់រួចរាល់ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើលិខិតអញ្ជើញសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីចូលរួមប្រជុំពិភាក្សាទៅលើរបាយការណ៍របស់ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ។យោងតាមមាត្រា១៤ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមានអាយុច្រើនជាងគេ ដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន។

ប្រការ១២ថ្មីវាក្យខណ្ឌទី១ នៃបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថា កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន។លិខិតអញ្ជើញប្រជុំត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញយ៉ាងតិច២ថ្ងៃ មុនថ្ងៃកំណត់ប្រជុំលើកលែងតែការប្រញាប់។យោងតាមប្រការ១៣ថ្មីវាក្យខណ្ឌទី១ នៃបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា ការកោះប្រជុំត្រូវធ្វើជាលិខិតអញ្ជើញភ្ជាប់ជាមួយគម្រោងរបៀបវារៈ ហើយផ្ញើជូនសមាជិកយ៉ាងតិច២ថ្ងៃ មុនថ្ងៃកំណត់ប្រជុំលើកលែងតែការប្រញាប់។

### ៣.១.៥.កិច្ចប្រជុំបឋម

ដើម្បីអាចប្រជុំបាន ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានកូរ៉ុមលើសពី ពាក់កណ្តាលដូចមានក្នុងមាត្រា ១៤ថ្មី វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា កិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិក លើសពីពាក់កណ្តាលចូលរួមប្រជុំ។នៅក្នុងកិច្ចប្រជុំបឋមនេះសមាជិករាយការណ៍ត្រូវតែរាយការណ៍ជូនក្រុមប្រឹក្សាធម្មនុញ្ញដូចដែលមានក្នុងរបាយការណ៍ដើម្បីពិភាក្សា។ សមាជិកទាំងអស់ បញ្ចេញមតិយោបល់ ថា តើរបាយការណ៍នេះបានពិនិត្យគ្រប់ជ្រុងជ្រោយឬ នៅខ្វះខាតមុននឹងដាក់ចូលក្នុងកិច្ចប្រជុំពេញអង្គពិនិត្យ និង សម្រេច។

### ៣.១.៦.កិច្ចប្រជុំពេញអង្គ

យោងតាមមាត្រា ២២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខណ៍អក្សរលើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈពេល៣០ថ្ងៃ។ប្រសិនបើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកត្រឹម៨ថ្ងៃ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិកដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍។កិច្ចប្រជុំពេញអង្គពិនិ-

ត្យ និង សម្រេចលើច្បាប់នោះថា តើស្របនឹងរដ្ឋធម្មនុញ្ញ ឬ មិនស្របរដ្ឋធម្មនុញ្ញ ឬមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញ។ត្រង់ចំណុចនេះមាត្រា ២០នៃច្បាប់ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា បើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថា បទប្បញ្ញត្តិថាមួយនៃច្បាប់មិនស្របនឹងរដ្ឋធម្មនុញ្ញ៖

ក.បើបទប្បញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅបានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រើប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបានឡើយ។

ខ.បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសេសសល់បាននោះ មានតែបទប្បញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេដែលមិនអាចយកទៅប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបាន។ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនលើសសម្លេងដាច់ខាតនៃសមាជិកទាំងមូល ដូចមានចែងក្នុងមាត្រា២២ថ្មី វាក្យខណ្ឌទី៣នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រការ៧ នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា ចំពោះគ្រប់សំណើឱ្យពិនិត្យខាងលើក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងពេលវេលាមួយដែលមានកំនត់ក្នុងច្បាប់ និង មតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល(៥សម្លេងយ៉ាងតិច)។

ទោះបីចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនគត់ក៏ដោយ(៩រូប) ប៉ុន្តែសម្លេងអាចស្មើគ្នាបានដោយសារតែវត្តមានរបស់សមាជិក មិនមែនចាំបាច់ខានមិនបាននោះទេមានន័យថា អាចមានសមាជិកអវត្តមាន។ យោងតាមមាត្រា ១៥ថ្មី វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថាកិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកថាបានលុះត្រាតែមានសមាជិកលើសពាក់កណ្តាលចូលរួមប្រជុំ។ ចំណែកឯបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រការ១២ថ្មី ក៏បានចែងពីកូរ៉ុមនេះដែរ។ដូច្នេះប្រសិនបើមានអវត្តមានតែ ៨ រូប អាចមានសម្លេងសម្លេងស្មើគ្នា។ ក្នុងករណីនេះមាត្រា២២ថ្មីនៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា សម្លេងប្រធានមានឧត្តមានុភាព។ ចំណែកឯប្រការ១៩ នៃបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញក៏បានចែងថាក្នុងការអនុម័តតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បើចំនួនមតិយល់ព្រមស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានឧត្តមានុភាព។

### ៣.១.៧.ការចេញសេចក្តីសម្រេច

សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរ និង បិទផ្លូវតវ៉ា។ សេចក្តីសម្រេចទាំងនេះមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។បទប្បញ្ញត្តិទាំងឡាយណាមួយ នៃច្បាប់ដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាវាមិនស្របនឹងរដ្ឋធម្មនុញ្ញមិនអាចយកទៅប្រកាសឱ្យប្រើ ឬអនុវត្តបានទេ។

ដើម្បីឱ្យសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានការជ្រួតជ្រាប ដោយមានប្រសិទ្ធភាព សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនព្រឹទ្ធសភា រដ្ឋសភា នាយករដ្ឋមន្ត្រី តុលាការកំពូល និង ត្រូវបោះផ្សាយនៅក្នុងរាជកិច្ច។ដូចមាត្រា២៤ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានព្រឹទ្ធសភា ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និង ប្រធានតុលាការកំពូល និង ចុះផ្សាយក្នុងរាជកិច្ច។

ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិកព្រឹទ្ធសភាទាំងអស់។ ប្រធានរដ្ឋសភា ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករដ្ឋសភាទាំងអស់។នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់សមាជិករាជរដ្ឋាភិបាលទាំងអស់។ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់តុលាការសាមី។

## ៣.២.នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន

### ៣.២.១.ការត្រួតពិនិត្យធម្មនុញ្ញភាពនៅស្ថាប័ននីតិប្រតិបត្តិ

នៅប្រទេសជប៉ុននៅពេលដែលមានសេចក្តីព្រាងច្បាប់ ធ្វើនៅស្ថាប័ននីតិប្រតិបត្តិគឺ នៅទីស្តីការគណៈរដ្ឋមន្ត្រីនៃប្រទេសជប៉ុនគឺមានក្រុមប្រឹក្សាអ្នកច្បាប់មួយ ដែលជាអ្នកត្រួតពិនិត្យមើលអំពីធម្មនុញ្ញភាពនៅក្នុងសេចក្តីព្រាងច្បាប់នោះ មុននឹងបញ្ជូនទៅឱ្យរដ្ឋសភាអនុម័តបន្ត។ ការដែលពិនិត្យមើលធម្មនុញ្ញភាពនៃសេចក្តីព្រាងច្បាប់នោះគឺមានភាពម៉ត់ចត់ និង តឹងរឹងបំផុតមុននឹងសម្រេចបញ្ជូន ទៅរដ្ឋសភា។ ប្រទេសជប៉ុន ពុំមែនត្រួតពិនិត្យ តែទិដ្ឋភាព ខ្លឹមសារ លទ្ធផលអនាគតនៅពេលអនុវត្តប៉ុណ្ណោះទេ គឺត្រួតពិនិត្យទៅលើធម្មនុញ្ញបន្ថែមទៀត។នៅពេលច្បាប់នោះបញ្ជូនទៅរដ្ឋសភា គឺសេចក្តីព្រាងនោះសឹងតែល្អឥតខ្ចោះពុំចាំបាច់ពិនិត្យលើធម្មនុញ្ញភាពនោះទេ។ ការពិនិត្យបែបនេះយើងអាចចាត់ទុកថា ជាការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល នៅប្រទេសជប៉ុន។

### ៣.២.២.ការត្រួតពិនិត្យធម្មនុញ្ញភាពនៅស្ថាប័នតុលាការ

នៅប្រទេសជប៉ុនការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាអាទិកាលអាចធ្វើទៅបាននៅស្ថាប័នតុលាការ គឺនៅពេលដែលមានបណ្ដឹងរបស់ភាគីនៅតុលាការគ្រប់ជាន់ថ្នាក់ ពោលគឺបណ្ដឹងដែលទាក់ទងទៅនឹងអធម្មនុញ្ញភាពចំពោះរឿងក្ដីនៅពេលអនុវត្តច្បាប់។តុលាការសាម៉ីនៅប្រទេសជប៉ុនក្រោយពីការពិនិត្យទៅលើបណ្ដឹងអធម្មនុញ្ញភាពនោះអាចធ្វើការពិនិត្យទៅលើទម្រង់ច្បាប់ និង ខ្លឹមសារច្បាប់ឬមាត្រានោះតាមការប្ដឹងរបស់ភាគីបាន។ប្រសិនបើពិនិត្យទៅឃើញអធម្មនុញ្ញភាពច្បាប់ តុលាការអាចចេញសេចក្ដីសម្រេចបញ្ជាក់អំពីអធម្មនុញ្ញភាពនៃច្បាប់នោះ ហើយពុំអាចយកមកប្រើបានទៀតឡើយចំពោះមាត្រាដែលប្រកាសនោះ។អានុភាពនៃសេចក្ដីសម្រេចនោះ គឺមានឥទ្ធិពលជាសារមួយអាចស្នើសុំឱ្យមានវិសោធនកម្មលើមាត្រា ឬ ច្បាប់នោះបាន។ នេះជាចំណុចមួយដែលផ្ទុយគ្នាជាមួយប្រព័ន្ធរបស់កម្ពុជាដោយតុលាការមានសិទ្ធិត្រឹមបញ្ជូនមកតុលាការកំពូល ហើយតុលាការកំពូលបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាពតែប៉ុណ្ណោះ ពុំមានសិទ្ធិអារកាត់ សម្រេចសេចក្ដីនោះឡើយ។

# ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

## ក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃ

## ប្រព័ន្ធកម្ពុជា និង ជប៉ុន

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ
# ក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃ ប្រព័ន្ធកម្ពុជា និង ជប៉ុន

## ផ្នែកទី១ បញ្ហាប្រឈមនៃការត្រួតពិនិត្យធម្មនុញ្ញភាព

ចំពោះព្រះរាជាណាចក្រកម្ពុជា គឺទើបតែមានក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពតាមរដ្ឋធម្មនុញ្ញថ្មីដែលបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។ដូច្នេះហើយការអនុវត្តតាំងពីពេលនោះមករហូតមកដល់បច្ចុប្បន្ន យើងឃើញថាមានចំនុចជាបញ្ហាប្រឈមមួយចំនួនដែលរកដំណោះស្រាយក្នុងការអនុវត្ត ស្ថាប័ននេះឱ្យមានតម្លាភាព អព្យាក្រឹត្យភាព និង ជាស្ថាប័នឯករាជ្យសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

### កថាខណ្ឌទី១ បញ្ហាកើតឡើងនៅប្រទេសកម្ពុជា

#### ១.សមាជិកភាពនៃស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាព(ឯករាជ្យភាព)

យោងតាមមាត្រា៣នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា សមាជិកទាំង៩ រូបនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុ៤៥ឆ្នាំមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច១៥ឆ្នាំ ។ត្រង់វាក្យខណ្ឌខាងលើមានន័យថាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជាឥស្សរជន គឺជនដែលមានសមត្ថភាព និង កេរ្តិ៍ឈ្មោះ ពោលគឺជាជនជាន់ខ្ពស់នៅក្នុងសង្គម មានឈ្មោះសញ្ជាតិខ្មែរពីកំណើត ហើយត្រូវមានអាយុ៤៥ឆ្នាំ។យើងឃើញថាការកំណត់អាយុ៤៥ឆ្នាំនេះ គឺពុំមានចំណោទត្រូវដោះស្រាយនោះទេ ព្រោះអាយុនេះក៏បានបង្ហាញពីបទពិសោធន៍ការងារ ក្នុងរយៈពេលដ៏យូរអង្វែង ចាប់ពី១៥ឆ្នាំឡើងទៅ គឺជារយៈពេលយូរក្នុងការធ្វើការក្នុងអតីតភាពការងារ។តែត្រង់វាក្យខណ្ឌនេះធ្វើអោយបេក្ខជនជាឥស្សរជនជ្រើសរើសនោះ ត្រូវមានជំនាញ តែជំនាញនោះទាក់ទងនឹងជំនាញផ្នែករដ្ឋធម្មនុញ្ញនោះទេ ថ្វីត្បិតតែបរិញ្ញាបត្រច្បាប់ក៏ដោយ ក៏ពុំទាន់ត្រូវនឹងជំនាញផ្នែកត្រួតពិនិត្យធម្មនុញ្ញភាពដែរ។មានន័យថាលក្ខខណ្ឌចំណេះដឹងខាងលើ គឺពុំទាន់មានភាពច្បាស់លាស់ជាមួយនឹងជំនាញនីតិរដ្ឋធម្មនុញ្ញនោះទេ។វាក្យខណ្ឌទី២ នៃមាត្រា៣ ដែលបានចែងថា «សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣ រូប តែងតាំងដោយព្រះមហាក្សត្រ ៣ រូបទៀត តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៣ រូបទៀតជ្រើសតាំងដោយរដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។ នៅ

ក្នុងវាក្យខណ្ឌនេះសបញ្ជាក់ថាក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំង ដោយអង្គព្រះមហាក្សត្រតែម្តង ចំនួន៣រូប គឺពុំមានការសម្រេចពីស្ថាប័នណាឡើយ ការតែងតាំងនេះគឺត្រូវយោងតាមព្រះទ័យរបស់ព្រះករុណាអម្ចាស់ជីវិតតម្កល់លើត្បូង។ការអនុវត្តកន្លងមក ការតែងតាំងដោយព្រះមហាក្សត្រនេះ គឺភាគច្រើនសុទ្ធតែព្រះរាជានុវង្សានុវង្ស ជាក់ស្តែងសមាសភាព ក្រុមប្រឹក្សាធម្មនុញ្ញ ៣ឆ្នាំលើកទី៦ (២០១៣ដល់២០១៦) គឺសមាសភាពតែងតាំងដោយព្រះមហាក្សត្រ មានព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ដារ៉ាវង្ស** សម្តេច **នរោត្តមសិរីវុធ** និង សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស** ដែលជាព្រះញាតិវង្សខាងព្រះ**ស៊ីសុវត្ថិ** និង **ព្រះនរោត្តម**។

រីឯសមាជិក៣រូបទៀត តែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺពុំមែនជ្រើសរើសចេញអំពីសមាជិកទាំង១១រូប ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះទេ គឺតម្រូវឱ្យជ្រើសរើសយកតាមការប្រជុំសម្រេចតែងតាំងរបស់ក្រុមប្រឹក្សានោះផ្ទាល់។ បើពិនិត្យទៅមើលការតែងតាំងប៉ុន្មានលើកកន្លងមក ការតែងតាំងនោះច្រើន តែងតាំងអតីតចៅក្រម ឬចៅក្រមចូលនិវត្តន៍ដែលជាឥស្សរជន ក្នុងគណបក្សកាន់អំណាច ដូច្នេះអាចមានភាពមិនប្រក្រតីចំពោះឯករាជ្យភាព នៃស្ថាប័ននេះ។

ចំណែកឯសមាជិក៣ រូបទៀតដែលត្រូវតែងតាំងដោយរដ្ឋសភា គឺ ការតែងតាំងនោះ ត្រូវយកមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល។ជាទូទៅការតែងតាំង ពីរដ្ឋសភានោះតែងតែយកតំនាងរាស្ត្រដែលជាតំនាងរាស្ត្រធ្វើការយូរឆ្នាំ និង ចាស់ទុំជាងគេក្នុងរដ្ឋសភាចំនួន៣នាក់ ធ្វើការច្រើនអាណត្តិ និងខ្លះទៀតជារដ្ឋលេខាធិការតាមស្ថាប័នរដ្ឋជាដើម។ជាក់ស្តែងឯកឧត្តម **ឯក សំអុល** និង ឯកឧត្តម **ហ៊ីន សាន** ក្នុងអាណត្តិទី៣នៃរដ្ឋសភាជាតំនាងរាស្ត្រនៅមណ្ឌលព្រៃវែងដែលជាសមាជិកសភា និង ឯកឧត្តម **ពិត តាំងសាន** ត្រូវបានជ្រើសតាំងដោយរដ្ឋសភា នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ជាអតីតអនុរដ្ឋលេខាធិកាទីស្តីការគណៈរដ្ឋមន្ត្រី។ប្រការនេះគឺគាត់ជាសមាជិកសភាផង និង ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញផង ។ដូច្នេះមានបញ្ហាវិសមិតភាពមុខងារដែលមាត្រា ៥ ថ្មី បានចែងថា « មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពជាមួយមុខងារសមាជិករដ្ឋាភិបាល សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ប្រធាន អនុប្រធាន គណបក្សនយោបាយ ប្រធាន អនុប្រធានសហជីពនិង ចៅក្រមក្នុងតំណែង។

វាក្យខណ្ឌទី២ នៃមាត្រាដដែលនេះ « សមាជិកនៃក្រុមប្រឹក្សាធម្មនុញ មិនត្រូវបំពេញមុខតំណែង និង មុខរបរផ្សេងទៀត ក្នុងអាណត្តិរបស់ខ្លួនឡើយអ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញមុនចូលកាន់តំណែងត្រូវសុំលាឈប់ជាបណ្តោះអាសន្ន ពីតំណែង ឬ មុខរបរ

ទាំងអស់ ដែលបានចែងក្នុងវាក្យខណ្ឌខាងលើ។ដូចនេះយើងឃើញថាមានបញ្ហាវិសមិតភាពចំពោះការអនុវត្តមុខងារដែលគួរតែកែតម្រូវនាពេលអនាគត។

**២.បញ្ហានៃការត្រួតពិនិត្យជាអាទិកាល**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ត្រួតពិនិត្យសេចក្ដីព្រាង ឬ សេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រត្រូវពិគ្រោះយោបល់នឹងក្រុមប្រឹក្សាធម្មនុញ្ញជាមុន។ការអនុវត្ត ចំពោះការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាលនេះ គឺក្រុមប្រឹក្សាធម្មនុញ្ញពេលខ្លះចេញសេចក្ដីសម្រេចក្រោយពិនិត្យគ្រប់មាត្រានៃច្បាប់ ថាស្រប នឹងរដ្ឋធម្មនុញ្ញទោះបីជាច្បាប់នោះជាសេចក្ដីព្រាង ឬ សេចក្ដីស្នើច្បាប់នោះទេជារឿយៗយើងឃើញថាមានរយៈពេលដែលអនុវត្តកន្លងគឺពិនិត្យលឿន រហ័សបំផុត ទោះបីជាមានសង្គមស៊ីវិលមួយចំនួន ឬ ក៏បណ្ដាទស្សនទានអ្នកច្បាប់ថាមិនស្រប នឹងរដ្ឋធម្មនុញ្ញក៏ដោយក៏ច្បាប់ដែលត្រូវនឹងដាក់ប្រកាសឱ្យប្រើនោះហាក់ដូចជាត្រឹមត្រូវតាមទម្រង់ និង គតិ នៃរដ្ឋធម្មនុញ្ញ។ពោលគឺច្បាប់ដែលចេញពីសេចក្ដីព្រាងខាងអំណាចនីតិប្រតិបត្តិពុំដែលសូវអធម្មនុញ្ញភាពនោះទេ ការពិនិត្យមានភាពរហ័ស និង មិនយឺតយូរឡើយ។

**៣.មូលដ្ឋានគ្រឹះនៃគោលការណ៍ត្រួតពិនិត្យធម្មនុញ្ញភាព**

អនុលោមតាមច្បាប់ស្ដីពីការរៀបចំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រង់មាត្រា១៥ថ្មី បានចែងថាក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការការពារគោរពធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ច្បាប់ដដែលនេះគ្រាន់តែចារឹកបញ្ជាក់អំពីការយករដ្ឋធម្មនុញ្ញជាគោលក្របខណ្ឌក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់តែប៉ុណ្ណោះ ពុំបានកំណត់ថា ប្រសិនបើអធម្មនុញ្ញភាពនោះមានន័យដូចម្ដេចទៅ? ពោលគឺពាក្យអធម្មនុញ្ញភាពនេះពុំបានកំនត់អោយច្បាស់លាស់អំពីបរិបទ នៃពាក្យនេះទេ ដោយពុំមានគោលការណ៍ប្រាកដ កំនត់អំពីនីតិវិធីត្រួតពិនិត្យធម្មនុញ្ញភាពស្រប ឬ មិនស្រប(អធម្មនុញ្ញ)។ម្យ៉ាងវិញទៀតនោះការពិនិត្យធម្មនុញ្ញភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺពឹងផ្អែកទៅលើរដ្ឋធម្មនុញ្ញតែមួយមុខប៉ុណ្ណោះ ពុំបានពិចារណាលើស្មារតីប៉ះពាល់សាមីជនដែលប្ដឹងអំពីរឿងអធម្មនុញ្ញភាពដោយសារ តែកម្ពុជាយើង ពុំធ្លាប់មានរឿងក្ដីបុគ្គលទាក់ទងនឹងអធម្មនុញ្ញភាពទើបពុំមានគោលការណ៍អធម្មនុញ្ញភាពក្រៅពីពិនិត្យខ្លឹមសារ ទម្រង់ ច្បាប់ ផ្ទៀងផ្ទាត់ទៅនឹងនឹងរដ្ឋធម្មនុញ្ញនោះទេ។

## កថាខណ្ឌទី២ បញ្ហាកើតឡើងនៅប្រទេសជប៉ុន

### ១.បញ្ហានៃការត្រួតពិនិត្យជាអាទិ៍កាលនៅស្ថាប័ននីតិប្រតិបត្តិតឹងរឹងជ្រុល

នៅប្រទេសជប៉ុនដោយសារតែការត្រួតពិនិត្យជាអាទិ៍កាលយ៉ាងតឹងរឹងពេក នៅក្រុមប្រឹក្សាអ្នកច្បាប់របស់គណរដ្ឋមន្ត្រី(ពោលគឺស្ថាប័ននីតិប្រតិបត្តិ) ធ្វើឱ្យមានផលប៉ះពាល់ដល់ការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព។ការត្រួតពិនិត្យនៅក្រុមប្រឹក្សាអ្នកច្បាប់ គឺច្បាប់ដែលបានបង្កើតឆ្លងកាត់ការត្រួតពិនិត្យមានលក្ខណៈម៉ត់ចត់តឹងរឹងបំផុត វាមានលទ្ធភាពដែលធ្វើឱ្យមានមន្ទិលគួរឱ្យសង្ស័យទៅលើការត្រួតពិនិត្យធម្មនុញ្ញភាព ជាបច្ឆាកាល ដែលមិនសូវមាន ការត្រួតពិនិត្យ ដោយតុលាការពីច្បាប់ដែលបានអនុម័ត និង ឱ្យប្រើប្រាស់។ពោលគឺដោយសារតែនៅក្រុមប្រឹក្សាអ្នកច្បាប់របស់គណៈរដ្ឋមន្ត្រីមានការពិនិត្យម៉ត់ចត់ពេក ធ្វើឱ្យច្បាប់នោះដាក់អនុវត្តពិបាកក្នុងការត្រួតពិនិត្យជាក្រោយ។ប្រសិនបើយើងមើលតែលើ ទិដ្ឋភាពខាងក្រៅរបស់ប្រព័ន្ធនៃការត្រួតពិនិត្យយ៉ាងតឹងរឹងនៅក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រី យើងឃើញថាស្ថាប័ននេះបានបំពេញតួនាទីយ៉ាងម៉ត់ចត់ក្នុងការធ្វើសេចក្តីព្រាងច្បាប់នីមួយៗ ឱ្យបានល្អដើម្បីកុំឱ្យសភាពិនិត្យ ឬក៏ពិបាកក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ឡើងវិញ ដោយគ្រាន់តែទទួលបានសេចក្តីព្រាងច្បាប់ហើយ អាចប្រជុំពិនិត្យនិងអនុម័តច្បាប់នោះបានលឿន ដោយមិនខ្ជះខ្ជាយពេលវេលាយូរ។ផ្ទុយទៅវិញប្រសិនបើ ក្រឡេកមើលតួនាទីត្រួតពិនិត្យធម្មនុញ្ញជាបច្ឆាកាលនៅតុលាការវិញ គឺតុលាការមិនអាចបំពេញតួនាទីរបស់ខ្លួនក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព ដោយត្រឹមត្រូវឡើយ ដោយសារតែក្រុមប្រឹក្សាអ្នកច្បាប់របស់គណរដ្ឋមន្ត្រីពិនិត្យយ៉ាងយកចិត្តទុកដាក់ឥតខ្ចោះពេក ធ្វើឱ្យតុលាការបាត់បង់តួនាទីរបស់ខ្លួនក្នុងការពិនិត្យជាអាទិកាល ហើយមើលទៅហាក់ដូចជា ក្រុមប្រឹក្សាអ្នកច្បាប់របស់គណៈរដ្ឋមន្ត្រីបានដណ្តើមតួនាទីត្រួតពិនិត្យធម្មនុញ្ញភាពពីស្ថាប័នតុលាការដោយប្រយោលរួចទៅហើយ។[49]

នៅក្នុងការអនុវត្តជាក់ស្តែង ត្រូវបានគេនិយាយថាតាំងពីក្រោយសង្គ្រាមលោកលើកទី២មកច្បាប់ដែលបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាអ្នកច្បាប់ នៅទីស្តីការគណរដ្ឋមន្ត្រីមិនសូវជាមានការចេញសេចក្តីសម្រេចថា អធម្មនុញ្ញដោយតុលាការកំពូលនោះទេ។ដូច្នេះយើងក្រឡេកទៅមើលបទដ្ឋានដែលនិយាយអំពីច្បាប់ដែលបានសម្រេចសេចក្តីថា អធម្មនុញ្ញដោយតុលាការកំពូល។ យោងតាមអ្នកស្រាវជ្រាវណាកាមឹរ៉ាអាគីរ៉ាក់(中村明 នៅឆ្នាំ ២០០១)បានចង្អុលបង្ហាញថាច្បាប់ដែលបានសម្រេចថាអធម្មនុញ្ញ គឺសុទ្ធតែជាច្បាប់ដែលមិនឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាអ្នកច្បាប់នៃគណរដ្ឋមន្ត្រី។ ពោលគឺប្រសិនបើដកក្រុមព្រហ្មទណ្ឌទាក់ទងទៅនឹងទណ្ឌកម្មចំពោះការ

[49] 佐藤岩夫「違憲審査制と内閣法制局」社會科學研究 56 巻 5、6 号（2005 年）88 頁
សាតុ អ៊ិវ៉ាអុ 「ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព និង ក្រុមប្រឹក្សាអ្នកច្បាប់នៅគណៈរដ្ឋមន្ត្រី」 ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម វ៉ុល ៥៦ លេខ ៥、៦ (ឆ្នាំ ២០០៥) ទំព័រ ៨៨

សម្លាប់បុព្វញាតិ(尊属殺重罰)មាត្រា២០០ (ដែលបានប្រកាសឱ្យប្រើប្រាស់នៅសម័យមេជិ)ចេញសេចក្តីសម្រេចមាត្រា៦វាក្យខណ្ឌ២ និង វាក្យខណ្ឌ៤នៃច្បាប់ស្តីអំពីការប្រើប្រាស់ឱសថ(薬事法)ដែលសម្រេចថាអធម្មនុញ្ញគឺច្បាប់នេះជាសេចក្តីព្រាងដែលធ្វើឡើងដោយរដ្ឋាភិបាលក៏ពិតមែនតែបញ្ហាត្រង់មាត្រា៦ វាក្យខណ្ឌ២ និងវាក្យខណ្ឌ៤ គឺជាចំណុចដែលត្រូវបានបន្ថែម ដោយសភាដូច្នេះវាមិនមែនជា បញ្ហារបស់ក្រុមប្រឹក្សាអ្នកច្បាប់នៅគណៈរដ្ឋមន្ត្រីឡើយ ដោយសារតែ មិនបានឆ្លងកាត់ការត្រួតពិនិត្យដោយក្រុមប្រឹក្សានេះផ្ទាល់។សេចក្តីសម្រេចនិងបញ្ហាដែលទាក់ទងទៅនឹងការវិសោធនកម្ម ច្បាប់បោះឆ្នោតមន្ត្រីរាជការគឺច្បាប់នេះបង្កើតដោយសមាជិកសភាដូច្នេះគឺមិនពាក់ព័ន្ធទៅនឹងការពិនិត្យរបស់ ក្រុមប្រឹក្សាអ្នកច្បាប់នៃ គណៈរដ្ឋមន្ត្រីឡើយ។ សេចក្តីសម្រេចទាក់ទងនឹងមាត្រា១៨៦នៃច្បាប់ព្រៃឈើដែលច្បាប់បង្កើតដោយក្រសួងកសិកម្ម និង ព្រៃឈើផ្ទាល់មិនបានឆ្លងកាត់ការត្រួតពិនិត្យ នៅក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីឡើយ គឺបញ្ជូនទៅឱ្យសមាជិកសភាបង្កើត និង ត្រួតពិនិត្យនៃគណកម្មការអេចិន្ត្រេ-យ៍រដ្ឋសភាប៉ុណ្ណោះ។ ពោលគឺដូចដែលបានឆ្លងកាត់ការត្រួតពិនិត្យដោយក្រុមប្រឹក្សាអ្នកច្បាប់នៃ គណៈរដ្ឋមន្ត្រី គឺមិនមានច្បាប់ណាដែលត្រូវបានសម្រេចថាអធម្មនុញ្ញដោយតុលាការកំពូលឡើយ (អ្នកស្រាវជ្រាវណាកាមឺរ៉ាអាគីរ៉ាក់ 中村明 ២០០១ ទំព័រ៣១ )។ក៏ប៉ុន្តែមានករណីពិសេសចំពោះសេចក្តីសម្រេច ដែលទើបចេញថ្មីៗនាពេលកន្លងមក គឺ អធម្មនុញ្ញភាពនៃច្បាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍(郵便法)។ច្បាប់នេះគឺជាច្បាប់ដែលបង្កើតឡើងដោយរដ្ឋាភិបាល នៅឆ្នាំ១៩៤៧ នេះគឺជាសម័យដែលជប៉ុនទើបតែចាញ់សង្គ្រាមភ្លាមៗហើយបានបង្កើតច្បាប់ជាច្រើនក្រោមប្រព័ន្ធថ្មី ដូចនេះបណ្តាលឱ្យមានបញ្ហាច្បាប់ខ្លះមិនត្រឹមតែប៉ុណ្ណោះ ពេលនោះការសន្និដ្ឋានទាក់ទងទៅនឹងនយោបាយGHQ ចង់ឱ្យលុបចោលក្រុមប្រឹក្សាអ្នកច្បាប់ផងនោះ ក៏ធ្វើការត្រួតពិនិត្យសេចក្តីព្រាងច្បាប់ផ្សេងៗសម័យនោះមានភាពខ្វះខាតមិនបានម៉ត់ចត់[50]។

ដូចនេះយោងតាមការរៀបរាប់ខាងលើ នូវអង្គហេតុជាក់ស្តែងជាបញ្ហានៅប្រទេសជប៉ុនកំពុងជួបប្រទះគឺ ដោយសារតែក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីមានប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាលយ៉ាងតឹងរឹងពេក គឺបានធ្វើឱ្យភាពចាំបាច់ក្នុងការពិនិត្យធម្មនុញ្ញភាពរបស់តុលាការជប៉ុនមានការធ្លាក់ចុះហើយជាលទ្ធផលនៅប្រទេសជប៉ុនសេចក្តីសម្រេចអធម្មនុញ្ញភាពនៃច្បាប់គឺមានតិចតួចបំផុត។

[50] 佐藤岩夫「違憲審査制と内閣法制局」社會科學研究 56 巻 5、6 号（2005 年）89 頁
សាតុ អ៊ិវ៉ាអុ 「ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព និង ក្រុមប្រឹក្សាអ្នកច្បាប់នៅគណៈរដ្ឋមន្ត្រី」 ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម វ៉ុល ៥៦ លេខ ៥、៦ (ឆ្នាំ ២០០៥) ទំព័រ ៨៩

## ២.បញ្ហាទ្រឹស្តីនៃការត្រួតពិនិត្យធម្មនុញ្ញភាព

នៅប្រទេសជប៉ុនគឺមានការរិះគន់ថា តុលាការកំពូលកំពុងឈរលើគោលជំហររបស់គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំងពេក(司法適極主義)។ គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំងពេក( 司法適極主義) គឺជាពាក្យបច្ចេកទេសដែលមានប្រភពកើតចេញពីវិវាទទ្រឹស្តី នៃការអនុវត្តសិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាព យ៉ាងវិជ្ជមានរបស់តុលាការកំពូលនៃសហរដ្ឋអាមេរិក។ គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំង គឺជាការកាត់សេចក្តីលើធម្មនុញ្ញភាពនៃច្បាប់ ដែលតុលាការឈរលើគោលជំហរឯករាជ្យ ដោយមិនគោរពលើសេចក្តីសម្រេចរបស់ស្ថាប័ននីតិបញ្ញត្តិឡើយ។ គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំងមានន័យថាជា ការធ្វើសេចក្តីសម្រេចអធម្មនុញ្ញ ដោយតុលាការធ្វើការត្រួតពិនិត្យធម្មនុញ្ញដោយគោរពសេចក្តីសម្រេច របស់ស្ថាប័ននីតិបញ្ញត្តិ។ តុលាការកំពូលរបស់ប្រទេសជប៉ុនពីបូរាណយោងតាមទ្រឹស្តីសុខុមាលភាពសាធារណៈ តែបច្ចុប្បន្នគឺយោងតាមទ្រឹស្តីផ្ចត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ(立法義量論) ដែលបង្ហាញពីអាកប្បកិរិយាការគោរពដ៏គួរឱ្យកត់សម្គាល់លើសេចក្តីសម្រេចរបស់សភា ហើយឈរលើគោលជំហរផ្ចត់គំនិតធ្វើច្បាប់របស់អង្គនីតិបញ្ញត្តិ(立法義量論)យ៉ាងខ្លាំងពិតប្រាកដ។

លើសពីនេះទៅទៀត ដែនកំណត់ដែលមកពីនីតិវិធីបណ្តឹងដែលមានន័យថាបណ្តឹងរបស់គូភាគីត្រូវបានដំណើរការបន្តដោយវិវាទដែនកំនត់សមត្ថកិច្ចវិនិច្ឆ័យរបស់តុលាការចំពោះបញ្ហាគោលនយោបាយ ដែលតុលាការគ្មានជំនាញបច្ចេកទេសនេះទេ បន្ថែមពីនេះទៅទៀត ការដែលស្ថាប័នយុត្តាធិការមិនមានភាពត្រឹមត្រូវបែបប្រជាធិបតេយ្យនោះគឺដោយសារមានបញ្ហានូវការវិនិច្ឆ័យរបស់ស្ថាប័ននីតិបញ្ញត្តិដែលភាពត្រឹមត្រូវបែបប្រជាធិបតេយ្យនោះគឺ ដោយសារមានបញ្ហាជាមូលដ្ឋានថាតើវាមិនផ្ទុយនឹងលទ្ធិប្រជាធិបតេយ្យទេដូច្នេះធ្វើឱ្យការគិតរបស់ស្ថាប័នតុលាការ គឺមិនស្របក្នុងការប្រើ គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំង។ដើម្បីអនុវត្តអំណាចត្រួតពិនិត្យធម្មនុ-ញ្ញភាពនៅស្ថាប័នតុលាការឱ្យបានត្រឹមត្រូវ ត្រូវតែបែងចែកការប្រើប្រាស់រវាង គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំងនិង ស្ថាប័នតុលាការ របៀបនៃការបែងចែកការប្រើប្រាស់នេះនៅជប៉ុនមានទ្រឹស្តីយ៉ាងទូលំទូលាយទាក់ទងទៅនឹងវា ហើយវាមានឈ្មោះថាទ្រឹស្តីមូលដ្ឋាននៃការត្រួតពិនិត្យត្រួតគ្នា( 二重の基準の理論)។នោះគឺមានន័យជាគោលការណ៍ដែលតុលាការទាមទារការប្រើគោលការណ៍នៃការប្រើប្រាស់ នូវប្រព័ន្ធយុត្តាធិការខ្លាំងពេក ចំពោះលិខិតបទដ្ឋានគតិយុត្តដែលកម្រិតនូវសេរីភាពខាងផ្លូវចិត្ត គឺជារចនាសម្ព័ន្ធ របស់ការត្រួតពិនិត្យធម្មនុញ្ញភាពដែល គេបានថែងនៅក្នុងសាលក្រម ឬ សាលដីកា របស់សហរដ្ឋអាមេរិក ហើយដោយសារតែមានមូលហេតុដែលវាមានភាពចាំបាច់ចំពោះការការពារដំណើរការលទ្ធិប្រជាធិបតេយ្យរបស់សេរីភាពខាងផ្លូវចិត្តក៏ដូចជា

ការគោរពសិទ្ធិមនុស្ស និង ស្វ័យភាពរបស់បុគ្គលដោយផ្ទាល់ជាដើម ទើបនៅក្នុងទ្រឹស្តីរបស់ប្រទេសជប៉ុនយ៉ាងច្រើនលើសលប់ អះអាងថាវាគឺត្រឹមត្រូវចំពោះការអនុវត្តតាមរចនាសម្ព័ន្ធរបស់ការត្រួតពិនិត្យធម្មនុញ្ញភាពនៅជប៉ុនផងដែរ។នៅក្នុងសាលដីកាតុលាការកំពូលរបស់ប្រទេសជប៉ុនបានសរសេរណែនាំពីទ្រឹស្តីមូលដ្ឋាននៃការត្រួតពិនិត្យត្រួតគ្នាផងដែរ ដូច្នេះអាចសន្និដ្ឋានថា តុលាការកំពូលនៃប្រទេសជប៉ុនទទួលយក ទ្រឹស្តីមូលដ្ឋាននៃការត្រួតពិនិត្យត្រួតគ្នា។ ក៏ប៉ុន្តែនៅក្នុងសេចក្តីសម្រេចអធម្មនុញ្ញភាពនៃច្បាប់របស់តុលាការកំពូលជប៉ុន គឺមិនមានសេចក្តីសម្រេចអធម្មនុញ្ញភាព ដែលទាក់ទងពីការកម្រិតសេរីភាពខាងផ្លូវចិត្តឡើយ ដូចនេះវាពិបាកនិយាយណាស់ថា តុលាការកំពូលបានត្រួតពិនិត្យធម្មនុញ្ញភាពយ៉ាងតឹងរ៉ឹងចំពោះច្បាប់ដែលកម្រិតសេរីភាពខាងផ្លូវចិត្ត។ ដូចនេះមិនអាចសន្និដ្ឋានបានថា តុលាការកំពូលជប៉ុនទទួលយក ទ្រឹស្តីមូលដ្ឋាននៃការត្រួតពិនិត្យត្រួតគ្នាឡើយ[51]។

ដូចដែលបានរៀបរាប់ខាងលើតុលាការកំពូលជប៉ុនគឺ បានឈរលើគោលជំហររបស់គោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការខ្លាំង(司法適極主義) ហើយមិនអាចបំពេញតួនាទីជាអ្នកការពាររដ្ឋធម្មនុញ្ញ ដោយប្រើអំណាចត្រួតពិនិត្យធម្មនុញ្ញភាពយ៉ាងត្រឹមត្រូវឡើយ។ហេតុអ្វីបានជាតុលាការកំពូលមិនអាចអនុវត្ត សិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាពជាវិជ្ជមាន? ចំពោះចំណុចអាចនិយាយថា មានមូលហេតុជាច្រើន ក៏ប៉ុន្តែបច្ចុប្បន្នមានការរិះគន់ថាបញ្ហាមកពីតុលាការកំពូលដែលជាតុលាការជាន់ខ្ពស់បំផុត។រហូតមកដល់ពេលនេះមិនមានការកម្រិតបណ្តឹងសារទុក្ខ ក្នុងនីតិវិធីរដ្ឋប្បវេណីឡើយនាំឱ្យមានបណ្តឹងសារទុក្ខយ៉ាងច្រើនសន្ធឹកសន្ធាប់។ ដូច្នេះដោយសារតែតុលាការកំពូលទទួលជំនុំជម្រះបណ្តឹងសារទុក្ខច្រើនបែបនេះ(ចៅក្រមតុលាការកំពូលម្នាក់ទទួលបណ្តឹងចាប់ពី៣០០បណ្តឹងឡើងទៅ)ធ្វើឱ្យតុលាការកំពូលមិនមានពេលគ្រប់គ្រាន់ក្នុងការស្រាវជ្រាវពិនិត្យបញ្ហារបស់រដ្ឋធម្មនុញ្ញឱ្យត្រឹមត្រូវ និង គ្រប់ជ្រុងជ្រោយឡើយ។បន្ថែមពីកិច្ចការងារដ៏មមាញឹកផង ចៅក្រមនៃតុលាការកំពូល ដើម្បីដោះស្រាយបញ្ហារបស់រដ្ឋធម្មនុញ្ញថ្មី គឺបើកសវនាការធំ ធ្វើឱ្យក្លាយទៅជាផលអវិជ្ជមានវិញ។ជាលទ្ធផល ក្នុងការអនុវត្តជាក់ស្តែង បញ្ហារដ្ឋធម្មនុញ្ញដែលបានវិនិច្ឆ័យនៅក្នុងសវនាការធំហើយ គឺត្រូវយកមកប្រើនៅសវនាការធម្មតា ហើយពេលលើកសេចក្តីសម្រេចរបស់សវនាការជំនុំជម្រះធំឡើង គឺចេញសេចក្តីសម្រេចថាមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ ពោលគឺ ការសម្រេចរបស់សវនាការធម្មតាគឺគ្មានអធម្មនុញ្ញភាពកាន់តែច្រើនឡើង។ ក្រោយមកគេបានធ្វើវិសោធនកម្មច្បាប់នីតិវិធីរដ្ឋប្បវេណី ដោយកម្រិតនូវបណ្តឹងសារទុក្ខរបស់នីតិវិធីរដ្ឋប្បវេណី(ដាក់ឱ្យប្រើខែមករា

[51] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）110 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឺមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១១០

ឆ្នាំ១៩៩៨)មិនថាក្នុងនីតិវិធីរដ្ឋប្បវេណី ឬ នីតិវិធីព្រហ្មទណ្ឌឡើយ បើចង់អះអាងអំពីការផ្ទុយនឹងរដ្ឋធម្មនុញ្ញអាចធ្វើតាមរយៈបណ្តឹងសារទុក្ខបាន ដូច្នេះដោយសារមានការទទួលតាមរយៈបណ្តឹងសារទុក្ខធ្វើឱ្យមានការអះអាង ពីអធម្មនុញ្ញភាពច្រើនឡើង។ មានមតិខ្លះលើកឡើងថាចៅក្រមតុលាការកំពូល ដោយមានគំនិតគិតថាខ្លួនគឺជាចៅក្រមដែលមានឋានៈខ្ពស់ មានកាតព្វកិច្ចការងាររបស់ខ្លួនដោយបកស្រាយច្បាប់ជារួមនោះ កាតព្វកិច្ចការងារដែលត្រូវការភាពចាំបាច់ផ្នែកនយោបាយ ដូចជាការបកស្រាយរដ្ឋធម្មនុញ្ញតាមបែបពិចារណាលើននយោបាយនឹងត្រូវបានចៅក្រមទាំងនោះគិតថាមិនមែនជាកាតព្វកិច្ចការងាររបស់ខ្លួនតាំងពីដើមមកឡើយ[52]។

បន្ថែមពីនេះទៅទៀត ក៏មានបញ្ហាក្នុងការជ្រើសរើសបេក្ខភាពចៅក្រមតុលាការកំពូល។នៅក្នុងរដ្ឋធម្មនុញ្ញមានចែងផ្តល់អំណាចឱ្យគណៈរដ្ឋមន្ត្រីមានអំណាចតែងតាំង ចាត់តាំង ចៅក្រមតុលាការកំពូល ហើយច្បាប់តុលាការក៏បានចែងពីលក្ខខណ្ឌក្នុងការតែងតាំងថា ជាបេក្ខភាពដែលមានចំណេះដឹងខ្ពង់ខ្ពស់ខាងផ្នែកច្បាប់ និង មានអាយុចាប់ពី៤០ឆ្នាំឡើងទៅ(មាត្រា៤១)(ក៏ប៉ុន្តែបេក្ខជន១០រូបក្នុងចំណោម១៥នាក់ គឺត្រូវតែបុគ្គលដែលធ្លាប់ជាចៅក្រមមេធាវីមានបទពិសោធន៍កំណត់ថាប៉ុន្មានឆ្នាំ)។តែចំពោះការអនុវត្តជាក់ស្តែងគឺមានចៅក្រម៦រូប មេធាវី៤រូប ព្រះរាជអាជ្ញា២រូប អ្នកជំនាញការច្បាប់ ៣រូប(អ្នកការទូត១រូប មន្ត្រីរបស់នាយកដ្ឋាននីតិកម្មនៃគណរដ្ឋមន្ត្រី១រូប អ្នកច្បាប់១រូប)។ក្នុងករណីខ្លះចៅក្រមតុលាការកំពូល គឺតុលាការទទួលតាមការណែនាំស្ថាប័នដើមរបស់ចៅក្រមនោះ (ឧទាហរណ៍បើជាមេធាវី ត្រូវជាសមាជិកនៃគណៈមេធាវី បើជាព្រះរាជអាជ្ញា គឺជាព្រះរាជអាជ្ញាដែលមានឋានៈខ្ពស់ ឬ ជាសិស្សច្បងរបស់ព្រះរាជអាជ្ញាទាំងឡាយ ហើយ សម្រេចពីបេក្ខជនរួចក៏ជូនដំណឹងទៅគណៈរដ្ឋមន្ត្រី។ប្រសិនបើមិនមែនជាភ្នែក ជាច្រមុះរបស់គណៈរដ្ឋមន្ត្រីទេប្រាកដណាស់ គឺមិនអាចត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូលឡើយ តែមិនមែនសុទ្ធតែជាចៅក្រមតុលាការកំពូលដែលលេចធ្លោបែបនយោបាយឡើយ។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងការដែលមានប្រភពនៃប្រភេទការងារផ្សេងៗគ្នា របស់តុលាការកំពូល ដែលជាតុលាការជាន់ខ្ពស់បំផុត ហើយការប្រជុំសម្រេចជ្រើសរើសបេក្ខជនយ៉ាងសម្ងាត់នោះគឺវាពិបាកធានាថា ជាបុគ្គលស័ក្តិសមជាចៅក្រមមួយរូបក្នុងនាមជាអ្នកការពាររដ្ឋធម្មនុញ្ញ[53]។

---

[52] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）110 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឺមេ  កាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១១០

[53] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）111 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឺមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១១១

ដូចដែលបានរៀបរាប់ខាងលើ ក្រៅពីបញ្ហាការតែងតាំងចៅក្រមតុលាការកំពូលក៏មានបញ្ហាដែលតុលាការកំពូលទទួលយកគោលការណ៍នៃការប្រើប្រាស់នូវប្រព័ន្ធយុត្តាធិការ(司法適極主義)ដែលជាគោលការណ៍នោះខ្លាំងពេក។ ឧទាហរណ៍ចៅក្រមតុលាការកំពូល នៅក្នុងកិច្ចការផ្ទៃក្នុងរបស់តុលាការកំពូល មានគំនិតគោរពនូវសន្តិភាពហើយក៏មានមតិលើកឡើងមកផងដែរ ថា តើមិនមែនដោយសារមានគំនិតគោរពផ្អៀងទៅរកស្ថាប័ននីតិប្រតិបត្តិទេ ឬ ?

លើសពីនេះទៅទៀតមូលហេតុដែលប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពរបស់ប្រទេសជប៉ុនមិនអាចដំណើរការបានល្អគឺក៏អាចលើកឡើងថាមកពីការបង្កើតប្រព័ន្ធនីតិវិធី។វិវាទនៃការអនុវត្តចំពោះអំណាចសាធារណៈរបស់ស្ថាប័ននីតិប្រតិបត្តិដែលមានដូចជានីតិវិធីរដ្ឋបាលនោះ គឺប្រភេទបណ្ដឹង ឬ ផ្លូវនៃបណ្ដឹង មានលក្ខណៈចង្អៀតដែរ។ដូចនេះករណីដែលគ្មានវិវាទសកម្មភាពដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញតុលាការច្រានចោលក៏មានច្រើនផងដែរ។នៅប្រទេសជប៉ុន រឿងក្ដីស្មុគស្មាញដែលជាប់ជំពាក់ជាមួយបញ្ហារដ្ឋធម្មនុញ្ញពេលខ្លះប្រើពេលយូរទៅ តុលាការពិបាកក្នុងការបដិសេធនូវស្ថានភាពចំណុចវិវាទដែលចំណាយពេលកាត់ក្ដីយូរ[54]។

មូលហេតុមួយទៀត ដែលធ្វើឱ្យប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព របស់ប្រទេសជប៉ុនមិនអាចដំណើរការបានល្អនោះគឺបញ្ហាទំនាក់ទំនងរវាងតុលាការជាន់ទាប និង តុលាការកំពូល។ដើម្បីអនុវត្តឱ្យត្រឹមត្រូវនូវប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបែបស្ថាប័នយុត្តាធិការ តុលាការជាន់ទាបនៅក្នុងនីតិវិធីគឺធ្វើការសិក្សាពីអង្គហេតុយ៉ាងជាក់លាក់ ហើយវិនិច្ឆ័យពីធម្មនុញ្ញភាព។បន្ទាប់មកតុលាការកំពូលពិនិត្យបន្ថែមពីលើសេចក្ដីសម្រេចរបស់តុលាការជាន់ទាប និង កំណត់ពីអត្ថន័យរបស់រដ្ឋធម្មនុញ្ញ។ នេះគឺជាទំនាក់ទំនងរវាងតុលាការជាន់ទាបនិង តុលាការកំពូលដែលត្រូវតែបំពេញមុខងារយ៉ាងរលូន និង ពិភាក្សាគ្នាទៅវិញទៅមក។ ក៏ប៉ុន្តែមានការសង្ស័យថាតើចៅក្រមតុលាការជាន់ទាប ពិតជាអាចធ្វើសេចក្ដីសម្រេចដោយសេរីដោយ មិនមានរងឥទ្ធិពល ពីខាងតុលាការកំពូលទេឬយ៉ាងណា។ឧទាហរណ៍ដូចជា មានការលើកឡើងថា នៅពេលដែលចៅក្រមធ្វើការបកស្រាយរដ្ឋធម្មនុញ្ញខុសពីការបកស្រាយរដ្ឋធម្មនុញ្ញរបស់តុលាការកំពូលនោះ មិនរើសអើងដោយសារតែមុខតំណែង ឬ ឋានៈជាដើមទេឬ។ពោលគឺ ច្បាប់ដែលតុលាការកំពូលចេញសេចក្ដីសម្រេចថា មិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ តែបែរជាតុលាការជាន់ទាប ចេញសេចក្ដីសម្រេចថា អធម្មនុញ្ញនោះ ក្រោយមកត្រូវបានគេវាយ

[54] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）112 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្រ្ត រិស្សឹមេកាន ឆ្នាំ២០០៤ លេខ ២ （វ៉ុល ២៩៤） ទំព័រ ១១២

ការណ៍ពីលទ្ធផលស្រាវជ្រាវថា ចៅក្រមនោះត្រូវបានផ្លាស់ប្តូរឱ្យធ្វើការនៅតុលាការផ្សេងទៀតយ៉ាងយូរផងដែរ[55]។

បញ្ហាចុងក្រោយនេះ គឺបញ្ហាដែលគណបក្សសេរីភាពប្រជាធិបតេយ្យកាន់អំណាចគ្រប់គ្រងក្បាលម៉ាស៊ីនយ៉ាងយូរប្រហែលជាង៥៥ឆ្នាំបន្តជាប់គ្នាជារៀងរហូត ដែលជាបញ្ហាផ្នែកនយោបាយដែលមិនអាចមើលរំលងបាននូវការកាន់អំណាច។ដូចដែលបានរៀបរាប់ខាងលើ ដោយសារតែការជ្រើសរើសបេក្ខភាពចៅក្រមតុលាការកំពូល និង សិទ្ធិក្នុងការតែងតាំងត្រូវបានកាន់កាប់ដោយគណៈរដ្ឋមន្ត្រី ចៅក្រមតុលាការមិនអាចធ្វើការផ្ទុយពីគោលគំនិតរបស់គណៈរដ្ឋមន្ត្រីបានឡើយ។ម្យ៉ាងវិញទៀត ដោយសារតែមិនមាន ការផ្លាស់ប្តូរគណបក្សកាន់អំណាច ពោលគឺមានគណបក្សកាន់អំណាចតែមួយ ដែលកាន់តំណែងយូរទៅធ្វើឱ្យពួកគេអាចគ្រប់គ្រងលើមុខងាររបស់ចៅក្រមតុលាការកំពូល ដែលទាមទារសុទ្ធតែជាមនុស្សដែលនៅជិតស្និតនឹងគណបក្សដែលកាន់អំណាចយូរនោះ។ ដូចនេះដោយសារតែតុលាការកំពូលស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋាភិបាលកាន់អំណាចនោះយូរទៅ ធ្វើឱ្យបញ្ហាឯករាជ្យភាពរបស់តុលាការកំពូល ពិបាកក្នុងការដោះស្រាយយ៉ាងខ្លាំង[56]។

[55] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）113 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឺមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១១៣

[56] 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号）113 頁
ម៉ាសាអុ អ៊ិឈិកាវ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」 សាកលវិទ្យាល័យនីតិសាស្ត្រ រិស្សឺមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤) ទំព័រ ១១៣

## ផ្នែកទី២ ដំណោះស្រាយលើបញ្ហាត្រួតពិនិត្យធម្មនុញ្ញភាពនៃប្រព័ន្ធទាំងពីរ

ថ្វីត្បិតតែប្រព័ន្ធ នៃការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន និង ប្រទេសកម្ពុជាប្រព្រឹត្តទៅសព្វថ្ងៃមែន ប៉ុន្តែការអនុវត្តកន្លងមកគឺស្តែងចេញឡើងជាបញ្ហាចំពោះការអនុវត្តមួយចំនួន ដែលចាំបាច់គប្បីគួរតែធ្វើការដោះស្រាយ ដើម្បីប្រទេសឈានទៅរកនីតិរដ្ឋ។

### កថាខណ្ឌទី១ ចំពោះប្រទេសកម្ពុជា

ចំពោះបញ្ហានៃសមាជិកភាពនៃក្រុមប្រឹក្សាធម្មនុញ្ញកន្លងមកឃើញថាមានបញ្ហាទាក់ទងទៅនឹងជំនាញ គឺលក្ខខណ្ឌរើសជំនាញហាក់ដូចជា ជាពុំមែនជាអ្នកជំនាញផ្នែកនីតិរដ្ឋធម្មនុញ្ញនោះឡើយ។ដូច្នេះគួរតែជ្រើសរើសបេក្ខជនដែលជាបេក្ខភាពណាដែលមានបទពិសោធន៍ និង ជំនាញផ្នែកនីតិរដ្ឋធម្មនុញ្ញឱ្យបាន ដោយចៀសវាងនៅការរើសជំនាញមិនច្បាស់លាស់សម្រាប់ សមាជិកដែលចូលរួមត្រួតពិនិត្យធម្មនុញ្ញភាព ។ ម្យ៉ាងវិញទៀតសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែជាបុគ្គលឥស្សរជន ដោយឯករាជ្យ មិនត្រូវឱ្យមានពាក់ព័ន្ធនឹងអំណាចដែលជាបេក្ខជនមានប្រភពការងារមកពីស្ថាប័នផ្សេងៗហើយនៅប្រកាន់អំណាចរបស់ខ្លួនឡើយ។ជាក់ស្តែងលោកបណ្ឌិត **ឈុន ណារ៉េត** បានសរសេររៀបរាប់ក្នុងសៀវភៅនីតិរដ្ឋធម្មនុញ្ញថា ក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវនៅក្នុងប្រព័ន្ធតុលាការនោះទេ ពីព្រោះយើងបានបែងចែកអំណាចរដ្ឋទាំងបីឱ្យនៅឯករាជ្យពីគ្នា តើអ្នកណាជាអ្នកត្រួតពិនិត្យថា អំណាចណាមួយរំលោភលើអំណាចណាមួយនោះ?តុលាការជាអ្នកផ្តន្ទាទោសចំពោះជនណារំលោភលើច្បាប់និង ត្រួតពិនិត្យអំពីនីត្យានុកូលភាព ដោយឡែកក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ និង ត្រួតធម្មនុញ្ញភាពនៃច្បាប់តែប៉ុណ្ណោះ។ដូច្នេះការសរសេររៀបរាប់នេះមានន័យថាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញចាំបាច់ត្រូវតែជាបុគ្គលឯករាជ្យទើបស្ថាប័នក្រុមប្រឹក្សានេះឯករាជ្យ។

ចំពោះការពិនិត្យត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិ៍កាលនោះមានលក្ខណៈរហ័សលឿនម្យ៉ាងទោះបីជាមាត្រាខ្លះ រឹតត្បិតទាក់ទងទៅ នឹងការចែងក្នុងមាត្រានៃរដ្ឋធម្មនុញ្ញក៏ដោយ ក៏ក្រុមប្រឹក្សាធម្មនុញ្ញពេលខ្លះពិនិត្យ និង ចេញសេចក្តីសម្រេចថាស្របនឹងរដ្ឋធម្មនុញ្ញ។វាជាបញ្ហាមួយដែលពាក់ព័ន្ធទៅនឹងអំណាច ឬក៏ឥទ្ធិពលនយោបាយទៅលើក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះចាំបាច់គួរតែធ្វើការពិនិត្យឱ្យម៉ត់ចត់ និង ផ្តល់សិទ្ធទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញឱ្យទូលាយជាងពេលបច្ចុប្បន្ន។

### កថាខណ្ឌទី២ ចំពោះប្រទេសជប៉ុន

ទាក់ទងទៅនឹងដំណោះស្រាយបញ្ហារបស់ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព នៃប្រទេសជប៉ុនដូចដែលបានរៀបរាប់ខាងលើនេះគឺ មានមតិជាច្រើនលើកឡើងឱ្យ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញប្រទេសជប៉ុននាពេលបច្ចុប្បន្នដោយ ប្តូរពីប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញភាព ដោយតុលាការដែលជាស្ថាប័នកំពូលនោះទៅជាតុលាការរដ្ឋធម្មនុញ្ញវិញ។ ក៏ប៉ុន្តែដោយសារតែរដ្ឋធម្មនុញ្ញប្រទេសជប៉ុនគឺជារដ្ឋធម្មនុញ្ញដែលមានភាពតឹងរ៉ឹងខ្លាំង ដូចនេះវាពិបាកក្នុងការធ្វើវិសោធនកម្មយ៉ាងខ្លាំង។ រដ្ឋធម្មនុញ្ញប្រទេសជប៉ុនមកដល់បច្ចុប្បន្ន មិនធ្លាប់បានធ្វើវិសោធនកម្មម្តងឡើយហើយក៏មានមតិលើកឡើងថា គួរតែបង្កើតផ្នែករដ្ឋធម្មនុញ្ញដែលត្រួតពិនិត្យជាឯកទេសទៅលើបញ្ហារដ្ឋធម្មនុញ្ញឬ គួរតែបង្កើតតុលាការជាន់ខ្ពស់ពិសេសហើយទទួលនូវប្រព័ន្ធដែលទទួលយក ការបញ្ជូនទៅតុលាការកំពូលតែរឿងក្តីសំខាន់ជាពិសេសឬ ក៏ តុលាការជាន់ទាបបញ្ជូនទៅតុលាការកំពូលតែរឿងក្តីដែលទាមទារការត្រួតពិនិត្យវិនិច្ឆ័យ តែបញ្ហារដ្ឋធម្មនុញ្ញទៅតុលាការកំពូល។

ប្រសិនបើបង្កើតតុលាការធម្មនុញ្ញ គឺតុលាការអាចដំណើរការនីតិវិធីត្រួតពិនិត្យធម្មនុញ្ញបានកាន់តែលឿនជាងពីមុន។ ពួកអ្នកស្រាវជ្រាវថា អំពីការបង្កើតតុលាការធម្មនុញ្ញបានលើកឡើងថាតុលាការធម្មនុញ្ញ គឺអាចចេញសេចក្តីសម្រេចដែលការពារសិទ្ធិមនុស្សបានយ៉ាងត្រឹមត្រូវ។ហេតុអ្វីបានជាតុលាការធម្មនុញ្ញ គឺមានលទ្ធភាពក្នុងការចេញសេចក្តីសម្រេចដែលអាចការពារសិទ្ធិមនុស្សបានយ៉ាងត្រឹមត្រូវជាងតុលាការកំពូលបច្ចុប្បន្ន? ទាក់ទងទៅនឹងចំណុចនេះការជជែកវែកញែកពិភាក្សាគ្នារឿងការបង្កើត តុលាការធម្មនុញ្ញនឹងអាចជ្រើសរើសយ៉ាងត្រឹមត្រូវ ហើយចៅក្រមតុលាការធម្មនុញ្ញនេះផងដែរគឺមានចំណេះដឹងខុសពីតុលាការកំពូលបច្ចុប្បន្ន និងអាចធ្វើឱ្យប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពរបស់ ប្រទេសជប៉ុនចេញជាលទ្ធផលយ៉ាងវិជ្ជមាន។ពោលគឺតុលាការធម្មនុ-ញ្ញជាស្ថាប័នដែលមានឯកទេសខាងត្រួតពិនិត្យធម្មនុញ្ញភាព ហើយចៅក្រមគឺសុទ្ធតែមានសមត្ថភាព និង ចំណេះដឹងទាក់ទងនឹងការត្រួតពិនិត្យធម្មនុញ្ញភាព នោះធ្វើឱ្យប្រព័ន្ធនៃការត្រួតពិនិត្យធម្ម-នុញ្ញភាពរបស់ ប្រទេសជប៉ុនអាចដំណើរការទៅបានកាន់តែប្រសើរជាងពីមុន។ទាក់ទងទៅនឹងការតែងតាំងចៅក្រមផងដែរ យោងតាមរបាយការណ៍របស់គណៈកម្មាធិការកំណែទម្រង់ប្រព័ន្ធយុត្តាធិការរបស់ប្រទេសជប៉ុន បានលើកឡើងថា គួរតែមានការពិចារណាទៅលើចំណុចជាសារវ័ន្តនៃឋា-នៈរបស់ចៅក្រមតុលាការកំពូល ហើយទន្ទឹមនឹងនេះ អំពីដំណើរនៃការជ្រើសរើសនេះគួរតែមានការសិក្សាឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមានការការពារច្បាស់និងភាពមានគោលដៅ។គណៈរដ្ឋមន្ត្រីផងដែរគឺធ្វើការគោរពទៅតាមការសម្រេចចិត្តរបស់គណៈកម្មាការតែងតាំងចៅក្រម ដោយមិនលូកដៃចូល

លើការតែងតាំង ផ្លាស់ប្តូរតំណែង ឬ ការតម្លើងតំណែងឡើយ ដោយខ្លួនគ្រាន់តែចាំបញ្ជីឈ្មោះតែងតាំង បញ្ឍប់ផ្សេងៗត្រូវធ្វើពីគណៈកម្មការនោះតែម្តង។

ទន្ទឹមនឹងនេះការបកស្រាយរដ្ឋធម្មនុញ្ញ អាចមានភាពជារូមព្រោះដោយសារប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពបច្ចុប្បន្នផ្តល់អំណាចឱ្យតុលាការគ្រប់ជាន់ថ្នាក់ជាអ្នកបកស្រាយ ឬ អាចត្រួតពិនិត្យធម្មនុញ្ញភាពបានដូច្នេះលទ្ធភាពនៃការបកស្រាយរដ្ឋធម្មនុញ្ញ គឺអាចមានភាពខុសគ្នាខ្ពស់មួយកម្រិតដែរ។

តាមរយៈការបង្កើតតុលាការរដ្ឋធម្មនុញ្ញនេះគឺអាចធ្វើឱ្យសភា និង រដ្ឋាភិបាលគោរព និង អនុវត្តតាមសេចក្តីសម្រេចរបស់តុលាការរដ្ឋធម្មនុញ្ញកាន់តែខ្ជាប់ខ្ជួនជាងមុន ដោយមិនមានរងឥទ្ធិពលពីអំណាចនីតិបញ្ញត្តិ និង អំណាចនីតិប្រតិបត្តិទៀតឡើយ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវខាងលើរួចមកហើយយើងអាចធ្វើការសន្និដ្ឋានមួយបានថា ដើមកំណើតនៃការត្រួតពិនិត្យធម្មនុញ្ញភាពគឺមានកំណើតដំបូងនៅចក្រភពអង់គ្លេស ហើយក៏បានជ្រួតជ្រាបជះឥទ្ធិពលទៅលើប្រទេសដទៃជាច្រើនហូរហែ ដែលប្រទេស ឬ រដ្ឋខ្លះ គេហៅថា តុលាការធម្មនុញ្ញ ឬ ក្រុមប្រឹក្សាធម្មនុញ្ញ ឬ គណៈកម្មការកំពូលត្រួតពិនិត្យធម្មនុញ្ញ ជាដើម។ការពិនិត្យធម្មនុញ្ញភាពគឺជាការស្វែងរកភាពត្រឹមត្រូវច្បាស់លាស់ ដោយមិនបំពារបំពានលើរដ្ឋធម្មនុញ្ញ ដែលរដ្ឋបានសរសេរក្នុងច្បាប់កំពូលមួយនេះ ដោយពុំឱ្យច្បាប់ណាមួយបញ្ញត្តិផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនោះឡើយ។

នៅព្រះរាជាណាចក្រកម្ពុជាយើង ចាប់តាំងពីព្រះមហាក្សត្រប្រទានដល់ប្រជារាស្ត្រព្រះអង្គនូវរដ្ឋធម្មនុញ្ញដំបូងបំផុតនាថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៤៧ ដែលបានកែប្រែបន្តបន្ទាប់រហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ១៩៦៤ រហូតមកដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ដល់១៩៨៩)ក៏ដូចជាសម័យរដ្ឋកម្ពុជា(១៩៨៩ដល់១៩៩៣)ពុំដែលមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពឡើយ លើកលែងតែ ក្នុងសម័យសាធារណរដ្ឋខ្មែរ(១៩៧០ ដល់១៩៧៥) ដែលមានតុលាការធម្មនុញ្ញ តែគេត្រួតពិនិត្យតែលើវិវាទបោះឆ្នោតប៉ុណ្ណោះ មិនបានត្រួតពិនិត្យធម្មនុញ្ញភាពឡើយ។ រហូតមកដល់ឆ្នាំ ១៩៩៣ ទើបយើងមានរដ្ឋធម្មនុញ្ញឈ្មោះថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ នេះសបញ្ជាក់ឱ្យយើងដឹងថា នេះគឺជាការវិលត្រឡប់ទៅរកឥទ្ធិពលនៃបស្ចឹមប្រទេសជាថ្មីម្តងទៀត។ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាយើងគឺ ចាប់ផ្តើមដំណើរការនៅខែមិថុនាឆ្នាំ១៩៩៨ គឺក្រោយរដ្ឋសភា បានអនុម័តច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា និង ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានសមាជិកទាំងអស់៩រូបត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅ ដែលមានជំនាញខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ចហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច១៥ឆ្នាំ។ សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ៣រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម៣រូប ហើយ ៣រូបទៀត ត្រូវជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល[57]។ក្នុងរយៈពេលបីឆ្នាំម្តង សមាជិកចំនួន៣ រូប ត្រូវផ្លាស់ប្តូរ និងតែងតាំងជាថ្មី គឺ ១រូបតែងតាំងដោយព្រះមហាក្សត្រ ១រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១រូបទៀត

[57] មាត្រា៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ជ្រើសតាំងដោយរដ្ឋសភា[58] ។ការត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសកម្ពុជាអាចប្រព្រឹត្តទៅជាអាទិ-កាល និង បច្ឆាកាល។ចំពោះការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាលក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យសេចក្តីព្រាងផ្សេងៗ ឬ សេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញដែលព្រះមហាក្សត្រត្រូវតែពិគ្រោះយោបល់ក្រុមប្រឹក្សាធម្មនុញ្ញជាមុន។មាត្រា១៨៣ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។ក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬ វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និង បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ត្រូវដាក់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ។មាត្រា១៤០ថ្មីវាក្យខណ្ឌទី២នៃ រដ្ឋធម្មនុញ្ញចែងថា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ។រីឯមាត្រា១៦ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា ច្បាប់រៀបចំអង្គការ និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ ក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់នោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មិននឹងប្រកាសឱ្យប្រើ។បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ក្រោយពីព្រឹទ្ធសភាអនុម័តរួចត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានព្រឹទ្ធសភាដើម្បីពិនិត្យតើបទបញ្ជាផ្ទៃក្នុងស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងប្រកាសឱ្យប្រើ។ការពិនិត្យធម្មនុញ្ញភាពជាអាទិកាលនេះ មាត្រា១៧ថ្មីនៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្ម-នុញ្ញបានចែងថា ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬ សមាជិករដ្ឋសភាចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ។ រីឯការត្រួតពិនិត្យច្បាប់ជាបច្ឆាកាល យោងតាមមាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬ តុលាការ អាចស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។ ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្ម-នុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬ ប្រធានព្រឹទ្ធសភា ។ចំណែកឯគោលការណ៍ នៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៅកម្ពុជាឃើញថា ក្រុម

[58] មាត្រា៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យទាំងទម្រង់ និង គតិទាំងស្រុងនៃច្បាប់ដែលសុំឱ្យពិនិត្យ រួចផ្ទៀងផ្ទាត់ទៅនឹងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ។

ថ្វីត្បិតតែក្រុមប្រឹក្សាធម្មនុញ្ញគឺ ជាស្ថាប័នមួយដែលឯករាជ្យ នៅក្នុងការត្រួតពិនិត្យច្បាប់នៅកម្ពុជា ប៉ុន្តែក៏នៅមានចំណុចអវិជ្ជមានមួយដែលជាបញ្ហាបានកើតឡើង នៅក្នុងការអនុវត្តរបស់ខ្លួននាពេលសព្វថ្ងៃនេះ**បញ្ហាទី១** គឺទាក់ទងទៅនឹងបញ្ហាសមាជិកភាព យើងឃើញថា សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ គឺហាក់ដូចជាអ្នកដែលពុំទាន់មានជំនាញច្បាស់លាស់នៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព គឺពុំមែនជាអ្នកជំនាញផ្នែកនីតិរដ្ឋធម្មនុញ្ញនោះឡើយ។ចំពោះការតែងតាំង និង ជ្រើសតាំងសមាជិកមួយចំនួនខ្លះ គឺមានបញ្ហាត្រង់វិសមតភាពការងារ ដែលបម្រើការងារជាតំណាងរាស្ត្រផង និង ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញផង ។ម្យ៉ាងទៀតបើស្ថាប័ននេះឯករាជ្យ បុគ្គលក៏ត្រូវឯករាជ្យដែរ គួរពុំរើសចេញពីបុគ្គល ដែលមាននិន្នាការនយោបាយ ឬ ពីថៅក្រុមដែលជាស្ថាប័នផ្នែកនីតិឯករាជ្យមកធ្វើការឡូកឡំនឹងស្ថាប័នពិនិត្យច្បាប់ទៅវិញ។ **បញ្ហាទី២** គឺច្បាប់ដែលត្រួតពិនិត្យជាអាទិកាលគឺមានភាពរហ័សដែលមានមតិខ្លះថា ពុំបានពិនិត្យគ្រប់ជ្រុងជ្រោយនោះឡើយ តួយ៉ាងច្បាប់ស្តីពីសហជីពកម្មករ ជាដើម គឺរឹតត្បិត ទៅលើសិទ្ធិបង្កើតសហជីព។ **បញ្ហាទី៣** គឺក្រុមប្រឹក្សាធម្មនុញ្ញ ពុំទាន់មានមូលដ្ឋានគ្រឹះនៃគោលការណ៍ត្រួតពិនិត្យធម្មនុញ្ញភាពច្បាស់លាស់នោះទេ មកទល់នឹងបច្ចុប្បន្នពុំទាន់មានចេញសេចក្តីពន្យល់ ឬ បញ្ញត្តិណាមួយដែលបញ្ជាក់អំពីថា ដូចម្តេចទៅដែលហៅថាអធម្មនុញ្ញភាព?គឺនៅតែជាចម្ងល់នៅក្នុងការអនុវត្ត។ ឆ្លើយតបទៅនឹងបញ្ហា ដែលចោទឡើងខាងលើគប្បីគួរតែក្រុមប្រឹក្សាធម្មនុញ្ញមានបុគ្គលឯករាជ្យក្នុងការដំណើរការ និង រៀបចំប្រព្រឹត្តទៅរបស់ខ្លួនដោយពុំត្រូវរើសចេញពីគណបក្សនយោបាយ ឬ បុគ្គលដែលមាននិន្នាការទៅខាងណានោះទេ។ ចំណែកឯការត្រួតពិនិត្យធម្មនុញ្ញភាពរហ័សនោះ គឺគួរតែពិចារណាលើសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ដែលអនុម័តនោះ ឱ្យល្អិតល្អន់ លើសិទ្ធិមនុស្ស ក៏ដូចជាពាក់ព័ន្ធទៅនឹងសិទ្ធិបុគ្គលដែលជាគ្រឹះនៃប្រទេសប្រជាធិបតេយ្យ។ទន្ទឹមនឹងនេះក្រុមប្រឹក្សាធម្មនុញ្ញគួរតែមានគោលការណ៍ឬ និយមន័យនៃពាក្យអធម្មនុញ្ញ?ដើម្បីជាការកំណត់គោលការណ៍មួយក្នុងការអនុវត្តពិនិត្យច្បាប់ផ្សេងៗឱ្យមានប្រសិទ្ធភាពចៀសវៀសការពិនិត្យ និង បកស្រាយច្បាប់ តាមការយល់ឃើញខុសៗគ្នា។

ចំណែកឯប្រទេសជប៉ុនវិញឆ្លងកាត់ជាច្រើន សម័យកាលមកគឺប្រទេសដំបូងដែលប្រកាន់យកលទ្ធិអធិរាជនិយមនេះ ក៏មានរដ្ឋធម្មនុញ្ញដែរនៅសម័យម៉េជិឆ្នាំ១៨៨៩ ។រដ្ឋធម្មនុញ្ញដំបូងគឺរដ្ឋធម្មនុញ្ញមេជិនេះ គឺផ្តល់អំណាចទាំងបីស្ថិតនៅអធិរាជជាអ្នកគ្រប់គ្រង គឺអធិរាជមានអំណាចទាំងអស់ ក្នុងកិច្ចការផ្សេងៗ ។ប្រទេសសជប៉ុនធ្វើបែបនេះគឺ ក្នុងបំណងពង្រឹងអំណាច អធិរាជ និងខ្សែរាជវង្ស ឱ្យមានឥទ្ធិពលក្នុងការដឹកនាំ ហើយអាចលូកដៃក្នុងអំណាចទាំងបីបានដោយងាយ។

រដ្ឋធម្មនុញ្ញសម័យមេជិ នោះពុំមានការត្រួតពិនិត្យធម្មនុញ្ញភាពនោះទេ ពោលគឺនត្ថិភាពនៃការត្រួតពិនិត្យធម្មនុញ្ញភាព។ រហូតមកដល់ពេលដែលជប៉ុនចាញ់សង្គ្រាមលោកលើកទី២ ទើបបង្កើតឱ្យមានរដ្ឋធម្មនុញ្ញថ្មីមួយទៀត ដែលមានការជ្រោមជ្រែងពីសហរដ្ឋអាមេរិក ដោយសន្និសញ្ញាGHQក្នុងគោលបំណងរឹតបន្តឹងនយោបាយជប៉ុនឱ្យឈានទៅរកប្រជាធិបតេយ្យ និង កាត់បន្ថយអំណាចរបស់អធិរាជ។រដ្ឋធម្មនុញ្ញថ្មីនោះមានការដាក់ឈ្មោះផ្លូវការថា រដ្ឋធម្មនុញ្ញប្រទេសជប៉ុនតែម្តង។នៅក្នុងនោះដែរ បើពិនិត្យទៅលើការត្រួតពិនិត្យធម្មនុញ្ញភាព គឺរដ្ឋធម្មនុញ្ញនេះមានចែងអំពីការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដោយចែងនៅក្នុងមាត្រា៨១ ថា តុលាការកំពូល ជាតុលាការចុងក្រោយដែលមានអំណាចកាត់សេចក្តីថា តើច្បាប់ បទបញ្ជា បទបញ្ជាផ្ទៃក្នុង ដីកា សារាចរជាដើម ស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។ដូចនេះមានន័យថា ពុំមែនតែតុលាការកំពូលទេ ដែលមានសិទ្ធិនៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព គឺ តុលាការគ្រប់ជាន់ថ្នាក់ នៅប្រទេសជប៉ុនអាចមានសិទ្ធិត្រួតពិនិត្យធម្មនុញ្ញភាពបាន ហើយអាចមានសិទ្ធលុបចោលលិខិតបទដ្ឋានទាំងនោះថែមទៀតផង។ការណ៍នេះបានបញ្ជាក់ឱ្យឃើញថា ប្រទេសជប៉ុនមានការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាលតែប៉ុណ្ណោះ។ គឺក្រោយពេលមានបណ្តឹងទាក់ទងនឹងអធម្មនុញ្ញភាពចំពោះរឿងក្តីរបស់ គូភាគីដែលប្តឹងមកតុលាការតែប៉ុណ្ណោះ។ចំណែកឯការត្រួតពិនិត្យជាអាទិកាលដូចកម្ពុជាវិញនោះគឺពុំមាននោះទេ ដោយហេតុថា ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានក្រុមប្រឹក្សាអ្នកច្បាប់នៃប្រទេសជប៉ុនធ្វើការត្រួតពិនិត្យច្បាប់នោះ ម៉ត់ចត់ខ្លាំងបំផុតទើបធ្វើឱ្យពុំមានស្ថាប័នណាផ្សេងទៀត ដែលបង្កើតឡើងពិនិត្យធម្មនុញ្ញភាពជាអាទិកាលមុននឹងបញ្ជូនទៅអធិរាជឡាយព្រហស្តលេខា។ ជាមួយគ្នានេះផងដែរដោយសារការត្រួតពិនិត្យនៅស្ថាប័នទីស្តីការគណៈរដ្ឋមន្ត្រីនៃប្រទេសជប៉ុនខ្លាំងពេកទើបធ្វើអោយអ្នកខ្លះគេយល់ថា ពុំមានការឆ្លើយឆ្លងនៅក្នុងរដ្ឋសភានៅពេលបង្កើតច្បាប់មួយ។ការអនុវត្តកន្លងមក នៅប្រទេសជប៉ុនទោះបីជា ខាងស្ថាប័ននីតិប្រតិបត្តិត្រួតពិនិត្យលើបញ្ហាធម្មនុញ្ញភាព នេះដែរ ក៏នៅតែមានបញ្ញត្តិខ្លះ អធម្មនុញ្ញស្វែងរកដោយតុលាការរបស់ជប៉ុននោះដែរ។ រីឯបញ្ហាមួយទៀត គឺ តុលាការនៅប្រទេស ជប៉ុនគឺឈរលើគោលការណ៍ផ្ទត់គំនិត សិទ្ធិមនុស្សជាដើម ខ្លាំងពេកដែលនាំឱ្យចេះតែពិនិត្យឃើញនូវ អត្ថិភាពនៃអធម្មនុញ្ញមាននៅក្នុងច្បាប់។ការណ៍ដែលធ្វើឱ្យមានបញ្ហាដូច្នេះគឺ តុលាការជប៉ុនឈរលើ គោលជំហរគោរពប្រជាធិបតេយ្យនៅក្នុងការអនុវត្តច្បាប់របស់ខ្លួន ក៏ដូចជាការពិចារណាទៅលើ រឿងក្តី ដែលប្តឹងអំពីអធម្មនុញ្ញភាព ទើបធ្វើឱ្យបណ្តឹងនេះមានច្រើនកើតឡើងនៅប្រទេសជប៉ុន។ជាមួយនឹងដំណោះស្រាយដ៏ចាំបាច់នៅប្រទេសជប៉ុន គួរតែមានតុលាការធម្មនុញ្ញ ឬស្ថាប័នណាមួយ ដែលសិទ្ធិ និង តួនាទីពិនិត្យច្បាប់ ដើម្បីកុំឱ្យខាងនីតិប្រតិបត្តិត្រួតពិនិត្យតែឯកឯងម្យ៉ាងទៀតគួរតែ ស្ថាប័នពិសេសនេះជាស្ថាប័នមួយឯករាជ្យ ។ តុលាការមានឆន្ទានុសិទ្ធិក្នុងការអនុវត្តច្បាប់ តែនេះបែរជាអនុវត្តច្បាប់ផង ត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ទៀត ដែលជាការធ្វើការ

ច្រើន ទាក់ទងទៅនឹង ការឡូកឡំនៃអំណាច។ ការបង្កើតឡើងនូវស្ថាប័នពិសេសត្រួតពិនិត្យធម្មនុញ្ញនៅប្រទេស ជប៉ុននឹងអាចជួយសម្រួល នូវអំណាចក៏ដូចជា សមត្ថកិច្ចច្បាស់លាស់ នៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព។

យោងតាមការបកស្រាយខាងលើ ឃើញថាប្រព័ន្ធនៃការត្រួតពិនិត្យធម្មនុញ្ញទាំងពីរ ទាំងប្រទេសកម្ពុជា និង ជប៉ុន គឺមានភាពស្របគ្នាមួយចំនួនដូចជាការបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាលដូចគ្នា គឺឱ្យខាងនីតិឯករាជ្យគឺតុលាការជាអ្នកពិនិត្យមើលទៅលើបណ្តឹង។ តែទាស់ត្រង់ថា តុលាការនៅកម្ពុជាត្រូវបញ្ជូនបណ្តឹងអធម្មនុញ្ញភាពនោះទៅតុលាការកំពូល ដោយពុំមានចេញសេចក្តីសម្រេចនោះទេ រីឯតុលាការជប៉ុនគ្រប់ជាន់ថ្នាក់មានសិទ្ធិសម្រេចលើបណ្តឹងនោះអធម្មនុញ្ញតែម្តង។ ចំណុចដូចគ្នាមួយទៀតគឺប្រទេសជប៉ុន និង កម្ពុជាគឺយករដ្ឋធម្មនុញ្ញជាគោលការណ៍នៅក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពដូចគ្នា ដែលពុំឱ្យច្បាប់ណាមួយផ្ទុយទៅនឹងស្មារតីនៃរដ្ឋធម្មនុញ្ញ ឡើយ។ទោះបីជា ប្រព័ន្ធទាំងពីរមានការត្រួតពិនិត្យធម្មនុញ្ញភាពក៏ដោយក៏នៅមានចំណុចមួយចំនួនខុសគ្នាដែរ គឺត្រង់ថា នៅប្រទេសជប៉ុនពុំមានក្រុមប្រឹក្សាធម្មនុញ្ញដូចនៅកម្ពុជាទេ គឺមានតែស្ថាប័នតុលាការតែមួយគត់ ដែលជាអ្នកត្រួតពិនិត្យមើលធម្មនុញ្ញភាពនៅពេលអនុវត្តដំណើរការរឿងក្តី។ រីឯកម្ពុជាយើងវិញ មានក្រុមប្រឹក្សាមួយដាច់ដោយឡែកគឺក្រុមប្រឹក្សាធម្មនុញ្ញតែម្តង ដែលជាអ្នកត្រួតពិនិត្យលើច្បាប់ ដែល រដ្ឋសភា និង ព្រឹទ្ធសភាក៏ដូចជាសេចក្តីព្រាងរបស់រដ្ឋាភិបាល ឬ បទបញ្ជាផ្សេងៗ ជាមួយនឹងរដ្ឋធម្មនុញ្ញ។ទន្ទឹមនឹងនេះផងដែរ នៅប្រទេសជប៉ុនតុលាការមានសិទ្ធិចេញសេចក្តីសម្រេចអធម្មនុញ្ញភាព រីឯនៅកម្ពុជាយើងវិញ គឺសេចក្តីសម្រេចនោះត្រូវធ្វើឡើងតាមរយៈក្រុមប្រឹក្សាធម្មនុញ្ញដែលជាអ្នកមានសិទ្ធិពិនិត្យ ថា ស្រប ឬ មិនស្របទៅនឹងរដ្ឋធម្មនុញ្ញ។

នៅប្រទេសកម្ពុជា គឺមានស្ថាប័នក្រុមប្រឹក្សាមួយដ៏ត្រឹមត្រូវដាច់ដោយឡែកពីស្ថាប័នទាំងបីតែ ហាក់ដូចជានៅមានចំណុចខ្សោយបន្តិចត្រង់ថា សមាជិកភាពពុំសូវច្បាស់លាស់ដាច់ពីអំណាចទាំងបីនោះទេ។ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ នៅកម្ពុជាមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈ អ្នកស្នើសុំដែលច្បាប់មានកំណត់ត្រឹមត្រូវ និងឋានានុក្រម ទោះបីជាបណ្តឹងពីប្រជារាស្ត្រក៏ដោយ។ រីឯ ប្រទេសជប៉ុនវិញពុំទាន់មានស្ថាប័នមួយដាច់ដោយឡែកក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនោះទេ គឺស្ថិតនៅក្នុងដៃរបស់តុលាការជប៉ុនគ្រប់ជាន់ថ្នាក់។ការពិនិត្យធម្មនុញ្ញភាពនៅស្ថាប័ននីតិប្រតិបត្តិគឺមានភាពតឹងរ៉ឹង ពុំចែករំលែកអំណាចនោះឡើយ ដែលសឹងតែនាមឱ្យរដ្ឋសភា និងព្រឹទ្ធសភាចាំតែអនុម័តតែប៉ុណ្ណោះ។ នេះក៏ជានីតិវិធីល្អដែរ ក៏ប៉ុន្តែវាហាក់ដូចជាការបង្កើតច្បាប់នោះមានសភាតែមួយក្នុងការធ្វើការងារ។ តុលាការប្រទេសជប៉ុនហាក់ដូចជាអ្នកអនុវត្តច្បាប់ផង និង

ត្រួតពិនិត្យច្បាប់ទៀត គឺ ត្រួតពិនិត្យធម្មនុញ្ញភាពដោយសិទ្ធិមានក្នុងរដ្ឋធម្មនុញ្ញទៀតផង។យ៉ាងណាក្តីការត្រួតពិនិត្យធម្មនុញ្ញភាព គឺ ចាំបាច់ត្រូវតែមាននៅក្នុងប្រព័ន្ធច្បាប់រៀងខ្លួន ដើម្បីចៀសវាងភាពរំលោភអំណាច និង តម្លាភាព អព្យាក្រឹត្យដើម្បីឈានទៅរកនីតិរដ្ឋដែលទាំងកម្ពុជា និង ជប៉ុនចង់បានជានិរន្តរ៍។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សា ស្វែងយល់នូវប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៃប្រទេសកម្ពុជា យើងនិងប្រទេសជប៉ុនរួចមកឃើញថា ប្រព័ន្ធទាំងពីរថ្វីត្បិតតែអនុវត្តអត្ថិភាពនៃការត្រួតពិនិត្យធម្មនុញ្ញភាព នៃច្បាប់ និង ទទួលនូវការប្តឹងអំពីអធម្មនុញ្ញភាពប្រាកដមែន ប៉ុន្តែក៏នៅមានចំនុចខ្សោយមួយចំនួន ដែលត្រូវតែកែលម្អ និង ដោះស្រាយ ដើម្បីពង្រឹងនូវគោលការណ៍នីតិរដ្ឋ និង ប្រជាធិបតេយ្យនាសម័យបច្ចុប្បន្ននេះ។

សម្រាប់ព្រះរាជាណាចក្រកម្ពុជាយើងដើម្បីឱ្យក្រុមប្រឹក្សាធម្មនុញ្ញ សមជាស្ថាប័ននៃនីតិរដ្ឋដ៏មានប្រសិទ្ធិភាពមួយ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលត្រូវធ្វើការកែលម្អដូចខាងក្រោមៈ

- ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញក៏ជាស្ថាប័នមួយដែលត្រូវតែមានឯករាជ្យភាពនៅក្នុងការអនុវត្ត និង អំណាចមុខងាររបស់ខ្លួន យ៉ាងដាច់ដោយឡែកពីស្ថាប័នផ្សេងៗទៀត ដូច្នេះសមាសភាពនៃបុគ្គល ដែលជាបេក្ខជនក៏ត្រូវតែជាបុគ្គលដែលឯករាជ្យនោះដែរទើបការពិនិត្យផ្ទៀងផ្ទាត់ធម្មនុញ្ញភាពពុំមានភាពលំអៀង និងទទួលបាននូវ តម្លាភាព និង អព្យាក្រឹត្យភាពដ៏ប្រសើរ។
- មកដល់នវសម័យនាពេលបច្ចុប្បន្ននេះ គឺស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ឬ ពុំទាន់មានច្បាប់ណាមួយដែលកំណត់អំពីនិយមន័យ ទៅលើពាក្យថា អធម្មនុញ្ញភាពនោះទេ ថាតើគោលការណ៍ដែលពិនិត្យអធម្មនុញ្ញភាពនោះមានអត្ថន័យយ៉ាងណាក៏ពុំបានសរសេរចារឹកប្បញ្ញត្តិ នៅក្នុងច្បាប់ណាមួយឱ្យប្រាកដនោះដែរ។
- នៅក្នុងករណីបន្ទាន់បង្ហំ រឿងក្តីនៅតុលាការ បុគ្គលដែលអាចប្តឹងអំពីអធម្មនុញ្ញភាពចំពោះរឿងក្តីរបស់ខ្លួន អំពីបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចនានាដែលគេអះអាងថាប៉ះពាល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនទៅតុលាការ តុលាការថ្នាក់ក្រោមត្រូវលើកករណីនេះទៅតុលាការកំពូល។ករណីនេះបើអ្នកប្តឹងគេប្តឹងពីតុលាការ តើតុលាការបញ្ជូនបណ្តឹងនេះមកក្រុមប្រឹក្សាធម្មនុញ្ញដែរឬទេ? ដូច្នេះក្នុងករណីបែបនេះគួរអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចប្តឹងផ្ទាល់មកក្រុមប្រឹក្សាធម្មនុញ្ញតែម្តង គឺជាការសមរម្យនៃការពុំខ្ជះខ្ជាយពេលវេលា និង បញ្ហាចំពោះការបិទសំណុំរឿងចោល។
- បើយោងទៅតាមមាត្រា១៤០ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមិនមានការស្នើឡើងឱ្យពិនិត្យធម្មនុញ្ញភាពដោយព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រមួយភាគដប់ សមាជិកព្រឹទ្ធសភាមួយភាគបួន ឬ តាមរយៈតុលាការនោះទេ ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសិទ្ធិសម្រេចលើបណ្តឹង ឬ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់បទប្បញ្ញត្តិ និង ការសម្រេចលើបណ្តឹងឬ ពិនិត្យលើច្បាប់បទប្បញ្ញត្តិ និង ការសម្រេចរបស់

ស្ថាប័នណាមួយបានឡើយ។ ដូចនេះអ្នកតាក់តែងច្បាប់ផ្ទាល់ ក៏ត្រូវតែគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ នេះមានន័យថា ពួកគេមិនអាចធ្វើច្បាប់ដែលមានលក្ខ-ណៈបំពានដល់ សិទ្ធិមនុស្ស ឬ បទដ្ឋានច្បាប់ និង គោលការណ៍នានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនោះទេ។ ដូច្នេះច្បាប់ទាំងអស់គឺអាចស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថា តើវាស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ។តាមមាត្រា៩២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បានចែងថា ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព ទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាព នយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការ តែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ។

- មិនគួរឱ្យក្រុមប្រឹក្សាធម្មនុញ្ញមកត្រួតពិនិត្យលើច្បាប់រដ្ឋសភា ដែលជាតំណាងរបស់រាស្ត្រ ពីព្រោះសមាជិករដ្ឋសភាជ្រើសតាំងឡើងដោយឆន្ទៈរបស់ប្រជារាស្ត្រក៏ពិតៗទូទាំងប្រទេស តើចាំបាច់អ្វីដែលបង្កើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញដែលមានសមាជិក០៩រូបប៉ុណ្ណោះ ហើយមានអំណាច ដ៏ធំធេងរហូតដល់រំលាយច្បាប់ ដែលរដ្ឋសភា និង ព្រឹទ្ធសភាអនុម័ត។គួរតែមានស្ថាប័នមួយទៀត ដើម្បីត្រួតពិនិត្យលើរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា និង តុលាការ ពីព្រោះថា ទោះបី ជាតំណាងរាស្ត្រកើតចេញពីការជ្រើសតាំងក្រោមឆន្ទៈរបស់ប្រជារាស្ត្រក៏ពិតមែន ប៉ុន្តែរដ្ឋសភា ព្រឹទ្ធសភា និង រាជរដ្ឋាភិបាលសុទ្ធតែកើតចេញពីគណបក្សនយោបាយ ដែលជាហេតុធ្វើឱ្យមាន ការបំពានតាមអំពើចិត្តទៅលើរដ្ឋធម្មនុញ្ញ។ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់របស់ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាលក្ខខណ្ឌមួយនៃការគោរពនីតិរដ្ឋ និង សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ក្នុងករណី នេះមានសំណួរមួយចោទសួរថា តើត្រូវឱ្យស្ថា-ប័ននេះស្ថិតក្នុងដៃតុលាការ ឬ ក៏នៅឯករាជ្យ?

ចំណែកឯការត្រួតពិនិត្យធម្មនុញ្ញភាពដែលតម្រូវឱ្យមានការកែប្រែ និង ផ្លាស់ប្តូរមួយចំនួនដើម្បីអនុវត្តឱ្យបាននូវនីតិរដ្ឋ និង ច្បាស់លាស់ចំពោះការត្រួតពិនិត្យធម្មនុញ្ញភាពប្រទេសជប៉ុនគួរតែ គិតគូរដល់ប្រការមួយចំនួនដូចខាងក្រោម៖

- ប្រទេសជប៉ុន ថ្វីត្បិតតែការត្រួតពិនិត្យធម្មនុញ្ញភាពធ្វើឡើងតឹងរ៉ឹងម៉ត់ចត់ នៅស្ថាប័ននីតិប្រតិបត្តិក៏ដោយ ក៏ចាំបាច់ត្រូវមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពមួយដាច់ដោយឡែកនោះដែរគឺដើម្បីអនុវត្តមុខងារក្នុងការពិនិត្យនិងសម្រេចលើបណ្តឹងទាក់ទងទៅនឹងបញ្ហាអធម្មនុ-ញ្ញភាព។ការបង្កើតឱ្យមានស្ថាប័នត្រួតពិនិត្យធម្មនុញ្ញភាពថ្មី គឺអាចមានភាពទុកចិត្តទៅលើការ ត្រួតពិនិត្យដោយឯករាជ្យ ដោយពុំខ្វល់ពីអំណាចឡុកឡំគ្នា ធ្វើច្បាប់ផងពិនិត្យធម្មនុញ្ញភាពផង ដែលនាំឱ្យមានភាពស្មុគស្មាញរឿងភាពលំអៀង។

- នៅប្រទេសជប៉ុនតុលាការសាម៉ីអាចមានសិទ្ធិពិនិត្យ និងមានសិទ្ធិចេញសេចក្តីសម្រេចទៅលើ បណ្តឹងអធម្មនុញ្ញភាពនោះបានប្រសិនបើការពិនិត្យនោះយល់ឃើញថា អធម្មនុញ្ញភាព។ នេះជាការអនុវត្តមុខងារមួយដោយមាន ភាពរប៉ាត់រប៉ាយមិនច្បាស់លាស់ និង ជំនាញខាងច្បាប់។ ក្នុងករណីនេះប្រសិនបើអាចបង្កើត តុលាការធម្មនុញ្ញ បានគឺរឹតតែប្រសើរ ព្រោះប្រទេសជប៉ុន ទាក់ទងទៅនឹងបណ្តឹងអធម្មនុញ្ញភាពនេះគឺកើតមានច្រើន។
- នៅពេលដែលច្បាប់ឬ ប្បញ្ញត្តិណាមួយដែលត្រូវបានប្រកាសថា អធម្មនុញ្ញភាព ដោយតុលាការ ឬក៏ស្ថាប័ននីតិប្រតិបត្តិខ្លួនឯងផ្ទាល់ច្បាប់នោះគឺត្រូវធ្វើវិសោធនកម្មដោយការស្នើសុំរបស់សភា មិនជាការឃើតឃូរឡើយ។ដូច្នេះបង្កើតច្បាប់ដោយខ្លួនឯង ពិនិត្យដោយខ្លួនឯង និង កែប្រែ កំហុសឆ្គង ដោយខ្លួនឯង ពោលគឺអំណាចប្រមូលផ្តុំ។
- ដោយសារតែពុំមានស្ថាប័នច្បាស់លាស់ តុលាការគ្រប់ជាន់ថ្នាក់អាចមានសិទ្ធិប្រកាសច្បាប់ ឬ ប្បញ្ញត្តិណាមួយថា អធម្មនុញ្ញភាពបានដោយខ្លួនឯង តាមការយល់ឃើញ និង ការត្រួតពិនិត្យ របស់ចៅក្រមនៅតុលាការសាម៉ី នេះជាប្រការមួយដែលត្រឹមតែជាការយល់ឃើញតែប៉ុណ្ណោះ ហើយក៏សម្រេចប្រកាសថា អធម្មនុញ្ញ ។ច្បាប់ដែលរដ្ឋសភា និង ព្រឹទ្ធសភាអនុម័ត គឺឆ្លងកាត់ នូវភាពតឹងរឹងបំផុត ត្រឹមតែតុលាការមានតែសិទ្ធិអនុវត្តច្បាប់ គឺពុំអាចរំលាយច្បាប់ដោយចេញ សេចក្តីសម្រេចថា អធម្មនុញ្ញឡើយ។

## ឯកសារយោង


- **ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត**
  - រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ឆ្នាំ១៩៤៧-១៩៧០
  - រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ ឆ្នាំ១៩៧០-១៩៧៥
  - រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ឆ្នាំ១៩៨៩-១៩៩៣
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ កែប្រែដល់ឆ្នាំ២០០១
  - ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨
  - ច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ខែមករា ឆ្នាំ២០០៧
  - អនុក្រឹត្យលេខ៤២ អនក្រ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
  - បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តទៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
  - បទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ
  - បទបញ្ជាផ្ទៃក្នុងនៃសាលាជំនុំជម្រះក្រុមប្រឹក្សាធម្មនុញ្ញ
  - បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា
  - បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- **ឯកសារជាភាសាខ្មែរ**
  - ឈុន ណារ៉េត.ឆ្នាំ២០១២.*សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ*.ភ្នំពេញ.រោងពុម្ពដារ៉ា។
  - សាយ បូរី.ឆ្នាំ ២០០១.*នីតិរដ្ឋបាលទូទៅ*.ភ្នំពេញ.
  - ហៀង សាង.ឆ្នាំ ២០១២ .*នីតិរដ្ឋបាលទូទៅ*.ភ្នំពេញ.
  - អ៊ិន បូជា.ឆ្នាំ ២០០៦ .*នីតិរដ្ឋធម្មនុញ្ញ*.ភ្នំពេញ
- **ឯកសារជាភាសាបរទេស**
  - **ភាសាអង់គ្លេស**
  - Constitutional Law of Foreign Country Part II M 1994 Page 322
    - នីតិរដ្ឋធម្មនុញ្ញនៃប្រទេសបរទេស ភាគ២ ឆ្នាំ១៩៩៤ ទំព័រ៣២២
  - **ភាសាបារាំង**

- Introduction générale au Droit ; François Terré Précis Dalloz 1991
- L'Accef sur le principe d'égalité dans la jurisprudence des Cours constitutionnelles et Institutions de compétence équivalente ayant en partage l'usage du française, septembre 1998.

- La Protection constitutionnelle et protection internationale des Droits de l'Homme: concurrence ou complémentarité? conférence des Cours constitutionnelles européennes- Paris- mai 1993.
- Le Conseil Constitutionnel A 40 ans, Librairie Générale des droit et jurisprudence, E.J.A, 31, rue Falguière, 75015 Paris, et Conseil constitutionnel, 1999.
- La Collection Science et technique de la démocratie, n° 15, la protection des
- droits fondamentaux par la cour constitutionnelle, Édition du Conseil de l'Europe F-67075 Strasbourg Cedex, 1996.


▪ **ភាសាជប៉ុន**


- 明治憲法 រដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យម៉េជិ
- 日本国憲法 រដ្ឋធម្មនុញ្ញប្រទេសជប៉ុន
- 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民』（カンボジア版）（2011 年 2 月）
    - មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រវត្តិសាស្ត្រ និង ពលរដ្ឋវិទ្យា ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកុម្ភៈ ឆ្នាំ ២០១១)
- 名古屋大学日本法教育研究センター『日本法を学ぶための日本法システム』（カンボジア版）（2013 年 9 月）
    - មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវច្បាប់ប្រទេសជប៉ុន នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា 『ប្រព័ន្ធច្បាប់ប្រទេសជប៉ុន ដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន』(ភាសាខ្មែរ) (ខែកញ្ញា ឆ្នាំ ២០១៣)
- 衆議院憲法調査会事務局『「司法制度及び憲法裁判所（憲法の有権解釈権の所在の視点から）」に関する基礎的資料』（衆憲資第 29 号）（2013）
    - ការិយាល័យស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា 『ឯកសារមូលដ្ឋានទាក់ទងនឹង「ប្រព័ន្ធយុត្តាធិការ និង តុលាការធម្មនុញ្ញ （ពីចក្ខុវិស័យ នៃសិទ្ធិមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ（លេខ ២៩）（ឆ្នាំ ២០១៣）
- 衆議院憲法調査会事務局（平成 16 年 3 月）「最高法規としての憲法のあり方に関する調査小委員会」
    - ការិយាល័យស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា（ឆ្នាំ ២០០៤ ខែ មិនា）「គណៈកម្មា-ការស្រាវជ្រាវនីតិរដ្ឋធម្មនុញ្ញក្នុងនាមជាច្បាប់កំពូល」
- 市川正人「日本における違憲審査制の軌跡と特徴」立命館法学 2004 年 2 号（294 号)

- ម៉ាសាអុ អ៊ិឈិការ៉ា 「លក្ខណៈពិសេស និង ការដំណើរការប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពនៅប្រទេសជប៉ុន」សាកលវិទ្យាល័យនីតិសាស្ត្រ វិស្សឹមេកាន ឆ្នាំ២០០៤ លេខ ២ (វ៉ុល ២៩៤)

- 野中俊彦ほか『憲法Ⅱ【第４版】』（有斐閣、2010 年）
    - តុស៊ិហិកុ ណុណាកា ផ្សេងៗ『រដ្ឋធម្មនុញ្ញ Ⅱ【បោះពុម្ពលើកទី ៤】』（រោងពុម្ព យឺហិកាកុ、ឆ្នាំ ២០១០）
- 初宿正典・その他、『憲法入門【第 4 版補訂版】』（有斐閣、2014 年）
    - ឯកសារផ្សេងៗ、『សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ【បោះពុម្ពលើកទី ៤ កែតម្រូវ】』（រោងពុម្ព យឺហិកាកុ、ឆ្នាំ ២០១៤）
- 佐藤岩夫「違憲審査制と内閣法制局」社會科學研究 56 巻 5、6 号（2005 年）
    - សាតុ អ៊ិវ៉ាអុ 「ប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាព និង ក្រុមប្រឹក្សាអ្នកច្បាប់នៅគណៈរដ្ឋមន្ត្រី」ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម វ៉ុល ៥៦ លេខ ៥、៦ (ឆ្នាំ ២០០៥)
- ヘイリー、ジョン (1995) 「日本における司法の独立・再考」 ( 浅香吉幹訳) 石井紫郎・樋口範雄編『外から見た日本法』東京大学出版会
    - ហៃលលីចន(ឆ្នាំ ១៩៩៥) 「ការពិចារណាឡើងវិញអំពីឯករាជ្យភាពតុលាការនៅប្រទេសជប៉ុន」『កាសង្កេតច្បាប់នៃប្រទេសជប៉ុនពីមជ្ឈដ្ឋានខាងក្រៅ』មូលនិធិបោះពុម្ពនៃសាកលវិទ្យាល័យតូក្យូ
- 樋口陽一 (1998) 『憲法( 改訂版) 』割文社
    - យុអ៊ិឈិ ហិហ្គឹឈិ (ឆ្នាំ ១៩៩៨) 『រដ្ឋធម្មនុញ្ញ(បោះពុម្ពសារឡើងវិញកែសម្រួល) 』រោងពុម្ព វ៉ារិបឹនស្យា
- 樋口陽一、辻村みよ子、山内敏弘嬬 (1999) 『憲法判例を読み直す: 下級審判決からのアプローチ』日本評論社
    - យុអ៊ិឈិ ហ៊ិហ្គឹឈិ、ស្សឹជិមឹរា មិយុកុ、យ៉ាម៉ាអឹឈិ តុស៊ិហ៊ិរុ (ឆ្នាំ ១៩៩៩) 『អានឡើងវិញសាលដីការដ្ឋធម្មនុញ្ញ: ការចូលទៅជិតសាលក្រមតុលាការជាន់ទាប』រោងពុម្ព នីហុងហ្យូរុងស្យា
- 伊藤正己 (1993) 『裁判官と学者の開』 有斐閣
    - អ៊ិតុ ម៉ាសាមិ(ឆ្នាំ ១៩៩៣) 『តុលាការ និង អ្នកស្រាវជ្រាវ』 រោងពុម្ព យឺហិកាកុ

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## មាត្រាខ្លះនៃរដ្ឋធម្មនុញ្ញនៃ

## ព្រះរាជាណាចក្រកម្ពុជា

## ទាក់ទងនឹងក្រុមប្រឹក្សាធម្មនុញ្ញ

# ឧបសម្ព័ន្ធទី២

## ច្បាប់ស្ដីពីវិសោធនកម្មស្ដីពីការរៀបចំ

## និង

## ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

## (នៅកម្ពុជា)

# ឧបសម្ព័ន្ធទី៣

## បទបញ្ជាស្ដីពីនីតិវិធីដែលត្រូវអនុវត្ត
## នៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## ( នៅកម្ពុជា )

# ឧបសម្ព័ន្ធទី៤

## បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាធម្មនុញ្ញ

## ( នៅកម្ពុជា )

# ឧបសម្ព័ន្ធទី៥

## មាត្រាបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ

## ប្រទេសជប៉ុនអំពីសមត្ថកិច្ច

## ត្រួតពិនិត្យធម្មនុញ្ញភាព